

# ការកាត់ទោសដោយមហាជន
# ការបង្ការ និងការឆ្លើយតបចំពោះ
# “ការកាត់ទោសដោយមហាជន”

## នៅកម្ពុជា

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ស៊ុយអែត
Sverige

ឧបត្ថម្ភថវិកាដោយប្រទេសស៊ុយអែត

ឯកសារនេះ បោះពុម្ពផ្សាយក្រោមជំនួយថវិការបស់ប្រទេសស៊ុយអែត។ មាតិកា ឬខ្លឹមសារនៅក្នុងឯកសារនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬការយល់ឃើញណាមួយរបស់ប្រទេសស៊ុយអែតឡើយ។

# តារាងមាតិកា


១. សេចក្តីសង្ខេប ............................................................................ ១
២. សេចក្តីផ្តើម....................................................................................២
៣. វិធីសាស្រ្ត ..................................................................................... ៧
៤. អំពើនៃ ការកាត់ទោសដោយមហាជន នៅកម្ពុជា ....................... ៨
៤.១. ការបង្ហាញពីអំពើនៃ ការកាត់ទោសដោយមហាជន ភ្លាមៗ ចំពោះជនដែលត្រូវបានចោទពីបទលួច ប្លន់ បទល្មើសព្រហ្មទណ្ឌ ឬពីការបង្កគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវ.......................... ៨
៤.១.១. ករណីនៃអំពើហិង្សាដោយមហាជន............................. ៨
៤.១.២. មូលហេតុនាំឲ្យឈានដល់អំពើនៃ ការកាត់ទោសដោយមហាជនភ្លាមៗ ......................................... ១០
៤.២. ការបង្ហាញពីអំពើនៃ ការកាត់ទោសដោយមហាជន ប្រឆាំងនឹងអ្នកដែលត្រូវបានចោទថាធ្វើអំពើអាបធ្មប់ ............................... ១៣
៤.២.១. ការចោទប្រកាន់ពីការប្រព្រឹត្តអំពើអាបធ្មប់ និងការធ្វើទុក្ខបុកម្នេញ ........................................ ១៣
៤.២.២. ទិដ្ឋភាពទូទៅនៃព្រឹត្តិការណ៍វាយប្រហារប្រឆាំងនឹងអ្នកដែលត្រូវបានចោទថាធ្វើអំពើអាបធ្មប់ .................. ១៤
៤.២.៣. មូលហេតុនាំឲ្យមានការចោទប្រកាន់ពីអំពើអាបធ្មប់ និងការធ្វើទុក្ខបុកម្នេញ ........................................ ១៨
៥. កាតព្វកិច្ចរបស់រដ្ឋដើម្បីបង្ការ និងការពារប្រឆាំងនឹង "ការកាត់ទោសដោយមហាជន"........................................ ១៩
៦. ការឆ្លើយតបដោយអាជ្ញាធរពាក់ព័ន្ធ.................................២២
៦.១ ក្របខ័ណ្ឌច្បាប់ និង គោលនយោបាយការពារនៅកម្ពុជា............២២
៦.២ ការបង្ការ ...........................................................................២៣
៦.៣ ការស៊ើបអង្កេត និងការចោទប្រកាន់.....................................២៦
៦.៤ ដំណោះស្រាយ និងការជួសជុលសំណង................................២៩
៧. សេចក្តីសន្និដ្ឋាន ........................................................................ ៣១
៨. អនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា.............................៣៣

# សេចក្តីសង្ខេប

អំពើហិង្សានៃអ្វីដែលហៅថា “ការកាត់ទោសដោយមហាជន” ដូចជា ការសម្លាប់ ការវាយដំលើមនុស្ស ដែលត្រូវបានចោទថា បានប្រព្រឹត្តអំពើល្មើសណាមួយ នៅតែឃើញបន្តកើតមាននៅព្រះរាជាណាចក្រកម្ពុជា។ ពាក្យ “ការកាត់ទោសដោយមហាជន” សំដៅដល់អំពើរបស់ប្រជាជនយកច្បាប់មកអនុវត្តដោយខ្លួនឯង ជាទូទៅពាក់ព័ន្ធនឹងអំពើហិង្សា ជារឿយៗ ជាការសងសឹកដល់ជនប្រព្រឹត្តល្មើស ជួនកាលជាការឆ្លើយតបនឹងការគំរាមកំហែង។ នៅកម្ពុជាវាអាចជាប្រតិកម្មភ្លាមៗពីហ្វូងមហាជន បន្ទាប់ពីហេតុការណ៍មួយភ្លាមៗ ឬក៏ជាឃាតកម្មគិតទុកជាមុន ប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ បណ្តាលមកពី ជួនកាល ការភ័យខ្លាច និងភាពជូរចត់ជាច្រើនឆ្នាំ។ និយាយដោយឡែក ការភ័យខ្លាចនេះហើយដែលនាំឱ្យមានការសម្លាប់ ការវាយដំ ការឃាយី និង/ឬការជម្លៀសអ្នកដែលត្រូវបានចោទពីការធ្វើអំពើអាបធ្មប់។ អ្នកដែល ត្រូវកំណត់ថាជាអាបធ្មប់ ឬគ្រូធ្មប់ ក្លាយជាអ្នកទទួលរងថ្មបាក់ចំពោះបញ្ហាផ្សេងៗនៅក្នុងភូមិ។ បញ្ហាទាំងនេះរួមមានកាសង្ស័យទៅលើគ្រោះកាចអកុសល ការឈឺចាប់ ជំងឺដង្កាត់ និងមរណភាពនៅក្នុងភូមិជាដើម។ ក្នុងគ្រប់ករណី ជនល្មើសមានអារម្មណ៍ ថាអ្វីដែលពួកគេកំពុងធ្វើ គឺត្រឹមត្រូវ ហើយអ្នកដទៃនឹងគាំទ្រនូវទង្វើរបស់ខ្លួន។

ក្នុងឆ្នាំ២០១៦ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ( OHCHR ) បានចាប់ផ្តើមការងារឡើងវិញអំពី “ការកាត់ទោសដោយមហាជន” ដែលបានធ្វើកាលពីដើមទសវត្សឆ្នាំ២០០០ និងបានចាប់ផ្តើមចងក្រងជាឯកសារករណីនៃការសម្លាប់ដោយមហាជន ដើម្បីស្វែងយល់ពីបរិបទដែលករណីទាំងនេះកើតឡើង និងផ្តល់អនុសាសន៍អំពីរបៀបដោះស្រាយស្ថានភាពទាំងនេះ។ របាយការណ៍នេះ គឺជាការប៉ុនប៉ងវិភាគលើកទីមួយ អំពី

កាលពីខែកក្កដា ឆ្នាំ២០១៧ នៅភ្នំពេញ មានក្មេងប្រុសម្នាក់ឈ្មោះឡេង[១] កំពុងតែដើរឆ្វេលជុំវិញផ្ទះតូចៗ ដែលមានកម្មករ រោងចក្ររស់នៅ។ មានមនុស្សម្នាក់ បានចោទក្មេងប្រុសនេះពីការពាក់អាវយឺតដូចគ្នាទៅនឹងអាវយឺតមួយ ដែលត្រូវបានគេលួចកាលពីមុននៅក្នុងតំបន់នេះ។ មនុស្សជាច្រើនបានមកប្រមូលផ្តុំគ្នា ហើយចាប់ក្មេងប្រុសឡេង និងស្រែកថាពួកគេចាប់បានចោរ។ ពួកគេចាប់ចងដៃក្មេងប្រុសនោះទៅក្រោយ។ មនុស្សកាន់តែច្រើន បានមកកន្លែងកើតហេតុ។ មនុស្សម្នាក់ចាប់ផ្តើមវាយតប់ និងទាត់ធាក់គាត់។ អ្នកដទៃទៀតក៏បានចោលកំប៉ុងស្រាបៀចំក្បាលក្មេងប្រុសនោះ។ សាក្សីម្នាក់បានរាយការណ៍ថា ឡេងបានលុតជង្គង់ និងសូមការ សណ្តោសប្រណី។ ទឹកភ្នែកហូររហាមលាយនឹងឈាម ដែលហូរពីក្បាលមក។ បន្ទាប់មក ឡេងបានព្យាយាមរត់គេចពីការវាយដំហើយក៏បានធ្លាក់ទៅក្នុងអាងស្តុកទឹកស្អុយ។ មនុស្សម្នានៅស្ងៀមឈរមើលក្មេងនោះលង់ទឹកដោយមិនមានបំណងជួយសង្គ្រោះក្មេងនោះទេ។ បន្តិចក្រោយមកនៅពេលដែលនគរបាលមកដល់ វាបានហួសពេលអស់ទៅហើយ។ សាកសពក្មេងប្រុសដែលពោរពេញដោយស្លាកស្នាម ត្រូវបានរកឃើញនៅព្រឹកបន្ទាប់។ មន្ត្រីនគរបាលបានបើកការស៊ើបអង្កេត ហើយបានសន្និដ្ឋានថា ក្មេងប្រុសនេះបានស្លាប់ដោយសារលង់ទឹក។ ព្រះរាជអាជ្ញាបានកោះហៅមនុស្សមួយចំនួនមកតុលាការដើម្បីសាកសួរ តែបន្តិចក្រោយមកសំណុំរឿងនេះ ក៏ត្រូវបានបិទទៅ។ ការវាយដំដែលនាំឱ្យក្មេងលង់ទឹកនោះមិនត្រូវបានយកមកពិចារណា និងត្រូវបានអង្កេតនោះទេ។ គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួននោះដែរ។ មានបុរសម្នាក់ ត្រូវបានសម្ភាសន៍ប៉ុន្មានថ្ងៃក្រោយមកថា “ក្មេងប្រុសនេះគឺជាមនុស្សមិនល្អ។ វាតែងតែបង្ករឿង។ ឥឡូវ វាបានស្លាប់ហើយ។ វានឹងលែងមានបញ្ហាអ្វីទៀតហើយនៅទីនេះ។”

(ប្រភព៖ កិច្ចសម្ភាសន៍របស់ការិយាល័យOHCHRនៅកម្ពុជា។

១ ឈ្មោះទាំងអស់នៅក្នុងឯកសារនេះ ត្រូវបានដូរ ដើម្បីការពារភាពជាឯកជនរបស់បុគ្គលនោះ។.

យន្តការដែលនាំឱ្យមានអំពើហិង្សា សំដៅចំពោះអ្នកដែលត្រូវបានចោទពីការធ្វើអំពើអាបធ្មប់នៅកម្ពុជា។

"ការកាត់ទោសដោយមហាជន" នៅកម្ពុជាក៏ដូចជានៅក្នុងប្រទេសដទៃជុំវិញពិភពលោករីកធំធាត់ដោយសារតែការខូចខាតដែលមានជាយូរមកហើយ ភាពតានតឹង និងការខកចិត្តកាន់តែកើនឡើង ដោយសារកង្វះជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋ ឥរិយាបទរើសអើងនៅក្នុងសង្គមភាពក្រីក្រ និងកង្វះការអប់រំ ជាពិសេស ការអប់រំសិទ្ធិមនុស្ស។ ឧប្បដិហេតុ ឬពាក្យចចាមអារាមជាយូរមកហើយ ឬស្ថានភាពស្វាស៊ីបាយរួចលាបមាត់ពពៃ អាចមានលក្ខណៈគ្រប់គ្រាន់បញ្ឆេះភាពតានតឹងទាំងនេះ។ អសមត្ថភាព និងជួនកាលភាពគ្មានឆន្ទៈរបស់អាជ្ញាធរដើម្បីឆ្លើយតបនឹងអំពើ "ការកាត់ទោសដោយមហាជន" អាចបដិសេធសិទ្ធិមនុស្សទាំងអស់ រួមទាំងសិទ្ធិទទួលបានដំណោះស្រាយត្រឹមត្រូវដល់ជនរងគ្រោះពីអំពើបែបនេះ។ វាក៏អាចនាំទៅរកនិទណ្ឌភាព ប្រហែលជាអាចកើនឡើងនៃការប្រព្រឹត្តិអំពើ "ការកាត់ទោសដោយមហាជន" នៅថ្ងៃអនាគត។

របាយការណ៍នេះ ធ្វើសេចក្តីសន្និដ្ឋានដោយមានអនុសាសន៍នានាដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹង៖

- ច្បាប់ និងគោលនយោបាយ
- ការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះគ្រប់បទល្មើសព្រហ្មទណ្ឌទាំងអស់
- ពង្រឹងស្ថាប័នយុត្តិធម៌
- ចំណេះដឹងរបស់សាធារណៈជន តុលាការ និងមន្ត្រីនគរបាល។

# ២. សេចក្តីផ្តើម

អំពើហិង្សានៃអ្វីដែលហៅថា "ការកាត់ទោសដោយមហាជន" ដូចជាការសម្លាប់ ឬការវាយដំអ្នកដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើសណាមួយ នៅតែបន្តកើតមាននៅព្រះរាជាណាចក្រកម្ពុជា។ ជាធម្មតាជនល្មើស គឺជាជនសាមញ្ញដែលជាទូទៅត្រូវបានមើលឃើញថាជាអ្នកសងសឹក ជាជាងឧក្រិដ្ឋជន។ ពួកគេកម្រត្រូវបានស៊ើបអង្កេត ចាប់ខ្លួន និងផ្តន្ទាទោសណាស់។

ពាក្យ "ការកាត់ទោសដោយមហាជន" សំដៅដល់អំពើមួយដែលប្រជាជនយកច្បាប់មកអនុវត្តដោយខ្លួនឯង ជាទូទៅ ពាក់ព័ន្ធនឹងអំពើហិង្សា ជារឿយៗដោយការសងសឹកចំពោះជនល្មើស។ នៅកម្ពុជា វាអាចជាប្រតិកម្មភ្លាមៗពីហ្វូងមនុស្ស បន្ទាប់ពីហេតុការណ៍មួយភ្លាមៗ ឬក៏ជាឃាតកម្មគិតទុកជាមុន ប្រព្រឹត្តិដោយមនុស្សម្នាក់ ឬច្រើននាក់បណ្តាលមកពី ជួនកាល ការភ័យខ្លាច និងភាពជូរចត់ជាច្រើនឆ្នាំ។ ក្នុងគ្រប់ករណី ជនល្មើសមានអារម្មណ៍ថា អ្វីដែលពួកគេកំពុងធ្វើ/ប្រព្រឹត្ត គឺត្រឹមត្រូវ ហើយថា អ្នកដទៃនឹងឯកភាពតាមនូវសកម្មភាពរបស់ខ្លួន។

អំពើនៃអ្វីដែលហៅថា "ការកាត់ទោសដោយមហាជន" គឺជាអំពើព្រហ្មទណ្ឌតាមច្បាប់កម្ពុជា។ តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋមានកាតព្វកិច្ចការពារបុគ្គលពីឧក្រិដ្ឋកម្មទាំងនេះ ព្រមទាំងស៊ើបអង្កេត និងកាត់ទោសជនល្មើស ប្រសិនបើអំពើនេះកើតឡើង។ ប្រសិនបើរដ្ឋ មិនបានបំពេញតាមកាតព្វ កិច្ចនេះទេ វាអាចក្លាយជាការរំលោភបំពានសិទ្ធិមានជីវិត សិទ្ធិមិនត្រូវបានធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងគោលការណ៍សន្មត់ជាមុនថាគ្មានទោស ព្រមទាំងសិទ្ធិទទួលបានដំណោះស្រាយត្រឹមត្រូវ។ វាក៏អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីលប់បំបាត់រាល់ទម្រង់នៃការរើសអើង។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ទទួលស្គាល់កាតព្វកិច្ចទាំងនេះរបស់រដ្ឋ ស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ

ពលរដ្ឋ និងសិទ្ធិនយោបាយ។[២]

ចាប់ពីដើមទសវត្សឆ្នាំ២០០០មក យន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានចាប់ផ្តើមលើកឡើងពីកង្វល់អំពី"ការកាត់ទោសដោយមហាជន"ជាពិសេសការសម្លាប់ដោយហ្វូងមហាជន និងការខ្វះខាតពីការឆ្លើយតបពីអាជ្ញាធរកម្ពុជាដើម្បីដោះស្រាយបញ្ហានេះ នៅក្នុងរបាយការណ៍ និងសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់របស់ខ្លួន។

នៅក្នុងរបាយការណ៍ជាសាធារណៈ ផ្សព្វផ្សាយក្នុងឆ្នាំ២០០២[៣]អតីតតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្រ្តាចារ្យ ភីតធឺ ឡឺព្រេច បានទាញការចាប់អារម្មណ៍ពីចំនួនដ៏ខ្ពស់នៃករណីហិង្សាដោយហ្វូងមនុស្សនៅតាមផ្លូវ ដែលត្រូវបានកត់ត្រាទុកនៅកម្ពុជាចាប់ពីឆ្នាំ១៩៩៩ ដល់ពាក់កណ្តាលឆ្នាំ២០០២ និងបានលើកឡើងពីកង្វល់ អំពីការខ្វះខាតនៃការបង្ការ និងប្រតិកម្មដ៏មានប្រសិទ្ធភាពពីនគរបាល និងតុលាការ។ ក្នុងកំឡុងពេលនោះ មានករណីសម្លាប់ និងវាយដំដោយហ្វូងមនុស្សចំនួន ៦៥ករណី ក្នុងនោះ ៥០ករណី ប្រព្រឹត្តិនៅភ្នំពេញ។ អតីតតំណាងពិសេសបានកត់សម្គាល់ថា ទន្ទឹមនឹងនគរបាល បានបង្ហាញពីឆន្ទៈជួយអន្តរាគមន៍ក្នុងករណីខ្លះក្នុងករណី"ជាច្រើន" នគរបាលមិនបានជួយអន្តរាគមន៍ ដើម្បីការពារមនុស្សដែលត្រូវគេវាយដំនោះទេ ហើយថែមទាំងបានចូលរួមក្នុងការញុះញង់ឱ្យមានអំពើហិង្សាដោយហ្វូងមនុស្សផងដែរ។ អតីតតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបាន អំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាត់គ្រប់វិធានការចាំបាច់ដើម្បីទប់ស្កាត់អំពើបែបនេះ រួមទាំងឱ្យពិចារណាបង្កើតស្ថាប័នស៊ើបអង្កេតឯករាជ្យមួយ ដោយមានសមាសភាពមកពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសាសនានានា ដើម្បីពិនិត្យមើលគ្រប់អំពើហិង្សាដោយហ្វូងមនុស្ស ថាហេតុអ្វីបានជាកើតមានការវាយប្រហារបែបនេះ ថាតើត្រូវទប់ស្កាត់យ៉ាងដូចម្តេចនិងធ្វើការពិនិត្យឱ្យបានល្អិតល្អន់ពីចំណាត់ការនគរបាល និងការចោទប្រកាន់ចំពោះការវាយប្រហារទាំងនេះ។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៥[៤] តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានគូសបញ្ជាក់ជាថ្មីអំពីសំណើរបស់លោកឱ្យបង្កើតគណៈកម្មការស៊ើបអង្កេតមួយ។ រហូតមកដល់ពេលនេះ មិនទាន់មានការបង្កើតគណៈកម្មការបែបនេះមួយនៅឡើយទេ។តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក៏បានគូសបញ្ជាក់ផងដែរថា ការកែលំអស្តង់ដារប្រតិបត្តិច្បាប់គួរតែជាអាទិភាពខ្ពស់បំផុត។ តាំងពីពេលនោះមកការិយាល័យ OHCHR បានរៀបចំកម្មវិធីបណ្តុះបណ្តាលជាហូរហែរអំពីការបង្ការទារុណកម្ម ការប្រព្រឹត្តិមិនគប្បី ការការពារសិទ្ធិក្រោយការចាប់/ឃាត់ខ្លួន និងការប្រើប្រាស់កំលាំងដល់មន្ត្រីនគរបាល និងអាវុធហត្ថ ដោយមានកិច្ចសហការយ៉ាងពេញលេញពីរាជរដ្ឋាភិបាលកម្ពុជា។

យោងតាមទិន្នន័យ[៥]ដែលការិយាល័យOHCHR បានប្រមូលបាន និងប្រភពដទៃទៀត[៦] ចំនួនករណីនៃអំពើហិង្សាដោយហ្វូងមហាជនបានថយចុះ បន្ទាប់ពីរបាយការណ៍ឆ្នាំ២០០៥ របស់តំណាងពិសេស

---

[២] រាជរដ្ឋាភិបាលកម្ពុជា បានចូលជាសមាជិកនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។

[៣] ការចងកម្មពៀតាមដងផ្លូវ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០១២ ( cambodia.ohchr.org/sites/default/files/Thematic-reports/Thematic_CMB06062002E.pdf )

[៤] បែបផែននៃទណ្ឌភាពនៅតែបន្តមាននៅកម្ពុជា របាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែតុលា ឆ្នាំ២០០៥។

[៥] ស្ថិតិផ្លូវការអំពីអំពើហិង្សាដោយហ្វូងមហាជន មិនអាចរកមានទេ ដោយសារតែករណីទាំងនេះ ជារឿយៗ មិនត្រូវបានរាយការណ៍ ឬកត់ត្រាទុកដោយមន្ត្រីនគរបាលនោះទេ។

[៦] អង្គការលីកាដូ បានធ្វើបញ្ជីនៃករណីសម្លាប់ដោយហ្វូងមនុស្ស មានចំនួន ៥៥ករណី ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៥។

របស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។ មានហេតុផលជាក់ ស្តែងមួយចំនួន អាចយកមកពន្យល់ពីការធ្លាក់ចុះនេះ។ កម្ពុជា បានងើបចេញពីសង្គ្រាមស៊ីវិល និងអំពើហិង្សាជាច្រើនទសវត្ស បន្ទាប់ពីការចុះចូលចុងក្រោយរបស់ពួកខ្មែរក្រហមក្នុងឆ្នាំ១៩៩៨ ដែលបន្ទាប់មកទៀតមានការកាត់រំសាយកងកំលាំងប្រដាប់អាវុធ។ រាជរដ្ឋាភិបាលក៏បានផ្តួចផ្តើមគំនិតនូវកម្មវិធីបំផ្លាញអាវុធធុនតូច និងសព្វាវុធធុនស្រាលដែលកំពុងចរាចរ និងបានបង្កើនការឆ្លើយតបរបស់ខ្លួនចំពោះបទល្មើសជាទូទៅ។ កត្តាទាំងនេះ បានជួយកាត់បន្ថយយ៉ាងធំធេងដល់ការប្រព្រឹត្តបទល្មើស។អំឡុងពេលសន្តិភាពនេះ ក៏បានឆ្លើយតបដល់ការបើកចំហទីផ្សារសេដ្ឋកិច្ច និងការកើនឡើងយ៉ាងគំហុកដល់វឌ្ឍនភាពសេដ្ឋកិច្ច។

ក៏ប៉ុន្តែ ទោះបីជាមានការថយចុះអំពើនៃ"ការកាត់ទោសដោយមហាជន"ដែលនាំឱ្យមានការសម្លាប់ក្រៅច្បាប់ក៏ដោយក៏វានៅតែជាបញ្ហាកង្វល់ដដែល។ ពីមួយថ្ងៃទៅមួយថ្ងៃ ករណីនៃការសម្លាប់ ឬការវាយដំដោយហ្វូងមហាជនទៅលើអ្នកដែលត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តបទប្លន់ ត្រូវបានរាយការណ៍នៅក្នុងសារព័ត៌មាន ហើយវីដេអូនៃអំពើនេះ ត្រូវបានចែកចាយនៅក្នុងបណ្តាញផ្សព្វផ្សាយសង្គម។[៧] ក្នុងករណីជាច្រើន អាជ្ញាធរតុលាការ នៅតែខកខានចាត់វិធានការដើម្បីនាំខ្លួនជនល្មើសនៃអំពើបែបនេះមកផ្តន្ទាទោសតាមច្បាប់។ ករណីបែបនេះ ចិញ្ចឹមបែបផែននៃនិទណ្ឌភាព ដោយសារតែវាបង្ហាញដល់ជនល្មើសថា អំពើរបស់ពួកគេនឹងមិនត្រូវទទួលបានការផ្តន្ទាទោសនោះទេ ហើយហេតុដូច្នេះ លើកទឹកឱ្យពួកគេជឿជាក់ថា អំពើបែបនេះអាចទទួលយកបាន និងអាចធ្វើបានតទៅទៀត។ ហេតុដូច្នេះ កិច្ចខិតខំប្រឹងប្រែងនៅតែតម្រូវជាដរាបដើម្បីលើកកំពស់នីតិរដ្ឋ ការពារដល់ជនរងគ្រោះពីអំពើហិង្សាដោយហ្វូងមហាជន និងចាប់ឱ្យជនល្មើសទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

ក្នុងឆ្នាំ២០១៦ ការិយាល័យ OHCHR បានចាប់ផ្តើមការងារឡើងវិញអំពី "ការកាត់ទោសដោយមហាជន" ដែលបានធ្វើកាលពីដើមទសវត្សឆ្នាំ២០០០ និងបានចាប់ផ្តើមចងក្រងជាឯកសារករណីនៃការសម្លាប់ដោយហ្វូងមនុស្ស ដើម្បីស្វែងយល់ពីបរិបទដែលករណីទាំងនេះកើតឡើង និងផ្តល់អនុសាសន៍ អំពីរបៀបដោះស្រាយស្ថានភាពទាំងនេះ។

នៅពេលដែលប្រមូលទិន្នន័យអំពីអំពើហិង្សានៅតាមដងផ្លូវដែលជាទម្រង់មួយនៃ"ការកាត់ទោសដោយមហាជន" ទម្រង់ករណីថ្មីមួយទៀតបានលេចឡើងនោះ គឺការវាយដំលើអ្នកដែលបង្កគ្រោះថ្នាក់ចរាចរណ៍ ហើយបន្ទាប់មកព្យាយាមបើករត់ពីកន្លែងកើតហេតុ ដោយសារតែភ័យខ្លាចពីការសងសឹកពីហ្វូងមហាជនដែលនៅជុំវិញកន្លែងកើតហេតុ។ ជាពិសេស ហ្វូងមនុស្សឃាត់ឡានឱ្យឈប់ វាយដំលើអ្នកបើកបរ ហើយថែមទាំងវាយកំទេចរថយន្តនោះទៀត។ ករណីទាំងនេះជាទូទៅ ត្រូវបានទុកចោល ដោយមិនយកអ្នកបង្កហិង្សាវាយដំគេមកផ្តន្ទាទោសនោះទេ។

ទោះជាយ៉ាងណាក៏ដោយកាលពីខែមីនាឆ្នាំ២០១៨[៨] បន្ទាប់ពីការវាយដំយ៉ាងធ្ងន់ធ្ងរទៅលើសាស្ត្រាចារ្យម្នាក់ដែលត្រូវបានចោទថាពាក់ព័ន្ធនៅក្នុងការបង្កគ្រោះថ្នាក់ចរាចរណ៍រួចហើយបើករត់ នាយករដ្ឋមន្ត្រីបានអំពាវនាវឱ្យបញ្ចប់យុត្តិធម៌ដោយហ្វូងមនុស្ស និងសុំឱ្យមានការស៊ើបអង្កេត ហើយត្រូវចាប់ខ្លួនជនល្មើសមកផ្តន្ទាទោស។ មន្ត្រីនគរបាល បានចាប់ខ្លួនជនសង្ស័យដែដល់ចំនួន៣នាក់ ដែលបន្ទាប់មកត្រូវផ្តន្ទាទោស

៧ ការផ្ទុកទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ គឺជាវិស័យថ្មីមួយដែលរូបភាពនៃអំពើហិង្សាត្រូវចែកចាយ និងផ្តល់យោបល់។ យោបល់ខ្លះដែលត្រូវសរសេរនៅក្នុងបណ្តាញផ្សព្វផ្សាយសង្គម ផ្តល់នូវយោបល់ និងការឆ្លើយតបតាមបែបបង្កហេតុ។

៨ សូមមើល: https://phnompenhpost.com/national/rare-call-end-mob-justice-after-brutal-beating-cpp-aligned-professor, http://en.freshnewsasia.com/index.php/en/8116-2018-03-21-08-43-22.html and https://www.khmertimeskh.com/50298772/sar-kheng-condemns-unjust-mob-violence.

ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ និងបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃដោយចេតនា។ ពួកគេ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៣ឆ្នាំ ហើយត្រូវបន្ថយទោសមកត្រឹម១៨ខែ និងត្រូវបង្គាប់ឱ្យសងសំណងការខូចខាតដល់ជនរងគ្រោះ។ សំណងនេះ មិនទាន់បានបង់នៅឡើយទេ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវឱ្យប្រជាពលរដ្ឋកុំប្រើហិង្សា និងបញ្ជាដល់មន្ត្រីនគរបាលទាំងអស់ឱ្យរាយការណ៍ ស៊ើបអង្កេត និងនាំខ្លួនជនល្មើសនៃអំពើបែបនេះមកផ្តន្ទាទោស។ កាលពីខែកញ្ញា ឆ្នាំ២០១៨ មានអ្នកភូមិមួយក្រុមនៅខេត្តស្វាយរៀង បានវាយដំទៅលើអ្នកបើកបរតាក់ស៊ីដែលបង្កគ្រោះថ្នាក់ចរាចរណ៍ធ្វើឱ្យបុរសអ្នកបើកម៉ូតូម្នាក់ស្លាប់។ មន្ត្រីនគរបាល បានបើកការស៊ើបអង្កេត និងបានចាប់ខ្លួនមនុស្សចំនួន ៤នាក់។ សកម្មភាពទាំងនេះ គួរត្រូវបានលើកទឹកចិត្ត និងគួរបើកផ្លូវដល់ការលើកកំពស់ការយល់ដឹងថែមទៀតអំពីនីតិរដ្ឋ និងធ្វើឱ្យប្រជាជនយល់ថា "ការកាត់ទោសដោយមហាជន" មិនអាចជំនួសឱ្យប្រព័ន្ធយុត្តិធម៌ផ្លូវការនោះទេ។

"ការកាត់ទោសដោយមហាជន"មិនកម្រិតត្រឹមតែករណីនៃការសងសឹកតាមដងផ្លូវដោយកំហឹងរបស់មហាជន ក្នុងការឆ្លើយតបនឹងការប្រព្រឹត្តិអំពើល្មើសមួយនោះទេ។ ទម្រង់មួយទៀតនៃការផ្តន្ទាទោសដោយមហាជនដែលបានទទួលការចាប់អារម្មណ៍តិចតួចនៅឡើយ គឺការសម្លាប់ ការវាយដំ ការបណ្តេញចេញ និង/ឬការធ្វើទុក្ខបុកម្នេញដល់អ្នកដែលត្រូវបានចោទថាចេះអំពើអាបធ្មប់។ ប្រភេទនៃ"ការកាត់ទោសដោយមហាជន" នេះ ប្រព្រឹត្តិដោយបុគ្គលនានា ឬក្រុមអ្នកភូមិ ដែលត្រូវបានលឺជាទូទៅក្នុងអំឡុងទសវត្សរ៍ទី៨០ និង៩០នោះ នៅតែកើតមាននៅតាមតំបន់ជនបទនានាក្នុងពេលសព្វថ្ងៃនេះ។

ការចោទប្រកាន់ និងការធ្វើទុក្ខបុកម្នេញដល់អំពើអាបធ្មប់ គឺជាបញ្ហាសិទ្ធិមនុស្សដែលកំពុងតែត្រដែតឡើងមិនត្រឹមតែនៅកម្ពុជានោះទេ។[៩] ករណីជាច្រើនត្រូវបានរាយការណ៍នៅក្នុងបណ្តាប្រទេសអាហ្វ្រិកដោយផ្តោតជាក់លាក់ទៅលើមនុស្សភ្មើក ដែលត្រូវបានកំណត់ជាគោលដៅពិសេសដោយ សារពួកគេត្រូវបានសម្លាប់ ឬរងគ្រោះធ្ងន់ធ្ងរ ដើម្បីប្រើប្រាស់ផ្នែកណាមួយនៃរាងកាយរបស់ពួកគេ បំផ្លែងទៅជាថ្នាំព្យាបាល ឬវត្ថុសក្តិសិទ្ធិដើម្បីការពារខ្លួន[១០] ដោយគេជឿថា "នាំលាភ និងផ្តល់សំណាង"[១១]។ នៅអាស៊ីអាគ្នេយ៍

---

[៩] កាលពីខែកញ្ញា ឆ្នាំ២០១៧ សិក្ខាសាលាអន្តរជាតិមួយរៀបចំដោយអង្គការសហប្រជាជាតិស្តីពីអំពើអាបធ្មប់ និងសិទ្ធិមនុស្ស បានបើកឱកាសឱ្យមានការពិភាក្សា អំពីអំពើហិង្សាទាក់ទងនឹងការចោទប្រកាន់ពីអំពើអាបធ្មប់។ មន្ត្រីអង្គការសហប្រជាជាតិ អ្នកជំនាញ និងអ្នកសិក្សាស្រាវជ្រាវបានចែករំលែកព័ត៌មានពីករណីនានានៅជុំវិញពិភពលោករបស់អ្នកដែលត្រូវបានគេរើសអើង អ្នកត្រូវរងគ្រោះ អ្នកត្រូវគេសម្លាប់ ដោយសារតែការចោទប្រកាន់ពីការធ្វើអំពើអាបធ្មប់។ អ្នកជំនាញ នៅសិក្ខាសាលាបានផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ "អំពើអាបធ្មប់" ថាជានិយមន័យមេនៅថ្នាក់អន្តរជាតិ ដែលគ្របដណ្តប់លើពហុភាពនៃការបង្ហាញពីអំពើអាបធ្មប់ដោយផ្តោតទៅលើការអនុវត្តន៍ដ៏គ្រោះថ្នាក់ និងកាតព្វកិច្ចរបស់រដ្ឋភាគី ដូចដែលបានកំណត់ន័យដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។ ហេតុដូច្នេះ អំពើអាបធ្មប់ ត្រូវបានកំណត់ថាជា "តថភាពដែលបានចាក់ឬសយ៉ាងជ្រៅនៅក្នុងសង្គម ដែលបំរើជាប្រព័ន្ធនៃការពន្យល់ និងការធ្វើអាជីវកម្មពីគ្រោះកាចអកុសល។ វាត្រូវបានបញ្ចេះដោយជំនឿមិនត្រឹមត្រូវតាមអំណាចអធិធម្មជាតិ និងទស្សនៈមិនត្រឹមត្រូវអំពីបញ្ហាសុខភាពសាធារណៈ។ សូមមើល៖ http://www.ohchr.org/EN/Issues/Albinism/Pages/Witchcraft.aspx.

[១០] ឆ្អឹង ស្បែក និងសក់របស់មនុស្សភ្មើក ត្រូវបានជឿជាក់ថានាំមកនូវលាភ និងសំណាង។ នៅក្នុងរបាយការណ៍ឆ្នាំ២០១៦ របស់លោកស្រីជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដែលផ្តោតលើទិដ្ឋភាពនៃអំពើអាបធ្មប់ទាក់ទងនឹងការសម្លាប់មនុស្សភ្មើកតាមបែបសាសនា ដើម្បីយករាងកាយមកប្រើប្រាស់ អ្នកជំនាញការឯករាជ្យស្តីពីការការទទួលបានសិទ្ធិមនុស្សរបស់មនុស្សភ្មើក បានកត់សម្គាល់ថា ការវាយប្រហារលើមនុស្សភ្មើក ត្រូវបានរាយការណ៍ថាកើតមានរហូតមកដល់ពេលនេះ មានទាំងអស់ ២៦ប្រទេស ស្ថិតនៅក្នុងអនុតំបន់សាហារា ទ្វីបអាហ្វ្រិក។ របាយការណ៍របស់អ្នកជំនាញការឯករាជ្យស្តីពីការការទទួលបានសិទ្ធិមនុស្សរបស់មនុស្សភ្មើក A/71/255, para 37។

សូមមើលផងដែរ Gettleman, Jeffrey. មនុស្សភ្មើក,ប្រឈមការគំរាមកំហែងមិនអាចចៀសបានក្នុងរយៈពេលយូរអង្វែងនៅប្រទេសតង់ហ្សានី, កាសែត N.Y. Times (June 8, 2008), អាចរកបាននៅ៖ http://www.nytimes.com/2008/06/08/world/africa/08albino.html; សូមមើលផងដែរ Obulutsa, George. មនុស្សភ្មើករស់ក្នុងភាពភ័យខ្លាចបន្ទាប់ពីគេពន្លះយកផ្នែកណាមួយនៃសរីរាង្គ កាសែត The Guardian (Nov. 4, 2008), អាចរកបាននៅ៖ http://www.guardian.co. uk/world/2008/nov/04/tanzania-albinos-murder-witchcraft; និងសូមមើលផងដែរ ការសំលាប់មនុស្សភ្មើកតាមបែបសាសនានៅប្រទេសម៉ាឡាវី (Feb. 2, 2017) អាចរកបាននៅ៖ https://www.amnesty.org.uk/ritual-murders-people-albinism-malawi.

[១១] របាយការណ៍ស្តីពីអំពើអាបធ្មប់ និងសិទ្ធិមនុស្សរបស់មនុស្សភ្មើក ដោយអ្នកជំនាញការឯករាជ្យស្តីពីការការទទួលបានសិទ្ធិមនុស្សរបស់មនុស្សភ្មើក A/HRC/34/59, 10 January 2017, para. 27.

និងតំបន់ប៉ាស៊ីហ្វិក អំពើហិង្សា ត្រូវបានដៅចំពោះអ្នកដែលចេះអំពើអាបធ្មប់។ ករណីជាច្រើនត្រូវបានចងក្រងជាឯកសារនៅប្រទេសប៉ាពួញូហ្គីណេ[១២] ឥណ្ឌូណេស៊ី[១៣] និងថៃ[១៤] ហើយត្រូវបានចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

ក្នុងឆ្នាំ២០១៨ការសម្លាប់ការវាយដំនិងការឃាយីដែលទាក់ទងនឹងអំពើអាបធ្មប់ និងករណីនីទណ្ឌភាពកើតចេញពីអំពើទាំងនេះ នៅតែជាបញ្ហាកង្វល់នៅផ្នែកខ្លះនៃកម្ពុជា។ អំពើទាំងនេះ បានទាញការចាប់អារម្មណ៍ជាសាធារណៈតិចតួចនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជា និងអ្នកការពារសិទ្ធិមនុស្ស បានលើកឡើងដោយកម្រនូវករណីទាំងនេះ។ សូម្បីតែអ្នកស្រាវជ្រាវក៏មិនបានធ្វើអ្វីច្រើនលើប្រធានបទនេះដែរ។[១៥] របាយការណ៍នេះ គឺជាការប៉ុនប៉ងលើកទីមួយ វិភាគពីយន្តការដែលនាំឱ្យមានអំពើហិង្សា ប្រឆាំងនឹងអ្នកចេះអំពើអាបធ្មប់នៅកម្ពុជា។

របាយការណ៍នេះរៀបចំឡើងដោយផ្អែកលើការងារ និងរបាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកភីតធើរ ឡឺព្រេច និងមានគោលបំណងប្រយុទ្ធប្រឆាំងនឹងការរើសអើង និងនីទណ្ឌភាព និងពង្រឹងគណនេយ្យភាព និងនីតិរដ្ឋ។ របាយការណ៍នេះចងក្រងស្ថានភាពនានាជាច្រើនចាប់ពីអំពើហិង្សាតាមដងផ្លូវ រហូតឃាតកម្មគិតទុកជាមុន និងពីមធ្យោបាយដែលអាជ្ញាធរដោះស្រាយករណីទាំងនេះ។ របាយការណ៍ ពិនិត្យពីបាតុភូតនៃការសម្លាប់ ការវាយដំការបណ្តេញចេញ និងការធ្វើទុក្ខបុកម្នេញដោយហ្វូងមហាជន ទៅលើបុគ្គលដែលសង្ស័យថាចេះអំពើអាបធ្មប់ ព្រមទាំងប្រតិកម្មពីអាជ្ញាធរ។ របាយការណ៍នេះក៏កំណត់ពីកត្តាខ្លះៗ និងបុព្វហេតុជារចនាសម្ព័ន្ធដែលនាំឱ្យមានអំពើបែបនេះ និងប្រវត្តិរបស់ជនរងគ្រោះខ្លះ។ របាយការណ៍ នេះគូសបញ្ជាក់ពីកង្វល់ផ្នែកសិទ្ធិមនុស្សពាក់ព័ន្ធនឹងបាតុភូតនៃ “ការកាត់ទោសដោយមហាជន”

[១២] សូមមើល Squires, Nick. អំពើអាបធ្មប់នាំការកាប់សម្លាប់មកកាន់តំបន់ឋានសួគ៌ប៉ាស៊ីហ្វិច៖ ជំងឺអេដស៍បានធ្វើឱ្យរស់ឡើងវិញនៃមន្តអាគមនអាក្រក់នៅប្រទេសប៉ាពួញូហ្គីណេ កាសែត the Daily Telegraph 21 (Feb. 9, 2007), សូមមើល Amnesty International. Papua New Guinea: អំពើហិង្សាលើស្ត្រី៖ មិនអាចចៀសវាងបាន មិនអាចទទួលយកបានទាល់តែសោះ, ASA 34/002/2006 (Sept. 4, 2006), អាចរកបាននៅ៖ http://www.amnesty.org/en/ library/info/ASA34/002/2006, សូមមើលរបាយការណ៍ស្តីពីរបាយការណ៍របស់អ្នកជំនាញការឯករាជ្យស្តីពីការទទួលបានសិទ្ធិមនុស្សរបស់មនុស្សភៀកក្រុមប្រឹក្សាសិទ្ធិមនុស្ស, សម័យប្រជុំលើកទី៤៤, ខែមករា ឆ្នាំ២០១៧, A/HRC/34/59. សូមមើល Amnesty International. Papua New Guinea, ករណីឧទ្ធរណ៍របស់ Anna Benny អ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី, ASA, 34/005/2006 (Sept. 4, 2006), អាចរកបាននៅ៖ http://www.amnesty.org/en/library/ asset ASA34/005/2006/en/dom-ASA340052006en.pdf.

[១៣] សូមមើល Ellen, Roy. កំហឹង ភាពអន្ទះសារ និងអំពើអាបធ្មប់៖ បទវិភាគមួយនៃរឿងក្តីជាក់ស្តែងពីតំបន់ Seram, ភាគខាងកើតឥណ្ឌូណេស៊ី, ក្នុងការស្វែងយល់ពីអំពើអាបធ្មប់នៅអាស៊ីអាគ្នេយ៍ (Watson, C.W. and R.F. Ellen ed.), University of Hawaii Press (1993), at 11 និងសូមមើល Herriman, Nicholas, ភាពភ័យខ្លាច និងភាពមិនច្បាស់លាស់៖ ទស្សនៈរបស់អ្នកស្រុកចំពោះអំពើអាបធ្មប់ និងរដ្ឋក្នុងការតាមប្រមាញ់អាបធ្មប់ឥណ្ឌូណេស៊ី, 34 Asian Journal of Social Science 360 (2006), អាចរកបាននៅ៖ http://arts.monash.edu.au/mai/staff/fearuncertainty.pdf (ចូលឆែកមើលចុងក្រោយកាលពីថ្ងៃ៣១ ធ្នូ ឆ្នាំ២០០៨) អត្ថបទសម្រង់។

[១៤] Golomb, Louis. Supernaturalist Curers and Sorcery Accusations in Thailand, 27 Soc Sci Med 437.

[១៥] ឯកសារបោះពុម្ពផ្តោតលើការអនុវត្តន៍របស់គ្រូថ្នាំបូរាណ(អ្វីដែលហៅថា វេទមន្តស្តោះផ្លុំប្រើដើម្បីព្យាបាលជំងឺ) និងរបាយការណ៍សង្ខេបតែប៉ុណ្ណោះស្តីពីការចោទប្រកាន់ពីអ្វីដែលហៅថាការប្រើមន្តអាគមផ្លូវងងឹត។ នរវិទូសង្គមចង្អុលបង្ហាញថា ការអនុវត្តន៍នេះមានលក្ខណៈពិបាកធ្វើការសិក្សាស្រាវជ្រាវ ដោយសារតែវាត្រូវបានទុកជាអាថ៌កំបាំង ហើយថា “រឿងរ៉ាវទាំងអស់នឹងលេចចេញមក នៅពេលដែលគ្រូអាបធ្មប់ត្រូវបានសម្លាប់” “ជួបគ្រូអាបធ្មប់នៅរស់ គឺមិនអាចទៅរួចទេជាក់ស្តែង” in Ovesen, Jan; Trankell, Ing-Britt, (2010), ប្រជាជនកម្ពុជា និងវេជ្ជបណ្ឌិតរបស់ពួកគេ៖ មនុស្សសាស្ត្របែបវេជ្ជសាស្ត្ររបស់កម្ពុជាសម័យអាណានិគម និងក្រោយសម័យអាណានិគម, NIAS Monographs, No. 117. សំរាប់រូបភាពទូទៅអំពីគ្រូថ្នាំបូរាណ, សូមមើលផងដែរ៖ LECLERE, Adhémard, (1895), “គ្រូអាបធ្មប់នៅតាមភូមិកម្ពុជា”, នៅក្នុងព្រឹត្តិប័ត្រវិទ្យាសាស្ត្រ, série 4, III, pp.129-136, ANG Choulean, (1986), Les êtres surnaturels dans la religion populaire khmère, Paris, Cedorek, EISENBRUGH, Maurice, (1992), “លំហតាមបែបសាសនារបស់អ្នកជំងឺ និងគ្រូថ្នាំបូរាណនៅកម្ពុជា”។ ក្នុងព្រឹត្តិប័ត្ររបស់សាលាបារាំងចុងបូព៌ា ភាគ 79 N°2, pp. 283-316, BERTRAND Didier, (2000), “គ្រូអាគម៖ ភាពជាក់លាក់នៃការអនុវត្តន៍ភោគៈនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ”, in Aigle D et alii, La politique des esprits: chamanisme et religions universalistes. Presses Universitaires de Nanterre, p 125-150.

នៅកម្ពុជា និងការទទួលខុសត្រូវរបស់រដ្ឋ ឆ្លើយតបទៅនឹងអំពើទាំងនេះ និងបង្ការកុំឱ្យកើតឡើង។ របាយការណ៍នេះ ក៏បានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ឱ្យជួយទប់ស្កាត់អំពើហិង្សាថែមទៀត និងបញ្ចប់និទណ្ឌភាព។

## ៣. វិធីសាស្ត្រ

របាយការណ៍នេះរៀបរៀងឡើងដោយផ្អែកលើការធ្វើបេសកកម្មចុះដល់ទីកន្លែងនៅកម្ពុជា ចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែធ្នូ ឆ្នាំ២០១៨។ ទិន្នន័យបឋមបានមកពីប្រព័ន្ធផ្សព្វផ្សាយនានារួមទាំងសារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងបណ្តាញផ្សព្វផ្សាយសង្គម រវាងឆ្នាំ២០១០ និងឆ្នាំ២០១៨ ពីកិច្ចប្រជុំនានាជាមួយមន្ត្រីនគរបាលមូលដ្ឋាន និងមន្ត្រីតុលាការ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សដែលមានស្នាក់ការនៅតាមខេត្តនានា។

ផ្អែកលើព័ត៌មានដែលប្រមូលបាន ការិយាល័យ OHCHR បានធ្វើបញ្ជីនៃករណីពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៨ សរុបទាំងអស់មាន ៧៣ករណី។ ក្នុងចំណោម៥៧ករណី មាន២២ករណី ត្រូវបានសម្លាប់ បន្ទាប់ពីមានការចោទប្រកាន់ពីការប្រព្រឹត្តិមិនល្អនៅក្នុងសង្គម លួច ឬបទល្មើសដទៃទៀត រួមទាំងគ្រោះថ្នាក់ចរាចរណ៍ផង និងមាន៣៥ករណីត្រូវបានសម្លាប់ បន្ទាប់ពីមានការចោទប្រកាន់ពីអំពើអាបធ្មប់។ ចំពោះ ១៦ករណីទៀតដែលនៅសល់ ត្រូវបានរងរបួស ឬត្រូវបានយាយី។ក្រសួងមហាផ្ទៃបានរាយការណ៍១៦ករណី ពីអំពើហិង្សាដោយមហាជន និងឃាតកម្មចំនួន៨ករណី ដែលកើតឡើងពីការ ចោទប្រកាន់ចេះអំពើអាបធ្មប់រវាងចន្លោះខែមករា ឆ្នាំ២០១៧ ដល់ខែមិថុនា ឆ្នាំ២០១៩។ តួរលេខជាក់ស្តែង ទំនងជាច្រើនជាងនេះ ដោយសារតែគ្មានទិន្នន័យរួមផ្លូវការអំពី "ការកាត់ទោសដោយមហាជន"។

ការិយាល័យ OHCHR បានធ្វើទស្សនកិច្ចចំនួន ៣៩ដង ចុះដល់ទីកន្លែងកើតហេតុនៃ "ការកាត់ទោសដោយមហាជន"។ មានកិច្ចសម្ភាសន៍យកព័ត៌មានជាង១៩០លើក ជាមួយជនរងគ្រោះ គ្រួសារជនរងគ្រោះ អ្នកជិតខាង សាក្សី និងជនល្មើសដែលត្រូវចោទប្រកាន់។[១៦] ការិយាល័យ OHCHR ក៏បានពិភាក្សាករណីទាំងនេះ និងបានលើកកំពស់ការយល់ដឹងអំពីការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងការការពារដល់ជនរងគ្រោះ ជាមួយអាជ្ញាធរមូលដ្ឋាន រួមទាំងមេភូមិ និងមេឃុំ ព្រមទាំងជាមួយមន្ត្រីយុត្តិធម៌ (ដូចជា នគរបាលប៉ុស្តិ៍ នគរបាលស្រុក និងនគរបាលខេត្ត ព្រមទាំងព្រះរាជអាជ្ញា និងចៅក្រមនៅសាលាដំបូងខេត្តទាំងនោះ) ផងដែរ។ សេចក្តីសង្ខេបនៃករណីជាក់លាក់ និងសម្រង់ផ្ទាល់ ត្រូវយកមកប្រើដោយមានការយល់ព្រមជាក់លាក់ពីអ្នកទាំងឡាយដលែបានផ្តល់សម្ភាសន៍ ឬដកចេញពីប្រភពចំហ។

ដោយសារតែប្រភេទផ្សេងៗនៃជនរងគ្រោះពាក់ព័ន្ធ និងមធ្យោបាយនានាដែលប្រជាជនមូលដ្ឋាន និងមន្ត្រីយុត្តិធម៌ យល់ និងចាត់ចែងករណី "ការកាត់ទោសដោយមហាជន" លទ្ធផលពីទស្សនកិច្ចដល់ទីកន្លែងត្រូវបានបង្ហាញជូនជាពីរផ្នែកផ្សេងគ្នា៖ ទី១ គឺការសម្លាប់ និងការវាយដំដោយហ្វូងមនុស្សនៃអ្នកដែលត្រូវបានចោទប្រកាន់ពីការខុសសីលធម៌សង្គម ឬបទល្មើសផ្សេងៗ រួមមានចោរ និងការបុក្ខរួចរត់ និងទី២ គឺការសម្លាប់ការវាយដំការបណ្តេញចេញ និងការយាយីដល់អ្នកដែលត្រូវបានចោទពីការធ្វើអំពើអាបធ្មប់។

[១៦] អ្នកផ្តល់សម្ភាសន៍បានផ្តល់ព័ត៌មានអំពីរបៀប និងមូលហេតុនៃអំពើ "ការកាត់ទោសដោយមហាជន" បានកើតឡើង និងពីរបៀបដែលពួកគេយល់ និងធ្លាប់ឆ្លងកាត់។

# ៤.អំពើនៃ “ការកាត់ទោសដោយមហាជន” នៅកម្ពុជា

## ៤.១. ការបង្ហាញពីអំពើនៃ “ការកាត់ទោសដោយមហាជន” ភ្លាមៗ ចំពោះជនដែលត្រូវបានចោទពីបទលួច ប្លន់ បទល្មើសព្រហ្មទណ្ឌ ឬពីការបង្កគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវ

### ៤.១.១. ករណីនៃអំពើហិង្សាដោយមហាជន

ការិយាល័យ OHCHR បានចងក្រងបញ្ជី និងចងក្រងទុកជាឯកសារ នូវការសម្លាប់ដោយមហាជនចំនួន ២២ករណីដែលបានកើតឡើងនៅចន្លោះឆ្នាំ២០១០និងឆ្នាំ២០១៨ នៅតំបន់ទីក្រុង និងជនបទ។ នៅក្នុងករណីចំនួន ១៤ ករណី ជនរងគ្រោះពីការសម្លាប់ដោយមហាជន គឺត្រូវបានគេអះអាងថាជាចោរ ត្រូវចាប់ខ្លួនបាននៅទីកន្លែងកើតហេតុ ជនរងគ្រោះចំនួន ២ នាក់ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ជនរងគ្រោះម្នាក់ត្រូវចាប់ខ្លួនបាន បន្ទាប់ពីត្រូវបានគេអះអាងថាបានប្រព្រឹត្តអំពើឃាតកម្ម ជនរងគ្រោះចំនួន ៣ នាក់ ត្រូវចាប់ខ្លួនបាន នៅពេលមានជម្លោះនៅតាមដងផ្លូវ ជនរងគ្រោះម្នាក់ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានបង្កគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្ត ហើយនិងជនរងគ្រោះម្នាក់ត្រូវបានចាប់ខ្លួនបន្ទាប់ពីមានការអះអាងថា បានចាប់ជម្រិតក្មេងតាមហ្វេសប៊ុក។ កាន់តែមានជនរងគ្រោះច្រើនឡើង បានទទួលរងនូវការវាយដំទាត់ធាក់។ ជនរងគ្រោះពីការសម្លាប់ និងការវាយដំទាត់ធាក់ដោយមហាជន គឺជាមនុស្សប្រុសទាំងអស់។ ការទាត់ធាក់ក្បាល និងខ្នងផ្នែកខាងក្រោមដងខ្លួន ការដាល់ក្បាលពោះ និងការវាយដំទាត់ធាក់នឹងដំបងឈើ ឬដុំថ្ម គឺជាមធ្យោបាយធម្មតាបំផុតទៅហើយ ដើម្បីដាក់ទណ្ឌកម្មដល់ជនរងគ្រោះដែលត្រូវចាប់ខ្លួនបាននៅទីកន្លែងកើតហេតុ។

ផ្អែកតាមដំណើររឿងនៃការសម្លាប់ចោរដោយមហាជនជាច្រើនករណី ដែលត្រូវបានឃ្លាំមើល និងស៊ើបអង្កេត សេណារិយ៉ូមួយលេចចេញជារូបរាងឡើង៖ ការសម្លាប់ដោយមហាជន គឺជាប្រតិកម្ម ភ្លាមៗពីមហាជន ឬហ្វូងមនុស្ស បន្ទាប់ពីមានការចោទប្រកាន់ថាមានអំពើល្មើសព្រហ្មទណ្ឌ ដោយជនរងគ្រោះ ស្ទើរតែគ្មានឱកាសទាល់តែសោះ ដើម្បីអះអាងអំពីភាពគ្មានទោសពៃរ៍របស់ពួកគេ។ មនុស្សដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តចោរកម្ម គឺក្លាយជាជនរងគ្រោះជាធម្មតាបំផុតទៅហើយ។ គ្រាន់តែជាការចោទប្រកាន់សាមញ្ញប៉ុណ្ណោះ គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ឆេះហ្វូងមហាជន ឲ្យប្រព្រឹត្តអំពើហិង្សាយ៉ាងប្រល័យ។ ប្រជាពលរដ្ឋដែលចូលរួមក្នុងការវាយដំទាត់ធាក់ គឺជាប្រជាពលរដ្ឋសាមញ្ញ ដែលតាមធម្មតាជាអ្នកឈរមើល ហើយភាគច្រើនជាយុវជនវ័យក្មេង ដែលឃើញឧប្បត្តិហេតុនឹងភ្នែក លឺសម្លេងស្រែកថា “ចោរ”។ មនុស្សផ្សេងទៀតទទួលការហៅទូរស័ព្ទ ឬសារតាមទូរស័ព្ទ ដោយជូនដំណឹងដល់ពួកគេអំពីឧប្បត្តិហេតុនេះ។ជនដែលត្រូវបានគេអះអាងថាជាចោរក្នុងករណីនៃអំពើប្លន់ ត្រូវគេចាប់ខ្លួនបានភ្លាមៗបន្ទាប់ពីមានអំពើប្លន់ ឬជាញឹកញាប់បន្ទាប់ពីមានការដេញតាមប្រម៉ាញ់រយៈពេលខ្លី។ ប្រសិនបើចោរមិនទាន់ត្រូវចាប់ខ្លួនបានភ្លាមៗ ហើយនិងប្រសិនបើចោររត់គេចខ្លួន ប្រជាពលរដ្ឋដែលមានវត្តមាននៅទីកន្លែងកើតហេតុ រត់ដេញតាមពីក្រោយដោយស្រែកថា “ចោរចោ” សុំឲ្យអ្នកឈរមើលជួយរាំងខ្ទប់កុំឲ្យចោររត់គេចខ្លួនរួច។ សាមគ្គីភាពគ្នាក្នុងការដេញតាមប្រម៉ាញ់ចោរគឺធ្វើឡើងភ្លាមៗ និងមានកំរិតខ្ពស់។ តាមធម្មតានៅពេលចាប់ខ្លួនបាន ប្រជាពលរដ្ឋជាច្រើននាក់ (ប្រជា

ពលរដ្ឋខ្លះមិនទាំងបានឃើញឧប្បត្តិហេតុនោះផងទេ) វាយដំទាត់ធាក់ជនសង្ស័យជាច្រើនដង តាមរបៀបមួយដែលមានអ្នកប្រព្រឹត្តច្រើននាក់ អាចជាអ្នកទទួលខុសត្រូវរួមគ្នាចំពោះការសម្លាប់នេះ។ ក្នុងករណីនៃការកាត់ទោសដោយមហាជននៅតាមដងផ្លូវ អ្នកប្រព្រឹត្តអំពើទាំងនេះក្នុងចំនួនដ៏ច្រើនលើសលុប មិនធ្លាប់ស្គាល់គ្នានោះទេ។ និគមន៍ជាតិសាសន៍ក៏អាចជាកត្តាមួយភ្ជាប់ទៅនឹងករណីបែបនេះដែរ។ មនោសញ្ចេតនាប្រឆាំងវៀតណាម មានអាត្រាប្រេវ៉ាឡង់ខ្ពស់នៅកម្ពុជាអស់ជាច្រើនទសវត្សរ៍មកហើយ បានស្វែងរកវិធីបញ្ចេញនូវមនោសញ្ចេតនាបែបនេះតាមពាក្យពេជន៍ហិង្សាក្នុងរយៈកាលថ្មីៗចុងក្រោយនេះ រួមទាំងករណីចំនួនពីរនៃការកាត់ទោសដោយមហាជនដែលការិយាល័យ OHCHR[១៧] បានចងក្រងទុក។ មានការបារម្ភថាការរើសអើងដោយសារពូជសាសន៍និង/ឬសញ្ជាតិអាចនាំឱ្យមានអំពើហិង្សាដោយមហាជននាពេលអនាគត។ ការតាមឃ្លាំមើលអំពើណាមួយដែលញុះញង់នាំឱ្យមានអំពើហិង្សាប្រឆាំងនឹងក្រុមទាំងនេះ គឺជាប្រការសំខាន់។

ប្រជាពលរដ្ឋកាន់តែច្រើនចោមរោមហ្វូងមហាជន បើទុកជាពួកគេមិនបានចូលរួមក្នុងការវាយដំទាត់ធាក់ក៏ដោយ។ ពួកគេថតរូប និងថតវីឌីអូ ហើយនិងបង្ហោះរូបថត និងរូបភាពវីឌីអូទាំងនេះតាមបណ្តាញផ្សព្វផ្សាយសង្គម[១៨]ដែលអាចបញ្ជោះជាសក្តានុពលឲ្យប្រើអំពើហិង្សាតាមដងផ្លូវ ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌជាបទលហុ ដោយសារតែប្រជាពលរដ្ឋ បានឃើញហ្វូងមនុស្សផ្សេងទៀតកំពុងប្រព្រឹត្ត។ នៅពេលមើលរូបភាពវីឌីអូទាំងនេះ គេអាចកត់សម្គាល់ឃើញថា មហាជនដែលវាយដំទាត់ធាក់ជនសង្ស័យ មិនព្យាយាមគេចមុខពីម៉ាស៊ីនថតឡើយ ហាក់ដូចជាពួកគេមិនចាត់ទុកសកម្មភាពរបស់ពួកគេថាជាសកម្មភាពដែលអាចផ្តន្ទាទោសបានឡើយ។ ការវាយដំទាត់ធាក់អាចបញ្ឈប់នៅត្រឹមដំណាក់កាលនេះ នៅពេលដែលបុគ្គលណាម្នាក់ព្យាយាមគ្រប់គ្រងហ្វូងមហាជនការពារជនរងគ្រោះពីការវាយដំទាត់ធាក់ ហើយសុំឲ្យមន្រ្តីនគរបាលចាត់ការករណីបែបនេះអាចជាមន្ត្រីនគរបាលស្លៀកពាក់ឯកសណ្ឋានស៊ីវិល ឬជាបុគ្គលសាមញ្ញម្នាក់។ បុគ្គលនេះ ពិនិត្យមើលហោប៉ៅរបស់ចោរ ដើម្បីរកមើលផលចោរកម្ម និងអត្តសញ្ញាណកម្ម។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងករណីខ្លះ ប្រសិនបើការខឹងសម្បាមានកម្រិតខ្ពស់ពេក អំពើហិង្សាក៏កាន់តែមានកម្រិតធ្ងន់ធ្ងរឡើងរហូតដល់ជនសង្ស័យត្រូវបានសម្លាប់។ មហាជនបន្តវាយដំទាត់ធាក់ចោរ បើទោះបីនៅពេលចោរសុំក្តីមេត្តា និងមានឈាមកំពុងហូរក៏ដោយ។ ប្រជាពលរដ្ឋអាចមានប្រើអាវុធផងដែរ ដែលជាអាវុធប្រភេទអ្វីក៏ដោយដែលពួកគេអាចស្រវាចាប់បាន ដូចជាដំបងឈើ មួកសុវត្ថិភាព ដុំឥដ្ឋ ទុយោផ្លាស្ទិក ឬដែកបំពង់ទីប ដើម្បីវាយដំទាត់ធាក់ជនសង្ស័យថាចោរ។ ស្ថានភាពកាន់តែធ្ងន់ធ្ងរទៅៗ នៅពេលជនរងគ្រោះដេកដួលលើដី។បន្ទាប់មកមហាជនទាត់ធាក់ក្បាល[១៩] របស់ជនរងគ្រោះជាច្រើនដង បើទុកជាជនរងគ្រោះបាត់បង់ស្មារតីទៅហើយក៏ដោយ។ ក្នុងករណីមួយដែលត្រូវបានថតជាប់ក្នុងវីឌីអូ និងចែកផ្សព្វផ្សាយតាមបណ្តាញសង្គម បុរសម្នាក់ត្រូវបានគេឃើញគប់បំណែកថ្មប៉េតុងយ៉ាងធំ និងធ្ងន់ទៅលើ

---

[១៧] ដោយសារតែទំនាក់ទំនងនយោបាយ និងជាប្រវត្តិសាស្ត្រដ៏ស្មុគស្មាញ និងយូរអង្វែងរវាងប្រទេសវៀតណាម និងកម្ពុជា កំហឹងចំពោះនិគមជនវៀតណាមភាគតិចដែលរស់នៅកម្ពុជា បាននាំឱ្យមានការរើសអើង ការធ្វើទុក្ខបុកម្នេញ អំពើហិង្សា និងការធ្វើឱ្យពួកគេខ្វាត់ព្រាត់ ក្នុងទ្រុងទ្រាយធំដែលនាំឱ្យពួកគេស្ទើរតែវិនាស ជាពិសេសក្នុងរបបលន់ ណុល និងរបបខ្មែរក្រហមក្នុងទសវត្សរ៍ទី៧០។ ក្នុងទសវត្សរ៍ទី៨០ និគមជនវៀតណាមបានវិលមកវិញ។ នៅក្នុងអតីតកាលថ្មីៗនេះ គណៈបក្សប្រឆាំងមួយចំនួនបានប្រើប្រាស់វោហាសាសន៍ស្អប់ខ្ពើមវៀតណាមប្រឆាំងនឹងនិគមជនវៀតណាមដែលរស់នៅកម្ពុជា។

[១៨] វីឌីអូស្តីពីការវាយដំទាត់ធាក់/ការសម្លាប់ចោរដោយមហាជន ដែលត្រូវបានអ្នកឈរមើលថតផ្សាយបន្តផ្ទាល់ បង្ហោះតាមបណ្តាញផ្សព្វផ្សាយសង្គម ។

[១៩] ក្នុងវប្បធម៌កម្ពុជា ក្បាលគេចាត់ទុកជាផ្នែកមួយនៃខ្លួនមនុស្ស ដែលខ្ពស់បំផុត បរិសុទ្ធបំផុត និងស័ក្តិសិទ្ធបំផុត។ គេមានជំនឿថាព្រលឹងស្ថិតនៅក្នុងក្បាលមនុស្ស។ គេហាមមិនឲ្យប៉ះក្បាលគ្នានោះទេ។ ដូច្នេះតាមវប្បធម៌ខ្មែរ ទាត់ធាក់ក្បាលរបស់បុគ្គលណាម្នាក់ គឺជាអំពើហិង្សាហួសហេតុ ការទាត់ធាក់ក្បាលនឹងជើង ចាត់ទុកជាផ្នែកមួយនៃខ្លួនមនុស្ស លែងមានភាពបរិសុទ្ធបំផុត ហើយជាក់ស្តែងមានឆន្ទៈកំទេច ឬសម្លាប់បុគ្គលនោះចោល។

ក្បាលរបស់ជនសង្ស័យថាចោរ ដែលកំពុងដេកបាត់បង់ស្មារតី ដោយមានចេតនាជាក់ស្តែងចង់សម្លាប់ជនសង្ស័យនោះ។ ដើម្បីពន្យល់អំពីអំពើហិង្សាទាំងនេះ ប្រជាពលរដ្ឋពន្យល់ថា កំហឹងធ្វើឲ្យពួកគេភ្លេចលែងគឺតៈ “នៅពេលពួកយើងចាប់បានចោរ ពួកយើងខឹងសម្បាខ្លាំងណាស់ ដែលមិនអាចគ្រប់គ្រងលើខ្លួនឯងបាន”។

នៅពេលចុះបំពេញបេសកកម្មនៅមូលដ្ឋានជាទីកន្លែងដែលការសម្លាប់ចោរដោយមហាជនបានកើតឡើងការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានសួរប្រជាពលរដ្ឋមូលដ្ឋានថា តើពួកគេចាត់ទុកមហាជន ដែលបានចូលរួមក្នុងការវាយដំទាត់ធាក់ ជាមនុស្សរបៀបណា។ ប្រជាពលរដ្ឋដែលបានផ្តល់កិច្ចសម្ភាសន៍បដិសេធ និងគេចវេះមិនឆ្លើយនឹងសំណួរ ដោយធ្វើការពន្យល់ថា ជនល្មើសគឺជាចោរដែលបង្កការឈឺចាប់ដល់ប្រជាពលរដ្ឋ។ ដូច្នេះ អ្នកចូលរួមក្នុងការវាយដំទាត់ធាក់ដែលបណ្តាលឲ្យស្លាប់ជនសង្ស័យថាចោរមិនត្រូវបានគេចាត់ទុកថាជាឃាតករទេ តែចាត់ទុកថាជាអ្នកបង្ក្រាប ឬជាអ្នកប្រយុទ្ធប្រឆាំងនឹងបទល្មើសព្រហ្មទណ្ឌច្រើនជាងដែលជួយកំចាត់ជនល្មើស ហើយនិងជួយស្តារឡើងវិញនូវសន្តិសុខ និងសន្តិភាពក្នុងភូមិ។ តាមកិច្ចសម្ភាសន៍ដែលបានធ្វើឡើង នៅតាមទីកន្លែងដែលការសម្លាប់ដោយមហាជន ឬទីកន្លែងដែលការវាយដំទាត់ធាក់បានកើតឡើង វាទំនងដែលថា សូម្បីតែមន្ត្រីនគរបាលខ្លះដែលផ្តល់កិច្ចសម្ភាសន៍បានយល់ដឹងជាទូទៅថា មហាជនទាំងនេះជាអ្នកបានស្តារឡើងវិញនូវសន្តិសុខ ហើយមិនគួរចាត់ទុកពួកគេថាជាជនល្មើសនោះឡើយ។ ទោះបីយ៉ាណាក៏ដោយ ប្រជាពលរដ្ឋខ្លះ សម្តែងនូវ “ការអាណិតអាសូរ” ចំពោះជនរងគ្រោះ ដែលត្រូវបានគេវាយដំទាត់ធាក់រហូតដល់ស្លាប់ នៅពេលមានអំពើហិង្សាដោយមហាជននៅតាមដងផ្លូវ។ និន្នាការមួយដែលគួរលើកទឹកចិត្តពីការបានឃើញតាមរូបភាពវីឌីអូ ដែលបានបង្ហោះតាមហ្វេសប៊ុក គឺការធ្វើអន្តរាគមន៍ពីអ្នកឈរមើលដែលសុំឲ្យបញ្ឈប់ការវាយដំទាត់ធាក់ដោយនិយាយថា៖ “បានហើយ”។

## ៤.១.២.មូលហេតុនាំឲ្យឈានដល់អំពើនៃ “ការកាត់ទោសដោយមហាជន” ភ្លាមៗ

ផ្អែកតាមរបកគំហើញរបស់ការិយាល័យOHCHR ទំនងជាមានកត្តាជាច្រើនចូលរួមចំណែកក្នុង “ការកាត់ទោសដោយមហាជន” ធ្វើឡើងប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលត្រូវបានគេអះអាងថាជាអ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ដូចដែលបានកត់សម្គាល់ក្នុងផ្នែកវិធីសាស្រ្ត ការិយាល័យ OHCHR មិនអាចធ្វើការពនិត្យនូវគ្រប់ករណីទាំងអស់នៃ “ការកាត់ទោសដោយមហាជន” បានឡើយ ដោយសារមិនមានទិន្នន័យជាផ្លូវការ។ ដូច្នេះការវិភាគខាងក្រោមនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើកិច្ចសម្ភាសន៍ប្រកបដោយគុណភាព ដែលការិយាល័យ OHCHR បានធ្វើក្នុងករណីទាំងឡាយ ដែលបានសិក្សាស្រាវជ្រាវ ហើយការវិភាគនេះគ្មានគោលបំណងធ្វើឲ្យទូលំទូលាយ ឬកើនបរិមាណនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគនេះ ពិតជាបង្ហាញអំពីការយល់ឃើញរបស់អ្នកទាំងឡាយ ដែលបានផ្តល់កិច្ចសម្ភាសន៍ ដោយផ្តល់នូវការយល់ដឹងកាន់តែទូលំទូលាយនូវហេតុផលទាំងឡាយ ដែលនាំឲ្យមាន “ការកាត់ទោសដោយមហាជន”។

អ្នកផ្តល់កិច្ចសម្ភាសន៍ជាច្រើននាក់ បានបង្ហាញពីភាពគ្មានទំនុកចិត្តលើមន្ត្រីនគរបាលប្រព័ន្ធតុលាការ និងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ។ ឧទាះ អ្នកផ្តល់កិច្ចសម្ភាសន៍មួយចំនួនបានបង្ហាញថាពួកគេមានអារម្មណ៍ថា គ្មានសុវត្ថិភាព ដោយសារមើលឃើញពីកង្វះខាតនៃវិធានការពីមន្ត្រីនគរបាល។ ប្រជាពលរដ្ឋ បានរាយការណ៍ពីចំណាប់អារម្មណ៍របស់ពួកគេថា មន្ត្រីនគរបាលមិនអាច ឬគ្មានឆន្ទៈការពារប្រជាពលរដ្ឋពីអំពើប្លន់ និងការវាយប្រហារដោយហិង្សា ដែលកើតឡើងក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេឡើយ។ ជាលទ្ធផលប្រជាពលរដ្ឋជឿជាក់ថា ពួកគេមានសិទ្ធិការពារខ្លួន

តាមមធ្យោបាយប្រើប្រាស់អំពើហិង្សានៃ “ការកាត់ទោសភ្លាមៗ” នៅពេលពួកគេចាប់បានជនទាំងឡាយដែលត្រូវបានគេអះអាងថាជាជនល្មើស។ អ្នកផ្ដល់កិច្ចសម្ភាសន៍មួយចំនួនបានបង្ហាញថា ប្រព័ន្ធតុលាការត្រូវការចំណាយលុយកាក់ច្រើន ប្រើពេលវេលាយូរ មានលក្ខណៈស្មុគ្រស្មាញ និងគ្មានភាពប្រាកដប្រជា ធ្វើឲ្យ “ការកាត់ទោសដោយមហាជន” ជាជម្រើសមួយពេញនិយម ដើម្បីដោះស្រាយនូវការអះអាងថាជាបទល្មើសព្រហ្មទណ្ឌ ដែលកើតមានឡើងរាល់ថ្ងៃ។

អ្នកផ្ដល់កិច្ចសម្ភាសន៍ទាំឡាយ បានរំលេចឡើងនូវការយល់ឃើញផងដែរអំពីអំពើពុករលួយ ដែលជាបច្ច័យជំរុញអំពើនៃ “ការកាត់ទោសដោយមហាជន”។ អ្នកផ្ដល់កិច្ចសម្ភាសន៍ខ្លះបានអះអាងថា ប្រសិនបើពួកគេចាប់ចោរបាន ហើយប្រគល់ចោរទៅឲ្យមន្ត្រីនគរបាល ពួកគេជឿជាក់ថា ២ ឬ ៣ ថ្ងៃក្រោយមក មន្ត្រីនគរបាលនឹងដោះលែងពួកចោរទាំងនោះពីព្រោះពួកចោរផ្ដល់សំណូក។ ប្រសិនបើករណីបែបនេះបញ្ជូនទៅតុលាការ ប្រជាពលរដ្ឋមានជំនឿផងដែរថា ពួកចោរនឹងត្រូវបានដោះលែង បន្ទាប់ពីពួកចោរសូកប៉ាន់មន្ត្រីតុលាការ។ ដូច្នេះ ប្រជាពលរដ្ឋខ្លះគេគិតថា ការប្រគល់ជនទាំងឡាយដែលត្រូវគេអះអាងថា ជាជនល្មើសទៅឲ្យមន្ត្រីនគរបាល នឹងមិនទទួលបាននូវការផ្ដន្ទាទោសតាមច្បាប់ឡើយ។

ក្នុងបរិបទស្រដៀងគ្នានេះដែរអ្នកផ្ដល់កិច្ចសម្ភាសន៍ខ្លះបញ្ចេញទស្សនៈថា មន្ត្រីនគរបាល និងប្រព័ន្ធយុត្តិធម៌ មិនបានបំរើការងារជាសេវាសាធារណៈ ជាមួយនឹងការប្រព្រឹត្តទៅ និងការឲ្យរួចផុតពីការបង់ថ្លៃសេវាដោយស្មើភាព សម្រាប់ប្រជាពលរដ្ឋទាំងអស់ឡើយ ប៉ុន្តែបានបំរើការងារជាប្រព័ន្ធពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតច្រើនជាងដែលដើមបណ្ដឹងចំណាយប្រាក់ទៅឲ្យមន្ត្រីនគរបាល និងតុលាការ ដើម្បីទទួលបានលទ្ធផល ហើយដែលជនល្មើសអាចចំណាយប្រាក់សូកប៉ាន់ ដើម្បីទទួលបានការដោះលែង។ ហេតុដូច្នេះជនក្រីក្រ និងប្រជាពលរដ្ឋដែលមិនសូវមាន “ខ្នងបង្អែក” ទំនងជាមានលទ្ធភាពតិចតួចប្រើប្រាស់ប្រព័ន្ធតុលាការ ហើយក៏បែរមកប្រើប្រាស់មធ្យោបាយផ្សេងពីនេះដូចជាមធ្យោបាយ“កាត់ទោសដោយមហាជន”។

ពិតប្រាកដណាស់ អ្នកផ្ដល់កិច្ចសម្ភាសន៍ភាគច្រើន រាប់ទាំងប្រជាពលរដ្ឋមូលដ្ឋាន និងមន្ត្រីតុលាការផង បានអះអាងថា នៅពេលប្រជាពលរដ្ឋដាក់ពាក្យបណ្ដឹង ដើមបណ្ដឹងគួរតែផ្ដល់ប្រាក់ទៅឲ្យមន្ត្រីនគរបាល ឬតុលាការសម្រាប់“ចំណាយលើការស៊ើបអង្កេត”។[២០]

អ្នកផ្ដល់កិច្ចសម្ភាសន៍ទាំងឡាយ បានបង្ហាញនូវការកង្វះទំនុកចិត្តទៅលើតុលាការក្នុងការដាក់ទោសទណ្ឌដែលមានកម្រិតទោសធួនល្មមទៅនឹងបទល្មើសដែលប្រព្រឹត្ត។ ប្រជាពលរដ្ឋដែលផ្ដល់កិច្ចសម្ភាសន៍ជាច្រើននាក់បានយល់ថា បើទុកជាតុលាការបានរកឃើញចោរជាប់ពិរុទ្ធ ហើយកាត់ទោសចោរនោះក៏ដោយ ក៏ទោសនោះមានកម្រិតស្រាលពេក បើប្រៀបធៀបទៅនឹងការឈឺចាប់ និងការបាត់ បង់ដែលពួកគេទទួលរង។ ពួកគេចង់ឲ្យមន្ត្រីនគរបាល និងតុលាការចាត់វិធានការឲ្យបានតឹងរឹងជាងនេះ។ ប្រជាពលរដ្ឋដែលផ្ដល់កិច្ចសម្ភាសន៍ជាច្រើននាក់បានពន្យល់ថា ជនល្មើសទទួលទោសជាប់ពន្ធនាគាររយៈពេលខ្លីដែលពួកគេជឿជាក់ថា នឹងមិនអាចធ្វើឲ្យជនល្មើសរាងចាលក្នុងការប្រព្រឹត្តបទល្មើសទៀត បន្ទាប់ពីពួកគេត្រូវបានដោះលែង។

អ្នកផ្ដល់កិច្ចសម្ភាសន៍ទាំងឡាយបានបង្ហាញផងដែរ នូវការកង្វះទំនុកចិត្តលើប្រព័ន្ធគ្រប់គ្រងពន្ធនាគារដែលជាមធ្យោបាយមួយសម្រាប់ទណ្ឌិត ឬជនជាប់ឃុំធ្វើការកែប្រែខ្លួន។ ជំនឿពលរដ្ឋមួយគឺថា៖ ការកែប្រែខ្លួនដោយគ្រាន់តែចំណាយរយៈពេលខ្លីនៅក្នុង

[២០] មន្ត្រីតុលាការថ្លែងបញ្ជាក់ថា៖ “វាមានការលំបាកធ្វើការស៊ើបអង្កេតដោយសារខ្ញុំគ្មានលុយចំណាយលើសាំងមធ្យោបាយដឹកជញ្ជូននិងចំណាយលើអាហារហូបចុក”។ នៅពេលករណីមានការវិវត្តន៍ល្អសម្រាប់ដើមបណ្ដឹង ពេលនោះដើមបណ្ដឹងអាចផ្ដល់ប្រាក់បន្ថែមជា “ប្រាក់សងគុណ”។

ពន្ធនាគារមិនអាចកែប្រែខ្លួនទៅរួចបានទេដូចសុភាសិតខ្មែរបានពោលមកថា៖ ឆ្កែកន្ទុយខ្មៀន នៅតែខ្មៀនដដែល។

ប្រជាពលរដ្ឋខ្លះបាននិយាយថា ពួកគេមានការភ័យខ្លាចថា ជនទាំងឡាយដែលបំពីទោសជាប់ពន្ធនាគាររយៈពេលខ្លី អាចនឹងធ្វើការសងសឹកទៅលើអ្នកធ្វើការចោទប្រកាន់ ព្រមទាំងទៅលើសាក្សីទាំងឡាយ។ ដូច្នេះ សម្រាប់ប្រជាពលរដ្ឋមួយចំនួន ការកំចាត់ចោលជាក់ស្តែង[២១] នូវជនទាំងឡាយដែលធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់សង្គម គឺជាមធ្យោបាយតែមួយគត់ដើម្បីស្តារឡើងវិញ នូវសន្តិសុខ និងសន្តិភាពយូរអង្វែង។

យ៉ាងហោចណាស់ការយល់ឃើញ អំពីផ្នែកកង្វះខាតទំនុកចិត្តលើមន្ត្រីនគរបាល តុលាការ និងពន្ធនាគារ អាចត្រូវបានពន្យល់តាមហេតុការណ៍ដែលថា ចំណេះដឹងផ្នែកច្បាប់ ចំណេះដឹងផ្នែកនីតិរដ្ឋ និងចំណេះដឹងខាងសិទ្ធិមនុស្ស មានលក្ខណៈទន់ខ្សោយ។ ប្រជាពលរដ្ឋដែលចូលរួមក្នុង "ការកាត់ទោសដោយមហាជន" មិនយល់ទេដែលថា បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិទទួលបាននូវការសន្មត់ជាមុនថាជាជនគ្មានទោស។ ពួកគេក៏មិនបានយល់ដឹងថា អំពើឃាតកម្មប្រព្រឹត្តដោយប្រជាពលរដ្ឋ ដែលចូលរួមក្នុងការសម្លាប់ដោយហ្វូងមហាជន គឺជាអំពើអាចមានទោសតាមច្បាប់។

លើសពីនេះទៅទៀតពួកគេមិនបានដឹងថាប្រទេសកម្ពុជាបានលុបបំបាត់ទោសប្រហារជីវិតក្នុងឆ្នាំ១៩៨៩ ឬពួកគេមិនបានយល់ព្រមចំពោះការលុបទោសប្រហាជីវិតឡើយ។[២២] ផ្ទុយទៅវិញអ្នកផ្តល់កិច្ចសម្ភាសន៍ខ្លះមានជំនឿថាការអនុវត្តទោសប្រហារជីវិតភ្លាមៗ (ការសម្លាប់ក្រៅច្បាប់) ចំពោះជនល្មើសដែលត្រូវបានចាប់ខ្លួនក្នុងករណីប្រព្រឹត្តបទល្មើសជាក់ស្តែងអាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋាន ហើយនិងមន្ត្រីនគរបាល ជាពិសេសអនុវត្តទោសនេះចំពោះចោរ។ តាមកិច្ចសម្ភាសន៍ដែលបានធ្វើនៅទីកន្លែងដែលការសម្លាប់ដោយមហាជនបានកើតឡើង ជាទូទៅអ្នកសងសឹកត្រូវបានគេចាត់ទុកថា ជាអ្នកធ្វើគុណប្រយោជន៍ច្រើន ជាជាងត្រូវបានគេចាត់ទុកថាជាជនល្មើស។

ហេតុផលមួយទៀតទំនងជាបច្ច័យដែលជម្រុញឲ្យកើត "ការកាត់ទោសដោយមហាជន" នោះគឺស្ថានភាពក្រីក្រ។ នៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជា ដែលប្រជាពលរដ្ឋភាគច្រើនយកខ្លួនជាទីពឹងតែលើការដោះស្រាយនូវស្ថានភាពពិតនៃជីវិតប៉ុណ្ណោះ ការបាត់បង់លុយកាក់ ឬម៉ូតូរបស់ពួកគេ អាចមានអានុភាពមហន្តរាយទៅលើជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ប្រជាពលរដ្ឋដែលផ្តល់កិច្ចសម្ភាសន៍ បានបង្ហាញអារម្មណ៍ស្អប់ខ្ពើមខ្លាំងចំពោះពួកចោរ។ នៅពេលចាប់បានចោរការខឹងសម្បានិងការខកចិត្តដែលពុះកញ្ជ្រោលឡើង ក៏មានអារម្មណ៍រំសាយដោយការវាយដំ និងទាត់ធាក់ពួកចោរទាំងនោះ ជួនកាលវាយដំ ទាត់ធាក់

[២១] វាយចោល គឺជាសំនួនសេចក្តីភាសាខ្មែរ ដែលត្រូវបានគេយកមកប្រើ សម្រាប់សម្លាប់មនុស្សដោយហ្វូងមហាជន ឬហ្វូងមនុស្សតាមដងផ្លូវដែលមានអំពើចំនួន ២៖ វាយ និង ចោល។

[២២] ប្រទេសកម្ពុជាបានលុបបំបាត់ទោសប្រហារជីវិតក្នុងឆ្នាំ១៩៨៩។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣) ត្រង់មាត្រា ៣២ ចែងថា៖ "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។ ទោសប្រហារជីវិត មិនត្រូវឲ្យមានឡើយ"។ នៅក្នុងឆ្នាំ១៩៩៥ នាយករដ្ឋមន្ត្រី សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ លើកព្រះរាជសំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងដាក់បញ្ចូលទោសប្រហារជីវិតឡើងវិញចំពោះឃាតករ និងឈ្មួញជួញដូរគ្រឿងញៀន ប៉ុន្តែព្រះរាជសំណើរបស់ព្រះអង្គត្រូវបានបដិសេធចោល៖ (http://www.phnompenhpost.com/national/why-capital-punishment-bad-idea-cambodia)។

ពួកចោររហូតដល់ស្លាប់ក៏មាន។ ជាលទ្ធផល ការធ្វើទោសតាមរយៈ"ការកាត់ទោសដោយមហាជន"អាចគ្មានភាពសមាមាត្រទៅនឹងអំពើល្មើសទាល់តែសោះ។ បុគ្គលម្នាក់ អាចនឹងត្រូវបានហ្វូងមនុស្សសម្លាប់ ដោយសារតែអំពើអ្វីមួយដែលច្បាប់កំណត់ត្រឹមតែជាបទល្មើសលហុប៉ុណ្ណោះ។[២៣]

## ៤.២. ការបង្ហាញពីអំពើនៃ "ការកាត់ទោសដោយមហាជន" ប្រឆាំងនឹងអ្នកដែលត្រូវបានចោទថាធ្វើអំពើអាបធ្មប់

### ៤.២.១. ការចោទប្រកាន់ពីការប្រព្រឹត្តអំពើអាបធ្មប់ និងការធ្វើទុក្ខបុកម្នេញ[២៤]

"ការកាត់ទោសដោយមហាជន"មួយប្រភេទទៀតដែលមិនទាន់បានស្រាវជ្រាវច្បាស់លាស់តាមទស្សនៈសិទ្ធិមនុស្ស គឺជាការសម្លាប់ ការវាយដំទាត់ធាក់កាយាយីរំខាន និង/ឬការបណ្តេញចេញនូវជនទាំងឡាយ ដែលត្រូវបានចោទថាប្រព្រឹត្តអំពើអាបធ្មប់។

ការមានជំនឿទៅលើកម្លាំងអធិធម្មជាតិ ដែលមនុស្សមួយចំនួនបានប្រើ ដើម្បីធ្វើអំពើល្អ ឬអំពើអាក្រក់ គឺជារឿងធម្មតាទៅហើយនៅប្រទេសកម្ពុជា ហើយក៏មានផលប៉ះពាល់សំខាន់ក្នុងជីវភាពសាធារណៈ និងឯកជន។ ព្រះសង្ឃ ឬអាចារ្យ ដែលមានចំណេះដឹងពិសេសខាង "មន្តអាគមក្នុងផ្លូវល្អ" រៀបចំពិធីសាសនា ធ្វើវត្ថុផ្សេងៗឧបកិច្ច ឬគូររូបផ្សេងៗលើផ្ទាំងក្រណាត់ ឬចារលើដងខ្លួន ដើម្បីការពារមនុស្សឲ្យរួចផុតពីឥទ្ធិពលអធិធម្មជាតិមិនល្អពីខាងក្រៅ។ ផ្ទុយទៅវិញ មនុស្សមួយចំនួនត្រូវបានគេសង្ស័យថា មានការប្រាស្រ័យទាក់ទងជាមួយកម្លាំងអំពើអាបធ្មប់ ឬ "មន្តអាគមក្នុងផ្លូវអាក្រក់" ដែលប្រើដើម្បីធ្វើបាបអ្នកដទៃ។

ការសម្លាប់ ការវាយដំទាត់ធាក់ ការរំខានយាយីឬការបណ្តេញចេញនូវជនទាំងឡាយ ដែលត្រូវបានចោទថាប្រើ"មន្តអាគមក្នុងផ្លូវអាក្រក់"ឬធ្វើអំពើអាបធ្មប់ គឺជារឿងធម្មតាទៅហើយនៅកម្ពុជា ដែលមនុស្សដែលត្រូវគេកំណត់ថាជាអាបធ្មប់ ក្លាយទៅជាសត្វស្វាស៊ីបាយលាបមាត់ពពែ សម្រាប់បញ្ហាផ្សេងៗនៅក្នុងភូមិ។ ប្រការទាំងនេះ រាប់បញ្ចូលទាំងគ្រោះកាចអកុសល ដែលគួរឲ្យសង្ស័យ ការឈឺចាប់ ជម្ងឺឈឺថ្កាត់ និងមរណៈភាព។ ក្នុងពិភពលោកដែលគេចាត់ទុកថាជាការគំរាមកំហែង ក្នុងករណីដែលប្រជាពលរដ្ឋខ្វះសំណាញ់សុវត្ថិភាពសង្គម អាចមានអារម្មណ៍តែលតោលគ្មានទីពឹង នៅពេលប្រឈមមុខនឹងដំណើរប្រែប្រួលនៃជីវិតប្រចាំថ្ងៃ ដោយស្វែងរកមនុស្សដើម្បីស្តីបន្ទោស អាចជាចម្លើយដើម្បីជួយប្រជាពលរដ្ឋពុះពារនឹងការភ័យខ្លាចដោយផ្ទាល់។

ពុំមានស្ថិតិច្បាស់លាស់ស្តីពីចំនួនឧប្បត្តិហេតុនៃអំពើហិង្សា ដែលទាក់ទងនឹងអំពើអាបធ្មប់នៅប្រទេសកម្ពុជាឡើយ។ ទោះបីយ៉ាងណាក៏ដោយ ផ្អែកតាមព័ត៌មានដែលទទួលបានពីមន្ត្រីនគរបាលនៅថ្នាក់មូលដ្ឋាន និងព័ត៌មានដែលទទួលបានពីមន្ត្រីតុលាការសាលាដំបូងខេត្ត ចំនួនការសម្លាប់ជនរងគ្រោះ ដែលត្រូវបានចោទពីអំពើអាបធ្មប់ គឺមានសារៈសំខាន់នៅក្នុងអំឡុងពេលកន្លងទៅថ្មីៗនេះ។[២៥] បច្ចុប្បន្ននេះ ចំនួន

---

[២៣] នៅក្នុងឆ្នាំ២០១៣ អ្នកឈរមើលមួយក្រុមនៅរាជធានីភ្នំពេញ បានវាយដំទាត់ធាក់យុវជនវ័យក្មេង ជាចោរម្នាក់រហូតដល់ស្លាប់ ក្រោយពីយុវជននេះលួចប្រាក់ ២០ ដុល្លារអាមេរិកពីហោប៉ៅអ្នកទេសចរណ៍ម្នាក់។

[២៤] ពាក្យថាអំពើអាបធ្មប់ ត្រូវបានកំណត់និយមន័យដោយបណ្តាញព័ត៌មានស្តីពីសិទ្ធិមនុស្ស និងអំពើអាបធ្មប់ តាមរយៈរបាយការណ៍ដែលបានបង្ហាញជូននៅក្នុងសម័យប្រជុំលើកទី ២៥ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៅខែមីនាឆ្នាំ២០១៤: http://www.whrin.org/whrin-publications/.។

[២៥] ចៅក្រមសាលាដំបូងខេត្ត និងមន្ត្រីនគរបាលភាគច្រើន ដែលបានបំពេញមុខងារនៅចន្លោះទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០ បានរាយការណ៍ថា បទល្មើសទាំងនេះ មានចំនួនច្រើននៅអំឡុងពេលអតីតកាល បើទុកជាពុំមានស្ថិតិជាផ្លូវការក៏ដោយ។ មន្ត្រីនគរបាលម្នាក់នៅខេត្តកំពង់ស្ពឺបានរាយការណ៍ថា នៅទសវត្សរ៍ឆ្នាំ១៩៩០ មន្ត្រីនគរបាល មិនបានធ្វើការស៊ើបអង្កេតបទល្មើសទាក់ទងនឹងអំពើអាបធ្មប់ឡើយ ដោយសារបទល្មើសបែបនេះមានចំនួនច្រើនពេក។

ករណីរំលោភសិទ្ធិមនុស្ស ទាក់ទងនឹងអំពើអាបធ្មប់ត្រូវបានគេរាយការណ៍មកថា មានចំនួនថយចុះ ក៏ប៉ុន្តែនៅតែជាបញ្ហាកង្វល់ដដែល នៅក្នុងតំបន់ដាច់ស្រយាលមួយចំនួនក្នុងប្រទេសកម្ពុជា។ នៅចន្លោះឆ្នាំ២០១២ និងឆ្នាំ២០១៨ ការិយាល័យ OHCHR បានចងក្រងទុកជាឯកសារនូវករណី ទាក់ទងនឹងអំពើអាបធ្មប់ចំនួន ៤៩ ករណី ក្នុងចំណោមករណីទាំងនេះមាន ៣៥ ករណីទាក់ទងនឹងការសម្លាប់ដោយមហាជន ហើយនិង ១៤ ករណីជាការប៉ុនប៉ងសម្លាប់ ឬជាករណីនៃការរំខានយាយី។

ដោយកត់សម្គាល់មើលលើការអនុវត្តជាក់ស្តែងអំពើអាបធ្មប់នៅកម្ពុជា ជារឿយៗមានជាទម្រង់នៃការចោទប្រកាន់ ដែលធ្វើឡើងចំពោះប្រជាពលរដ្ឋមួយចំនួន។[២៦]តាមកិច្ចសម្ភាសន៍ដែលធ្វើឡើងជាមួយប្រជាពលរដ្ឋ ដែលត្រូវបានគេចោទថាជាអាបធ្មប់ ហើយនិងជាមួយសមាជិកគ្រួសាររបស់ជនរងគ្រោះ ដែលត្រូវបានគេសម្លាប់តាមការចោទប្រកាន់ ដែលមានភស្តុតាងតិចតួចបំផុត ត្រូវបានគេរកឃើញថាពួកគគាំទ្រគំនិតដែលថា បុគ្គលទាំងនេះកំពុងរៀបចំពិធីសាសនា ឬពិធីសែនព្រេនប្រភេទអ្វីមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ការចោទប្រកាន់ជារឿងពិត ហើយការចោទប្រកាន់ទាំងនេះនាំឲ្យមានស្លាកស្នាមទុរយសដល់សាមីជនដែលបានធ្វើឡើងពីអ្នកភូមិដទៃទៀត។

## ៤.២.២.ទិដ្ឋភាពទូទៅនៃព្រឹត្តិការណ៍វាយប្រហារប្រឆាំងនឹងអ្នកដែលត្រូវបានចោទថាធ្វើអំពើអាបធ្មប់

បច្ចុប្បន្នមានធាតុផ្សំមួយចំនួននៅក្នុងព្រឹត្តិការណ៍ជាបន្តបន្ទាប់ ដែលនាំឲ្យមានការចោទប្រកាន់មនុស្សថាជាអាបធ្មប់។ តាមធម្មតាការចោទប្រកាន់នេះ ផ្តើមចេញពីពាក្យចចាមអារ៉ាម។ នៅពេលស្ថានភាពមួយមានលក្ខណៈគំរាមកំហែងជាសក្តានុពល ប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ ព្យាយាមស្វែងរកការពន្យល់ និងស្វែងរកអ្នកទទួលខុសត្រូវ។ នៅតាមជនបទនៃប្រទេសកម្ពុជា ប្រការនេះតាមធម្មតា វាផ្តើមចេញពីជម្ងឺជាបន្តបន្ទាប់ គ្រោះកាចអកុសល និងមរណៈភាពដែលត្រូវបានគេមើលឃើញដោយសង្ស័យថាកំពុងកើតឡើងនៅទីកន្លែងមួយ។ ប្រសិនបើគ្មានការពន្យល់ច្បាស់លាស់ទេ ប្រជាពលរដ្ឋអាចចាត់ទុកថាវាអាចជាអន្តរាគមន៍អធិធម្មជាតិ។

នៅពេលមានមនុស្សឈឺ តាមធម្មតាដំបូងឡើយត្រូវពឹងផ្អែកទៅលើថ្នាំពេទ្យជាប្រភេទថ្នាំមកពី បស្ចឹមប្រទេស ដើម្បីស្វែងរកដំណោះស្រាយយ៉ាងរហ័សចំពោះបញ្ហាសុខភាព។ ក្នុងករណីដែលប្រជាពលរដ្ឋមិនមានអារម្មណ៍ធូរស្បើយគ្រាន់បើទេ ដោយសារគ្រូពេទ្យមិនអាចព្យាបាលពួកគេឲ្យជាសះស្បើយបាន អ្នកជម្ងឺអាចនឹងទៅរកគ្រូខ្មែរ ឬហៅថាគ្រូស្តោះ ដែលជាអ្នកអាចពន្យល់អំពីបញ្ហា ដែលបង្កឡើងពីខ្មោចបីសាចដែលចូលរូប[២៧] ឬអាបធ្មប់។

[២៦] គ្រូខ្មែរដែល “ កែ ” គ្រោះបង្កឡើងពីអង្គអធិធម្មជាតិ ខ្មោចព្រាយបីសាច ឬអាបធ្មប់ អនុវត្តជាចំហនៅតាមផ្ទះ ឬនៅក្នុងវត្ត។ ផ្ទុយទៅវិញគ្មានអ្នកណានិយាយជាចំហថា គ្រូខ្មែរទាំងនេះធ្វើមន្តអាគមក្នុងផ្លូវអាក្រក់នោះឡើយ។

[២៧] គេអាចសុំឲ្យអ្នកស្នងរូបរៀបចំពិធីសាសនា ដើម្បីកំណត់ឈ្មោះរបស់ខ្មោចព្រាយបីសាច ដែលខឹងសម្បាចូលក្នុងរូប ហើយសួរខ្មោចព្រាយបីសាចដែលចូលរូបថា ហេតុអ្វីក៏ធ្វើឲ្យកូនចៅឈឺ។ តាមធម្មតា ខ្មោចព្រាយបីសាចនោះនឹងពន្យល់ថា អ្នកជម្ងឺរំលោភបំពានលើទំនៀមទម្លាប់សង្គម ដូចជាចោលកាកសំណល់ទៅលើទីកន្លែងខ្មោចព្រាយបីសាចរស់នៅ ឬសង់ផ្ទះខុសទៅនឹងទិសតាមប្រពៃណី។ គេរៀបចំពិធីសាសនា ឬពិធីសែនព្រេនដើម្បីផ្គាប់ចិត្តខ្មោចព្រាយបីសាច។ ឥទ្ធិពលអាក្រក់ក្នុងខ្លួនអ្នកជម្ងឺ ត្រូវបំប្លែងទៅជារូបតំណាង ដែលសូនរូបពីម្សៅអង្ករ រួចយកទៅបោះចោលនៅខាងក្រៅភូមិករ។ តួអង្គតំណាងសភាវៈអាក្រក់ នឹង “ សែបសោយ” រូបតំណាងជំនួស ហើយទុកអ្នកជម្ងឺនោះឲ្យរស់នៅក្នុងភាពសុខសាន្ត។ ភាពស្របគ្នាមួយចំពោះពិធីសាសនា ឬពិធីសែនព្រេនបណ្តេញរូប ឬបណ្តេញខ្មោចព្រាយបីសាច អាចត្រូវធ្វើឡើងដោយសម្លាប់មនុស្ស ដែលមានអាកប្បកិរិយាមិនល្អ (មនុស្សដែលត្រូវបានចោទប្រកាន់ពីបទប្លន់ អាកប្បកិរិយាមិនល្អក្នុងសង្គម។ល។) ឬនាំយកឥទ្ធិពលអាក្រក់ចេញ (មនុស្សដែលត្រូវបានចោទប្រកាន់ពីអំពើអាបធ្មប់)។

នៅឆ្នាំ២០១៧ មនុស្សភាគច្រើនស្លាប់ដោយសារជម្ងឺផ្សេងៗ ក្នុងរយៈពេលខ្លីនៅក្នុងភូមិមួយនៅខេត្តកំពង់ស្ពឺ។ ព្រឹត្តិ ការណ៍ខុសធម្មតា បានកើតឡើងផងដែរ ដូចជារន្ទះបាញ់ផ្ទះ។ មនុស្សម្នាក់ទៅរកគ្រូទាយ និងព្រះសង្ឃ ដើម្បីស្វែងរកការពន្យល់ចំពោះព្រឹត្តិការណ៍ដ៏គួរឲ្យព្រួយបារម្ភនេះ។ ព្រះសង្ឃមានសង្ឃដីកាសន្និត់ថា ព្រឹត្តិ ការណ៍ទាំងនេះ គឺបណ្តាលមកពីវត្តមាន “តួអង្គតំណាងសភាវៈអាក្រក់” នៅក្នុងភូមិ ហើយស្នើសុំឲ្យរៀបចំពិធីសាសនាមួយ ដើម្បីកំចាត់សភាវៈអាក្រក់នេះ។ មានពាក្យចចាមអារ៉ាមនិយាយតៗគ្នាថា វត្តមាន “តួអង្គតំណាងសភាវៈអាក្រក់” អាចជាបុរសម្នាក់ឈ្មោះ ភាព ភ័ក្ត្រ ជាគ្រូខ្មែរ ដែលមកកាន់ភូមិនេះជារឿយៗ ដើម្បីមកជួបប្រពន្ធចុងទី២របស់គាត់។ គ្រូទាយរស់នៅក្នុងតំបន់នោះបានបញ្ជាក់ថា តួអង្គតំណាងសភាវៈអាក្រក់ គឺបុរសម្នាក់នេះ។ ការចោទប្រកាន់ឈ្មោះ ភ័ក្ត្រ ថាជាអាបធ្មប់ កើតមានជាយូរលង់ណាស់មកហើយ នៅពេលប្រជាពលរដ្ឋចាប់ផ្តើមសួនាំពីការផ្លាស់ប្តូរអាកប្បកិរិយាប្រពន្ធចុងទី២របស់គាត់ឈ្មោះ សុខ ផាន់នី ដែលតាមការរាយការណ៍មកថា គាត់ចាប់ផ្តើមផឹកស្រា និយាយសំដីអសុរសទៅកាន់ប្រជាពលរដ្ឋជិតខាង រហូតដល់ជេរប្រទេចពួកគេ ដោយនិយាយយោងដល់ “មន្តអាគមអូមអាម” បន្ទាប់ពីជួបប្តីរបស់គាត់។ តាមការរាយការណ៍មក សុខ ផាន់នី ជាមនុស្សតែម្នាក់គត់នៅក្នុងភូមិ មានអាកប្បកិរិយាខុសប្លែក ប្តូរមកកាន់សាសនាគ្រិស្ត ហើយមានកូនចូលរៀនក្នុងមណ្ឌលកុមារកំព្រា-សាសនាគ្រិស្ត។ ឈ្មោះ ភ័ក្ត្រ ត្រូវបានគេរាយការណ៍មកថា ជាបុរសមានសណ្តានចិត្តល្អ ប៉ុន្តែហេតុការណ៍ពិតដែលថាគាត់ចេះរបៀបប្រើប្រាស់រុក្ខជាតិផ្សំធ្វើជាឱសថ រូបមន្តមន្តអាគម ហើយនិងចេះរបៀបធ្វើយ័ន្ត និងខ្សែកថាសម្រាប់ក្មេងៗការពារខ្លួន បង្កើនការសង្ស័យកាន់តែច្រើនឡើង។ បុរសឈ្មោះ ភ័ក្ត្រ រស់នៅក្នុងភូមិជិតខាងគ្នា ប៉ុន្តែគាត់បង្រៀនប្រពន្ធឈ្មោះ សុខ ផាន់នី ពីរបៀបប្រើរុក្ខជាតិផ្សំធ្វើឱសថលក់ទៅឲ្យអ្នកភូមិ។ អំពើហិង្សាទៅលើឈ្មោះ ភ័ក្ត្រ បានផ្ទុះឡើងក្នុងខែមិនា ឆ្នាំ២០១៧ នៅពេលពិធីសាសនាមួយត្រូវបានរៀបចំឡើងនៅក្នុងភូមិ ដើម្បីកំចាត់ឥទ្ធិពលសភាវៈអាក្រក់ (ពិធីបណ្តេញខ្មោចព្រាយបីសាច) និងស្តារឡើងវិញនូវភាពសុខដុមរម្យនា។ ទីកន្លែងស័ក្តិសិទ្ធិមួយត្រូវបានរៀបចំឡើង។ ចៅអធិការវត្តចំនួន ៨ អង្គប្រចាំវត្តចំនួន ៨ វត្តត្រូវបានដាក់ពង្រាយនៅជុំវិញភូមិ តាមចំណុចសំខាន់ៗចំនួន ៨ កន្លែង ហើយនិងអន្តរការី។ អំបោះ ត្រូវបានដាក់រាយនៅជុំវិញភូមិ ហើយចៅអធិការវត្តមួយអង្គ ដែលមានកិត្តិនាមល្បីល្បាញ ត្រូវគង់នៅចំកណ្តាលភូមិ។ ព្រះសង្ឃគ្រប់អង្គធ្វើពិធីសូត្រធម៌ ដោយព្រះហស្តកាន់អំបោះ។ ឈ្មោះ ភ័ក្ត្រ បានមកដល់នៅពេលកំពុងធ្វើពិធីនៅពេលនោះគាត់ត្រូវបានហាមឃាត់មិនឲ្យចូល និងចាកចេញពីភូមិនោះ។ តាមការរាយការណ៍មកគឺថាឈ្មោះ ភ័ក្ត្រ មានចេតនាវាយកំទេចជើងទម្រអំបោះ ដែលរៀបពិធីចូលទៅក្នុងភូមិ។ ការអុកឡុកនេះត្រូវបានអ្នកភូមិមើលឃើញ ដែលជាភស្តុតាងយ៉ាងច្បាស់បញ្ជាក់ថាឈ្មោះ ភ័ក្ត្រ ពិតជាអាបធ្មប់ដែលបៀតបៀនអ្នកភូមិមែន។ ភ្លាមៗនោះ មហាជនដែលខឹងសម្បាចំនួន ២០០ នាក់ទៅ ៣០០ នាក់ ដែលដឹកនាំដោយមេភូមិនាំគ្នាសម្រុកចូលទៅកាន់ផ្ទះឈ្មោះសុខផាន់នីជាប្រពន្ធចុងទី២របស់ឈ្មោះភ័ក្ត្រ។នៅទីនោះទាំងប្តីនិងប្រពន្ធត្រូវបានរារាំងមិនឲ្យចេញចូលក្នុងផ្ទះក្នុងរយៈពេលមួយ ដោយមានរបងពាត់ជុំវិញផ្ទះនោះ។ នៅពេលហ្វូងមហាជនមានមនុស្សមកចូលរួមកាន់តែច្រើនឡើង និងកាន់តែមានភាពគឃ្លើនឡើង មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ ក៏សុំជំនួយគាំទ្រពីមន្ត្រីនគរបាលនៅអធិការដ្ឋាននគរបាលស្រុក និងស្នងការដ្ឋាននគរបាលខេត្ត។ គ្រួសារឈ្មោះ ភ័ក្ត្រ និងឈ្មោះ សុខ ផាន់នី ដែលមានសមាជិកចំនួន ៨ នាក់ត្រូវបានសង្គ្រោះជីវិតពីសំណាក់មន្ត្រីនគរបាល ដែលបាននាំពួកគេទៅកាន់អធិការដ្ឋាននគរបាលស្រុក។ (ប្រភព៖ កិច្ចសម្ភាសន៍ដែលបានធ្វើឡើងដោយការិយាល័យOHCHR)។

នៅក្នុងករណីដែលពិបាក និងមិនអាចព្យាបាលជាបាន គ្រូខ្មែរបុរាណអាចប្រាប់ថា គាត់មិនអាចព្យាបាលអ្នកជម្ងឺឲ្យជាសះស្បើយបានទេ ដោយសារជម្ងឺនេះកើតមកពីអាបធ្មប់ ដែល “មានកម្លាំងមន្តអាគមខ្លាំងក្នុងផ្លូវអាក្រក់”។ បន្ទាប់មក គ្រូខ្មែរបុរាណនោះ អាចកំណត់អត្តសញ្ញាណមនុស្សមិនច្បាស់លាស់ ដោយបង្ហាញនូវតម្រុយដូចជា“មនុស្សដែលធ្វើឲ្យអ្នកមានជម្ងឺ គឺរស់នៅទិសខាងជើងផ្ទះរបស់អ្នកឯង” ឬ “មនុស្សនោះរាងខ្ពស់ ហើយមានម្រាមដៃតូចៗ”។ គ្រូខ្មែរបុរាណ កម្រនឹងប្រាប់ឈ្មោះពិតប្រាកដរបស់មនុស្សណាម្នាក់ណាស់។ ក្នុងករណីមួយនៅខេត្តកំពង់ចាម គ្រូខ្មែរ បានប្រាប់ឈ្មោះពិតប្រាកដរបស់មនុស្សម្នាក់ដែលជាជនសង្ស័យថាជាអាបធ្មប់។[២៨]“បន្ទាប់ពីមានការចោទប្រកាន់រួចមក មនុស្សដែលគេចោទប្រកាន់ ត្រូវបានគេបណ្តេញចេញពីភូមិករជាច្រើនឆ្នាំ និងទទួលរងនូវការវាយប្រហារ ព្រមទាំងទទួលរងនូវរបួសស្នាមចំនួន ២ លើក ដោយសារគេលួចកាប់នឹងពូថៅ។

មនុស្សដែលត្រូវគេចោទថា បានប្រព្រឹត្តអំពើអាបធ្មប់ ត្រូវបានគេនិយាយថា “ធ្វើអំពើ ឬដាក់អំពើ” លើប្រជាពលរដ្ឋបណ្តាលឲ្យពួកគេមានជម្ងឺរហូតដល់ស្លាប់។ មនុស្សដែលត្រូវគេចោទថាចេះធ្វើអំពើធ្មប់ គេហៅថា ធ្មប់ ប្រសិនបើគាត់ជាមនុស្សប្រុស ហើយគហៅថា អាប ប្រសិនបើគាត់ជាមនុស្សស្រី។ នៅក្នុងចំណោម ៣៥ ករណីដែលត្រូវបានចងក្រងទុកជាឯកសារ មាន ៣ ករណី ដែលអ្នកចេះធ្វើអំពើជាមនុស្សស្រី។

តាមធម្មតាអាប/ធ្មប់ត្រូវបានរាយការណ៍មកថាជាមនុស្សដែលចេះរូបមន្តមន្តអាគមអូមអាមចារជាសំណេរដោយដៃរក្សាទុកជាការសម្ងាត់ ឬកាន់កាប់វត្ថុមន្តអាគមមានមហិទ្ធីឫទ្ធិ[២៩] ដើម្បីជួយពួកគេបង្កនូវគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដទៃ។ មនុស្សមួយចំនួនត្រូវបានគេនិយាយថាជាធ្មប់អាបជាប់ពីកំណើតដោយស្នងមត៌កពីជីដូនជីតាមក ឬទើបតែក្លាយខ្លួនជាអាបធ្មប់បន្ទាប់ពីមានជម្ងឺ។ ការចោទប្រកាន់ថាចេះអំពើអាបធ្មប់ជាសែស្រឡាយ អាចនាំឲ្យសម្លាប់កូនៗ ឬរហូតដល់សម្លាប់សហព័ទ្ធម្ខាងទៀតរបស់បុគ្គលដែលត្រូវបានគេចោទថាជាអាបធ្មប់។ ការសម្លាប់បែបនេះត្រូវបានគេដឹងជាទូទៅថា “សម្លាប់ទាំងពូជ“។

នៅពេលបុគ្គលណាម្នាក់ត្រូវបានគេកំណត់អត្តសញ្ញាណថាជាធ្មប់ ពាក្យចចាមអារ៉ាមអំពីអំពើអាក្រក់ជាក់លាក់ទាំងនេះរបស់ពួកគេ នឹងក្លាយជាដំណឹងលេចឮតៗគ្នា។[៣០] នៅក្នុងករណីភាគច្រើន ការចោទប្រកាន់ពីអំពើអាប ដំបូងឡើយគ្រាន់តែត្រូវបានធ្វើឡើងពីមនុស្សចំនួន ២ ឬ ៣ នាក់បុណ្ណោះច្រើនតែជាសាច់ញាតិរបស់ពួកគេ។ ក្រោយមក ការចោទប្រកាន់បានលេចឮដល់ភូមិទាំងមូល ហើយក្នុងករណីខ្លះលេចឮដល់ភូមិជាច្រើន។ ពាក្យចចាមអារ៉ាមជួយបង្កើតសាមគ្គីភាពរួមគ្នា ដែលបង្កលក្ខណៈឲ្យមានបណ្តឹងបរិហារ និងពលីកម្មរបស់ជនរងគ្រោះ។ ពាក្យចចាមអារ៉ាមទាំងឡាយពោពេញទៅដោយរឿងរ៉ាវបំភ្លៃ ដែលត្រូវបានប្រមូលផ្តុំបង្កើតជាការចោទប្រកាន់មានពិរុទ្ធ។ ដំបូងឡើយបុគ្គលត្រូវបានគេបណ្តេញចេញ[៣១] ហើយ

---

[២៨] នៅក្នុងសតវត្សរ៍ទី១៩ មានមាត្រាមួយចំនួននៃក្រមច្បាប់ទាក់ទងនឹងការធ្វើអំពើអាបធ្មប់ ដែលអាចកាត់ទោសប្រហារជីវិត ប្រសិនបើមានភស្តុតាងបញ្ជាក់។ គ្រូខ្មែរ មានភារកិច្ចកំណត់អត្តសញ្ញាណ និងប្តឹងបរិហារប្រឆាំងនឹងអាបធ្មប់ទៅកាន់មន្រ្តីតុលាការ។ គេទទួលស្គាល់ថាគ្រូខ្មែរ អាចទទួលយកព័ត៌មានពីខ្មោចព្រាយបីសាចបាន ( LECLERE, les Codes Cambodgiens, vol 2, Paris, Ersnerst Leroux, 1898, p.41 )។

[២៩] ពុទ្ធិបដិមាករ គ្រឿងរបៀន ( កន្សែងយ័ន្ត ខ្សែកថា ) ប្រទាលមានមហិទ្ធីឫទ្ធិ។

[៣០] ក្នុងករណីមួយ បុរសម្នាក់ដែលត្រូវបានគេរាយការណ៍អះអាងថាជាធ្មប់ បានយកដៃរបស់គាត់ដាក់លើប្រដាប់ភេទរបស់បុរសម្នាក់ផ្សេងទៀត ហើយបុរសម្នាក់នោះ ក៏បានទទួលមរណៈភាពនៅថ្ងៃបន្ទាប់។ ក្នុងករណីមួយទៀត បុរសជាធ្មប់នោះ ត្រូវបានគេនិយាយថា គាត់បានប៉ះជើងរបស់ក្មេងស្រីម្នាក់។ នៅក្នុងខេត្តកំពង់ស្ពឺ ប្រជាពលរដ្ឋភាគច្រើនបានរាយការណ៍ថា ពួកគេបានទទួលដំណឹងថាជនដែលត្រូវបានគេអះអាងថាជាធ្មប់ បានធ្វើសាច់ជ្រូកដាក់ក្នុងចានឲ្យក្លាយទៅជាដង្កូវរស់រវើក។ រឿងរ៉ាវនេះត្រូវបានគេនិយាយប្រាប់តៗគ្នា ហើយវាជារឿងរ៉ាវត្រូវបានគេបំភ្លៃគ្រប់ពេលវេលា។

[៣១] នៅក្នុងខេត្តកំពង់ចាម ជីវិតរស់នៅរបស់ជន ដែលគេអះអាងថាជាអាប/ធ្មប់ ជួបការលំបាក។ អស់រយៈពេលជាច្រើនឆ្នាំ ប្រជាពលរដ្ឋ មិនចង់អង្គុយនៅជិត ឬនិយាយរកបុគ្គលនោះទេ ពីព្រោះពួកគេខ្លាចគាត់អាចដាក់អំពើលើពួកគេ។ នៅក្នុងស្រុកកណ្តៀង ខេត្តពោធិសាត់ ស្ត្រីម្នាក់បានប្រាប់ពួកយើងថា ចាប់តាំងពីគាត់នៅវ័យជាកុមារភាព ប្រជាពលរដ្ឋបាននិយាយថា ម្តាយរបស់គាត់គឺជាអាប ដែលបណ្តាលឲ្យស្ត្រីនេះទទួលរងនូវការឈឺចាប់ខាងផ្លូវចិត្ត។

*នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៤ នៅខេត្តកំពង់ស្ពឺ ប្រជាពលរដ្ឋមួយក្រុមចំនួន៦០០នាក់ ប្រដាប់ដោយដំបងឈើ និងដុំថ្ម បានមកដល់ផ្ទះរបស់ចេក ដោយចោទប្រកាន់គាត់អំពីអំពើអាបធ្មប់។ គាត់បានស្លាប់ក្រោយពីការរងរបួសជាច្រើនកន្លែង បន្ទាប់ពីទទួលរងការគប់ដោយដុំថ្ម និងការវាយតប់រួចមក។ ចេក គឺជាគ្រូខ្មែរ។ តាមដឹង គាត់បានព្យាយាមរកអតិថិជនថ្មីៗ ដោយនិយាយប្រាប់អ្នកដែលធ្លាក់ខ្លួនឈឺថា ប្រសិនបើ ពួកគេមិនមកជួបគាត់ សម្រាប់ទទួលការព្យាបាលសមរម្យទេ ពួកគេនឹងស្លាប់ឆាប់ៗ។ មនុស្សមួយចំនួន បានស្លាប់ដោយសារជម្ងឺ ដែលនគរបាល និងប្រជាពលរដ្ឋអ្នកចេះដឹងបានរៀបរាប់ថា ជាជម្ងឺអេដស៍ មហារីក ឬ ទឹកនោមផ្អែម។ ប៉ុន្តែ សម្រាប់ប្រជាពលរដ្ឋសាមញ្ញក្នុងភូមិ ក៏ដូចជាប្រជាពលរដ្ឋតាមភូមិជុំវិញ យល់ថាប្រជាពលរដ្ឋទាំងនេះបានស្លាប់ដោយសារបណ្តាសាររបស់ចេក។ ដោយសារប្រជាពលរដ្ឋមួយចំនួនបានស្លាប់កាលពី២ ឬ ៣ ខែមុនវិញ អ្នកភូមិបានចាប់ផ្តើមភ័យខ្លាចចេក ព្រមទាំងបានចោទគាត់ពីអំពើអាបធ្មប់។ បន្ទាប់ពីមានការសង្ស័យចំពោះការស្លាប់របស់បុរសម្នាក់ គ្រូទាយម្នាក់ បានសំដៅដោយប្រយោលទៅលើឈ្មោះចេក ថាជាអ្នកទទួលខុសត្រូវនោះ។ ព័ត៌មានត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងភូមិក្នុងរយៈពេល២ ឬ ៣ម៉ោងក្រោយមក។ ប្រជាពលរដ្ឋ ចាប់ផ្តើមគិតថា ដល់ពេលដែលត្រូវនៅឆ្ងាយពីចេក។ នៅពេលចាប់ផ្តើមនៃរសៀលមួយ មានមនុស្សម្នាយ៉ាងច្រើន បានមកជួបជុំគ្នានៅមុខផ្ទះរបស់ចេក រហូតកើនចំនួនដល់៥០០នាក់។ ចេក បាននៅក្នុងផ្ទះ ព្រោះព្រួយបារម្ភក្នុងការចេញទៅក្រៅ។ មហាជនដែលខឹងសម្បារ បានចាប់ផ្តើមចោលដុំថ្មទៅលើដំបូល និងជញ្ជាំងផ្ទះប្រក់ស្បូវរបស់គាត់។ មានមន្ត្រីនគរបាលប្រហែល១៥-២០នាក់ ពីស្រុកជុំវិញ បានមកដល់កន្លែងកើតហេតុ។ ពួកគេ បានព្យាយាមជន្លៀសចេកតាមរថយន្តរបស់គេ តែមហាជនដែលខឹងសម្បារនោះ បានបញ្ឈប់ពួកគេ។ បន្ទាប់មក ប្រជាពលរដ្ឋមួយក្រុមបានចូលក្នុងផ្ទះ ព្រមទាំងអូសចេកចេញមកក្រៅ។ ប្រជាពលរដ្ឋ បានគប់ដុំថ្ម វាយ ទាត់ធាក់គាត់រហូតដល់គាត់ស្លាប់។ មន្ត្រីនគរបាល បានបើកការស៊ើបអង្កេតមួយ ហើយព្រះរាជអាជ្ញាមកពីសាលាដំបូងខេត្តតាកែវ បានចេញដីកាចាប់ខ្លួនបុរស១១ នាក់។ មានតែជនសង្ស័យម្នាក់ប៉ុណ្ណោះ ត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានដោះលែងវិញ តាមដីកាតុលាការ។ ជនសង្ស័យនៅសេសសល់ ត្រូវបានរាយការណ៍ថាបានរត់គេចខ្លួន និង មិនត្រូវបានគេចាប់ខ្លួនឡើយ។ (ប្រភព៖ បទសម្ភាសន៍ធ្វើឡើងដោយការិយាល័យ OHCHR-កម្ពុជា)*

រហូតដល់ត្រូវគេឲ្យចាកចេញពីភូមិករ។[៣២] ក្រោយពីមានរឿងរ៉ាវ និងកំហឹងបានពុះកញ្ជ្រោលកាន់តែច្រើនឡើង ឧប្បត្តិហេតុតិចតួចបំផុតអាចនាំឲ្យផ្ទុះអំពើហិង្សាយ៉ាងរាលដាលនៅកម្រិតឃុំ សង្កាត់។

ជនល្មើសទាំងឡាយអាចជាហ្វូងមហាជន (ហ្វូងមនុស្ស) ដែលមានភូមិទាំងមូល ឬក្នុងករណីនៃអំពើឃាតកម្មគ្រោងទុកជាមុន មនុស្សមួយក្រុមតូច ដែលជាញឹកញាប់ត្រូវជាសាច់ញាតិជនរងគ្រោះ។ការសម្លាប់មនុស្សដែលត្រូវបានចោទថាជាអ្នកធ្វើអំពើអាបធ្មប់ ជាធម្មតាត្រូវបានប្រព្រឹត្តដោយប្រើដំបង កាំបិតខ្មែរ ឬកាំបិតផ្គាក់ ឬកាំភ្លើង។ តាមសេចក្តីរាយការណ៍ ស្ត្រីក៏ជាអ្នកចូលរួមផងដែរ។ គេរកឃើញជនរងគ្រោះមួយចំនួន ត្រូវបានគេសម្លាប់កាត់ក្បាល។ ប្រជាពលរដ្ឋខ្លះលើកអំណះអំណាងថា ការសម្លាប់កាត់ក្បាលគឺជាវិធានការមួយ ដើម្បីបង្ការមិនឲ្យមន្ត្រីនគរបាលរកឃើញជនល្មើស ពីព្រោះពួកគេជឿថារូបភាពរបស់ជន

[៣២] ករណីជាច្រើននៃជនដែលគេអះអាងថាជាអាប/ធ្មប់ ដែលគេបណ្តេញចេញពីភូមិករ ត្រូវគេរាយការណ៍មកថា បានកើតឡើងក្នុងខេត្តរតនគិរី។ នៅឆ្នាំ២០១៣ និងឆ្នាំ២០១៥ ជនជាតិដើមភាគតិចចារ៉ាយចំនួន ២ នាក់បានរត់ចេញពីភូមិរបស់ពួកគេ ដោយមានការភ័យខ្លាចចំពោះអាយុជីវិតរបស់ពួកគេ។

ដែលបានសម្លាប់អាបធ្មប់ ត្រូវបានផ្ដិតជាប់ក្នុងប្រស្រីភ្នែករបស់សាកសព។

## ៤.២.៣. មូលហេតុនាំឲ្យមានការចោទប្រកាន់ពីអំពើអាបធ្មប់ និងការធ្វើទុក្ខបុកម្នេញ

ជាទូទៅ អំពើហិង្សាទាក់ទងនឹងអាបធ្មប់ មាននិន្នាការជាអំពើគ្រោងទុកជាមុន ហើយផ្ដោតលើជនងាយរងគ្រោះ និងជនរងគ្រោះបំផុតនៅក្នុងសហគមន៍ រួមទាំងជនពិការរាងកាយ ឬ ស្មារតី។

ជារឿយៗអ្នកផ្ដល់កិច្ចសម្ភាសន៍ បានរៀបរាប់បុគ្គលដែលត្រូវបានចាត់ទុកជាអាបធ្មប់ ថាមានអាកប្បកិរិយាខុសប្លែក ឬមានអត្តចរិតខុសប្លែកពីគេ (ធ្វើអ្វីប្លែកៗ)។ អាកប្បកិរិយា ឬអត្តចរិតខុសប្លែក ត្រូវបានបង្ហាញតាមរយៈពាក្យសំដីរបស់ពួកគេ ឬតាមរបៀបបរិភោគអាហារហើយ និងតាមរបៀបដើរហើរ។[៣៣] តាមសេចក្ដីរាយការណ៍ ជាធម្មតា ពួកគេពុំមានទំនាក់ទំនងល្អក្នុងសង្គមជាមួយមនុស្សដទៃឡើយ។ ពួកគេមួយចំនួន ត្រូវបានគេពិពណ៌នាថា ជាអ្នកមាន "អារម្មណ៍ឆេវឆាវ" "ជេរប្រទេចអ្នកដទៃ" ឬ "គំរាមកំហែងពួកគេ" (នៅពេលស្រវឹងស្រា) និងមានបំណងរស់នៅដាច់ដោយឡែកពីគេឯង។ រីឯពួកគេមួយចំនួនផ្សេងទៀតមានអារម្មណ៍ស្ងប់ស្ងាត់ជាង ប៉ុន្តែពួកគេ "មិនសំឡឹងភ្នែកត្រង់ឆ្ពោះទៅមុខទេ" "មានភ្នែកទាំងគូពណ៌ក្រហម" ឬ "មិនអាចបែរមុខចំពន្លឺព្រះអាទិត្យឡើយ"។ ចំណែកឯពួកជាច្រើនទៀត មានពិការភាពពីកំណើត ឬមានសញ្ញាសម្គាល់ពិសេស (ខ្មៅ/ផ្លូក) ដែលជាប្រពៃណីបង្ហាញពីលទ្ធផលនៃបាបកម្ម ដោយសារសកម្មភាពអាក្រក់ដែលបានសាងឡើងនៅក្នុងអតីតជាតិ (ឧទាះ ជនដែលត្រូវបានគេអះអាងថាជាធ្មប់ ឬអាបម្នាក់ គឺជាមនុស្សគមខ្នង ជនដែលកើតមកមានភ្នែកតែម្ខាង)។ ពួកគេមួយចំនួនទៀត មានលក្ខណៈពិសេសខាងរាងកាយ ដែលអាចផ្សារភ្ជាប់នឹងជំនឿអរូបី (ឧទាះ ជនដែលត្រូវបានគេអះអាងថាជាធ្មប់ ឬអាបម្នាក់ មានសក់កណ្ដាញ់នៅពីក្រោយក្បាលរបស់គាត់)។

លើសពីនេះទៀត វាក៏អាចជាបញ្ហានៃការរំពឹងទុកនៃការប្រកាន់ខ្ជាប់ ទៅនឹងបទដ្ឋានវប្បធម៌មួយចំនួនផងដែរ។ សញ្ញាមួយដែលបង្ហាញថា បុគ្គលម្នាក់អាចចាត់ទុកជាអាបធ្មប់បាន គឺដោយសារអវត្តមានរបស់គេក្នុងពិធីបុណ្យព្រះពុទ្ធសាសនា ដែលទំនងជាដោយសារពួកគេ មិនអាចចូលរួមក្នុងតំបន់ស័ក្ដិសិទ្ធក្នុងវត្តបាន ដោយសារតែថាមពលអាក្រក់របស់គេត្រូវប្រឈមនឹងបារមី ដែលស្ថិតនៅទីនោះ។ ជួនកាលមានការរាយការណ៍មកថា មានភ្លើងចំលែកហោះជុំវិញផ្ទះរបស់គេ។[៣៤] ក្នុងករណីភាគច្រើនដែលត្រូវបានគេស៊ើបអង្កេត អាបធ្មប់ដែលត្រូវបានគេចោទប្រកាន់បានកើតនៅភូមិផ្សេងមួយទៀត។

ការចោទប្រកាន់អំពីអំពើអាបធ្មប់ គឺផ្ដោតលើជនទាំងឡាយណា ដែលដើរគ្មានទិសដៅតាមផ្លូវដែលមនុស្សតែងតែដើរញឹកញាប់។[៣៥] ការផ្លាស់ប្ដូរក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់ អាចបង្កើតឱ្យមានការច្រណែន និង/ឬត្រូវបានចាត់ទុកថាជាការរំខានដែលមានលក្ខណៈគ្រោះថ្នាក់ជាសក្ដានុពលដល់អ្នកភូមិ។ ជាប្រពៃណី ការគោរពបទដ្ឋានសង្គម និងការរក្សាភាពស្ងៀមស្ងាត់ គឺមានតម្លៃច្រើនជាងការអភិវឌ្ឍគំនិតថ្មីៗ ដែលអាចរំខានដល់ស្ថេរភាពសង្គម។

បន្ថែមពីលើការរើសអើង និងការរំពឹងទុកស្ដីពីអនុលោមភាពទៅតាមបទដ្ឋានវប្បធម៌ ការស្រាវជ្រាវមួយបានចង្អុលបង្ហាញឲ្យឃើញនូវកត្តាផ្សេងៗទៀតដែលទាក់ទងគ្នាជាមួយនឹងហេតុផលនានាដែលជា

33 ពួកគេនិយាយមានសម្លេងខុសប្លែក មានន័យថាពួកគេអាចមានដើមកំណើតមកពីទីកន្លែងផ្សេង ឬតួអង្គអធិធម្មជាតិចូលសណ្ឋិតរូបពួកគេ។ ពួកគេខ្លះត្រូវបានរាយការណ៍មកថាហុតឈាមស្រស់។

៣៤ ពន្លឺនៅតាមដើមឈើធំៗ នៅពេលយប់បង្ហាញពីវត្តមានរបស់ព្រលឹងខ្មោច។

៣៥ ប្រភព៖ បទសម្ភាសន៍របស់ការិយាល័យ OHCHR កម្ពុជា

បច្ច័យជំរុញឱ្យកើតមានអំពើនៃការកាត់ទោសដោយមហាជនដោយបើកចំហរ ដូចបានរៀបរាប់នៅផ្នែកមុន។ កត្តាទី១ អ្នកសម្ភាសន៍បានគូសបញ្ជាក់ការពិតថា ប្រព័ន្ធយុត្តិធម៌នៅតែខ្វះខាតធនធាន ខាងហិរញ្ញវត្ថុ និងមនុស្ស ដើម្បីការពារមនុស្ស ដែលជំរុញឲ្យពួកគេស្វែងរកយុត្តិធម៌សម្រាប់ខ្លួនឯង។ កត្តាទី២ ការអប់រំផ្នែកសិទ្ធិមនុស្សនៅមានកម្រិតទាប មានន័យថាជនល្មើស មិនបានចោទសួរពីទង្វើរបស់ពួកគេ ទោះបីជាពួកគេនាំឱ្យមានការរើសអើង និងការផាត់ចេញពីសង្គមក៏ដោយ។

បញ្ហានេះក៏អាចផ្សារភ្ជាប់ទៅនឹងភាពក្រីក្រ និងការផាត់ចេញពីសង្គមផងដែរ។ ករណីជាច្រើនបានកើតមានឡើង នៅតាមទីតាំងភូមិសាស្ត្រជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមមានកំរិតទាប ឬ ជាតំបន់ដែលពិបាកក្នុងការចូលទៅដល់ទីកន្លែង។ឧទាហរណ៍មានករណីមួយចំនួនធំនៅតាមបណ្តាស្រុកមួយចំនួនក្នុងខេត្តតាកែវ កំពង់ស្ពឺ និងពោធិ៍សាត់ ដែលនៅតែមានការពិបាកក្នុងការចូលទៅដល់កន្លែងកើតហេតុទាំងនោះ។ នៅតំបន់ដាច់ស្រយាលទាំងនេះ អត្រានៃភាពក្រីក្រនៅមានកម្រិតខ្ពស់នៅឡើយ។ យោងទៅតាមអ្នកស្រាវជ្រាវជនជាតិអាឡឺម៉ង់២នាក់ ការលំបាកផ្នែកសេដ្ឋកិច្ច ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមាញ់អាបធ្មប់។ ពួកគេបានសង្កេតឃើញថា នៅទូទាំងពិភពលោក ការចោទប្រកាន់ពីមនុស្សមួយក្រុម ទៅលើមនុស្សម្នាក់ផ្សេងទៀតថាជាអាបធ្មប់ ជាហេតុនាំឲ្យឈានដល់ការកាប់សម្លាប់ និងកើនឡើងនូវបញ្ហាសេដ្ឋកិច្ច។[៣៦] លើសពីនេះទៅទៀត អត្រាចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យនៅមានកម្រិតទាប ដោយមាន ៥៥.៧% បានចុះឈ្មោះចូលរៀននៅថ្នាក់ក្រោមអនុវិទ្យាល័យ និង២៥.១% បានចុះឈ្មោះចូលរៀននៅថ្នាក់លើអនុវិទ្យាល័យ។[៣៧] អស់រយៈពេលជាច្រើនឆ្នាំ ប្រជាជននៅតាមភូមិទាំងនេះ ខ្វះផ្លូវថ្នល់ សាលារៀន និងមណ្ឌលសុខភាព។ អត្រានៃការសេពគ្រឿងស្រវឹងហាក់ដូចជាមានកម្រិតខ្ពស់នៅក្នុងតំបន់ទាំងនេះ។

## ៥. កាតព្វកិច្ចរបស់រដ្ឋដើម្បីបង្ការ និងការពារប្រឆាំងនឹង "ការកាត់ទោសដោយមហាជន"

ផ្នែកមុន បានបង្ហាញពីរបៀបដែលអំពើនៃ "ការកាត់ទោសដោយមហាជន" ដែលជាលទ្ធផលនៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ឬ អាបធ្មប់ អាចលើកឡើងជាកង្វល់ចំពោះសិទ្ធិមនុស្ស។ "ការកាត់ទោសដោយមហាជន" គឺជាអំពើមួយដែលនាំឲ្យឈានដល់ការសម្លាប់ ដែលរំលោភលើសិទ្ធិរស់រានមានជីវិត ប្រសិនបើ រដ្ឋមិនបានធ្វើសកម្មភាពដើម្បីទប់ស្កាត់ ឬ ផ្តល់សំណងសមរម្យនោះទេ។ អំពើនៃ"ការកាត់ទោសដោយមហាជន" បានប៉ះពាល់ដល់សិទ្ធិដទៃទៀត រួមទាំងសិទ្ធិរួចផុតពីទារុណកម្មនិងប្រព្រឹត្តិកម្មមិនគម្បី។ រដ្ឋ មានកាតព្វកិច្ចការពារបុគ្គលគ្រប់រូបប្រឆាំងនឹងប្រព្រឹត្តិកម្មបែបនេះ "ទោះបីប្រព្រឹត្តដោយបុគ្គលដែលធ្វើសកម្មភាពក្នុងសមត្ថភាពជាផ្លូវការ ឬ ក្រៅផ្លូវការ ឬ ក្នុងលក្ខណៈឯកជនក៏ដោយ"។[៣៨]

[៣៦] ការបោះពុម្ពផ្សាយរបស់ Baten, Jörg, and Ulrich Woitek, (2001)៖ “កត្តាកំណត់សេដ្ឋកិច្ចពាក់ព័ន្ធនឹងការប្រមាញ់អាបធ្មប់”។ Baumes, Jeff, Mark Goldberg, Malik Magdon-Ismail, and William Al Wallace. 2004.

[៣៧] ស្ថិតិ និង សូចនាករអប់រំសាធារណៈឆ្នាំ ២០១៥-២០១៦។ ក្រសួងអប់រំ យុវជន និង កីឡា។ ខែ មីនា ឆ្នាំ ២០១៧ ទំព័រ ៤១។

[៣៨] សេចក្តីពន្យល់ទូទៅលេខ ២០ (ឆ្នាំ ២០០៧) ត្រង់មាត្រា ៧ (ការហាមឃាត់ការធ្វើទារុណកម្ម ឬ ប្រព្រឹត្តកម្ម ឬ ការដាក់ទណ្ឌកម្មដទៃទៀត

ទង្វើរបស់សមាជិកនៃក្រុមណាមួយ ដែលយកយុត្តិធម៌មកគ្រប់គ្រងក្នុងដៃរបស់គេផ្ទាល់គឺរំលោភលើសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលត្រូវបានបង្កើតឡើងដោយច្បាប់ សមភាពនៅចំពោះមុខច្បាប់ និងចំពោះមុខតុលាការ និងសាលាក្តី និងការសន្មត់ជាមុនថាគ្មានទោស។ អ្វីដែលសំខាន់បំផុត គឺការសន្មត់ជាមុនថាគ្មានទោស "តម្រូវថាអយ្យការ ត្រូវមានបន្ទុកក្នុងការបង្ហាញភស្តុតាងចំពោះបទចោទប្រកាន់ធានាថាគ្មានទោសណាអាចត្រូវបានសន្មត់ជាមុននោះទេ រហូតទាល់តែបទចោទប្រកាន់នោះត្រូវបានបង្ហាញឱ្យលើសពីវិមតិសង្ស័យ ព្រមទាំងធានាថា ក្នុងករណីវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ"។[៣៩]

លើសពីនេះទៀត ការចោទប្រកាន់ និងការធ្វើទុក្ខបុកម្នេញមកលើអាបធ្មប់ បង្ហាញអំពីក្តីព្រួយបារម្ភនៃការរើសអើង ការជ្រើសរើសអ្នកទាំងឡាយណាដែលមានលក្ខណៈ "ខុសពីគេ" ដោយសារតែខ្លាច ឬ មិនចូលចិត្ត។[៤០] អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ ឬ សម្លាប់ភ្លាមៗ ឬ តាមទំនើងចិត្ត បានរាយការណ៍ថា ជាញឹកញាប់ ការឆ្លើយតបចំពោះអំពើអាបធ្មប់នៅក្នុងប្រទេសជាច្រើន ពាក់ព័ន្ធនឹងទម្រង់នៃការរើសអើងយ៉ាងធ្ងន់ធ្ងរ និងជាប្រព័ន្ធ ជាពិសេសឈរលើមូលដ្ឋានយេនឌ័អាយុ និងពិការភាព។[៤១]

ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ គ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរដទៃទៀតរួមទាំងអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ត្រូវតែមិនត្រឹមតែរារាំងពីការប្រព្រឹត្តអំពើរំលោភសិទ្ធិទាំងនេះទេ ប៉ុន្តែថែមទាំងអនុម័តវិធានការនានាដូចជាវិធានការខាងនីតិប្បញ្ញត្តិ តុលាការ រដ្ឋបាល អប់រំ និងវិស័យដទៃទៀត ដើម្បីការពារ និងបំពេញសិទ្ធិមនុស្សទាំងនេះ។[៤២]

កាតព្វកិច្ចទាំងនេះលាតសន្ធឹងលើអំពើទាំងឡាយរាប់ទាំងអំពើនៃ "ការកាត់ទោសដោយមហាជន" ដែលត្រូវបានប្រព្រឹត្តដោយតួអង្គមិនមែនរដ្ឋ ដូចជាបុគ្គលដែលប្រតិកម្មទៅនឹងបទល្មើសព្រហ្មទណ្ឌដែលអាចកើតមានឡើង ឬធ្វើទុក្ខបុកម្នេញលើនរណាម្នាក់ដែលត្រូវបានចោទពីអំពើអាបធ្មប់។ ក្នុងស្ថានភាពនានាដែលរាជរដ្ឋាភិបាលអនុញ្ញាត ឬ ខកខានក្នុងការចាត់វិធានការសមស្រប ឬអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់ដើម្បីបង្ការ ការដាក់ទណ្ឌកម្ម ការស៊ើបអង្កេត ឬការដោះស្រាយបញ្ហាហានិភ័យដែលបង្កឡើងដោយបុគ្គល ឬអង្គភាពឯកជន នោះអាចជាការនាំឲ្យរំលោភសិទ្ធិមនុស្ស។[៤៣] ការបរាជ័យបែបនេះក៏អាចបណ្តាលឱ្យមាននិទណ្ឌភាពផងដែរ ព្រោះជនល្មើសនៃការរំលោភសិទ្ធិមនុស្សមិនត្រូវបានយកមកឲ្យទទួលខុសត្រូវ ព្រមទាំងក៏ខកខានផ្តល់សំណងដល់ជនរងគ្រោះផងដែរ។[៤៤] ជាក់ស្តែងនិទណ្ឌភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សក៏ជាធាតុផ្សំដ៏សំខាន់ ចំពោះការកើតឡើងនូវការរំលោភបំពានផ្សេងៗផងដែរ។[៤៥]

ដែលហៅឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប) CCPR/C/GC/20 កថាខ័ណ្ឌ២។

៣៩ សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ (២០០៧) ត្រង់មាត្រា ១៤៖ សិទ្ធិទទួលបានសមភាព នៅចំពោះមុខតុលាការនិងសាលាក្តី និង ការទទួលបានការកាត់ក្តីដោយយុត្តិធម៌ CCPR/C/GC/32 កថាខ័ណ្ឌ ៣០។

៤០ សូមមើលត្រង់ផ្នែក ៣.១.៣។ ហេតុផលនានាដែលនាំឱ្យមានការចោទប្រកាន់ និង ការធ្វើទុក្ខបុកម្នេញមកលើអំពើអាបធ្មប់។

៤១ A/HRC/11/2 កថាខ័ណ្ឌ ៥១។

៤២ សេចក្តីពន្យល់ទូទៅលេខ ៣១ (៨០) ស្តីពីប្រភេទនៃកាតព្វកិច្ចផ្លូវច្បាប់ ដែលត្រូវបានដាក់លើរដ្ឋភាគី ចំពោះកតិកាសញ្ញា CCPR/C/21/Rev.1/Add.13 កថាខ័ណ្ឌ ៧។

៤៣ សេចក្តីពន្យល់ទូទៅលេខ ៣១ (៨០) កថាខ័ណ្ឌ ៨។

៤៤ បានធ្វើបច្ចុប្បន្នភាពនូវគោលការណ៍សម្រាប់ការពារ និង ការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈវិធានការ ដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព E/CN.4/2005/102/Add.1 កថាខ័ណ្ឌ ៦។

៤៥ សេចក្តីពន្យល់ទូទៅលេខ ៣១ (៨០) កថាខ័ណ្ឌ ១៥ និង ១៨។

លើសពីនេះទៀត ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ចែងពីក្របខ័ណ្ឌដូចខាងក្រោម ដើម្បីស្វែងយល់ពីកាតព្វកិច្ចរបស់រដ្ឋនៅក្នុងវិស័យនេះ។

ទី១ រដ្ឋត្រូវតែអនុម័តក្របខ័ណ្ឌច្បាប់ការពារ រួមទាំង ការហាមឃាត់បទល្មើសព្រហ្មទណ្ឌដែលមានប្រសិទ្ធិភាពលើគ្រប់រូបភាពនៃអំពើហិង្សា ឬញុះញង់ឱ្យមានអំពើហិង្សាដែលទំនងជានាំឱ្យមានការដកហូតយកជីវិត[៤៦] ឬអាចនាំឱ្យមានទារុណកម្ម ឬការប្រព្រឹត្តិកម្មមិនគប្បី។ ការការពារផ្នែកច្បាប់ ត្រូវតែអនុវត្តដូចគ្នាចំពោះបុគ្គលទាំងអស់ និងផ្តល់ការធានាប្រកបដោយប្រសិទ្ធភាពប្រឆាំង នឹងរាល់ទម្រង់នៃការរើសអើង។[៤៧] ក្របខ័ណ្ឌបែបនេះ ត្រូវចាត់វិធានការការពារពិសេសសម្រាប់បុគ្គល ដែលស្ថិតក្នុងស្ថានភាពដែលងាយរងគ្រោះ ដែលជីវិតរបស់គេប្រឈមនឹងហានិភ័យពិសេសរួមទាំងអ្នកដែលសង្ស័យថាជាអាបធ្មប់។[៤៨] ក្របខ័ណ្ឌច្បាប់ ក៏ត្រូវបង្កើតឱ្យមានផងដែរនូវតុលាការដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ដែលលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសាធារណៈ និងការសន្មត់ជាមុនថាគ្មានទោស។

ទី២ រដ្ឋ ក៏ត្រូវអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់ដើម្បីបង្ការអំពើនៃ "ការកាត់ទោសដោយមហាជន" ពីការកើតមានឡើង ហើយក្នុងការអនុវត្តដូច្នោះ ដើម្បីការពារជីវិតរបស់បុគ្គលពី ការដកហូតជីវិត ដែលបណ្តាលមកពីទង្វើរបស់បុគ្គលដែលមិនទាក់ទងទៅនឹងរដ្ឋ។[៤៩] វិធីមួយ គឺតាមរយៈការលើកកំពស់ការយល់ដឹងរបស់សាធារណៈជននៅថ្នាក់មូលដ្ឋានស្តីពីគោលការណ៍សិទ្ធិមនុស្ស និងនីតិរដ្ឋ ជាពិសេស អំពើខុសច្បាប់នៃការកាត់ទោសដោយមហាជន ព្រមទាំងសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងការសន្មត់ជាមុនថាគ្មានទោស។

ទី៣ កាលណាវិធានការបង្ការដើម្បីបញ្ឈប់ "ការកាត់ទោសដោយមហាជន" មិនទទួលបានជោគជ័យទេនោះ រដ្ឋត្រូវតែធ្វើការស៊ើបអង្កេត និងចោទប្រកាន់ក្នុងករណី ដែលអាចនាំអោយមានការដកហូតជីវិតដោយខុសច្បាប់ ទារុណកម្ម ឬប្រព្រឹត្តិកម្មមិនត្រឹមត្រូវ។ វិធានការទាំងនេះ ត្រូវតែមានគោលបំណងក្នុងការធានាថា អ្នកទាំងឡាយដែលទទួលខុសត្រូវនោះ ត្រូវបាននាំយកមកកាត់ទោសក្នុងការលើកកម្ពស់គណនេយ្យភាព ការបង្ការនិទណ្ឌភាព និងការចៀសវាងការបដិសេធយុត្តិធម៌ និងចងក្រងជាបទពិសោធន៍ដើម្បីជៀសវាងការរំលោភបំពានម្តងហើយម្តងទៀត។[៥០] ការស៊ើបអង្កេត ត្រូវតែធ្វើឡើងដោយ "ឯករាជ្យ មិនលំអៀងទាន់ពេល ហ្មត់ចត់ មានប្រសិទ្ធភាព គួរអោយទុកចិត្តបាន និងមានតម្លាភាព..."[៥១]។

ជាចុងក្រោយ រដ្ឋ ត្រូវផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធិភាព ដល់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្ស។ ដំណោះស្រាយ គួរតែត្រូវបានកែសម្រួល ដើម្បីពិចារណាអំពីភាពងាយរងគ្រោះនៃប្រភេទបុគ្គលជាក់លាក់មួយចំនួន។ ដំណោះស្រាយអាចរួមបញ្ចូលទាំងការជួសជុលសំណង ការស្តារនីតិសម្បទា និងវិធានការនៃការពេញចិត្ត ដូចជាការធានាមិនឲ្យមានការប្រព្រឹត្តច្រំដែលៗ និងការផ្លាស់ប្តូរ

[៤៦] សេចក្តីពន្យល់ទូទៅលេខ ៣៦ ត្រង់មាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ព្រមទាំងសិទ្ធិរស់រានមានជីវិត CCPR/C/GC/36 កថាខ័ណ្ឌ ២០។

[៤៧] សេចក្តីពន្យល់ទូទៅលេខ ៣៦ កថាខ័ណ្ឌ ៦១។

[៤៨] សេចក្តីពន្យល់ទូទៅលេខ ៣៦ កថាខ័ណ្ឌ ២៣។

[៤៩] សេចក្តីពន្យល់ទូទៅលេខ ៣៦ កថាខ័ណ្ឌ ៧។

[៥០] សេចក្តីពន្យល់ទូទៅលេខ ៣៦ កថាខ័ណ្ឌ ២៧។

[៥១] សេចក្តីពន្យល់ទូទៅលេខ ៣៦ កថាខ័ណ្ឌ ២៧។

ច្បាប់ និងការអនុវត្តពាក់ព័ន្ធ និងការនាំខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់។[៥២]

# ៦. ការឆ្លើយតបដោយអាជ្ញាធរពាក់ព័ន្ធ

## ៦.១ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ការពារនៅកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជារួមមានជំពូកមួយ ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ដែលទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់។[៥៣] រដ្ឋធម្មនុញ្ញនេះ ទទួលស្គាល់ ជាពិសេស សិទ្ធិជាក់លាក់ ដូចជាសមភាពនៅចំពោះមុខច្បាប់ ការហាមប្រាមមិនឲ្យមានការរើសអើង សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខ ការហាមប្រាមមិនឲ្យមានការរំលោភបំពានលើរាងកាយលើបុគ្គលណាមួយ សិទ្ធិក្នុងការសន្មត់ជាមុនថាគ្មានទោស និងសិទ្ធិការពារក្តីតាមផ្លូវច្បាប់។ ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងបន្ថែមទៀតនូវសិទ្ធិជាច្រើនទាក់ទងនឹងដំណើរការនីតិវិធីត្រឹមត្រូវ។ ក្រមព្រហ្មទណ្ឌរួមបញ្ចូលបទល្មើសព្រហ្មទណ្ឌទាំងអស់ ដែលពាក់ព័ន្ធនឹងអំពើនៃការកាត់ទោសដោយមហាជន ដែលរួមមានមនុស្សឃាត ទារុណកម្ម និងអំពើឃោរឃៅ អំពើហិង្សាដោយចេតនា និងការគំរាមកំហែង ទោះបីជាអំពើទាំងនេះមិនស្របតាមស្តង់ដារអន្តរជាតិទាំងស្រុងក៏ដោយ (ឧ.បទឧក្រិដ្ឋស្តីពីទារុណកម្ម)។ ក្រមនេះក៏កំណត់និយមន័យផងដែរ អំពីជនល្មើសជាចារី សហចារី អ្នកផ្តើមគំនិត និងជនសមគំនិតនៃបទល្មើសព្រហ្មទណ្ឌ។ ថ្វីបើ មានការការពារពីរដ្ឋធម្មនុញ្ញមិនឲ្យមានការរើសអើង និងបទប្បញ្ញត្តិមួយចំនួននៅក្នុងក្រមព្រហ្មទណ្ឌ ដែលហាមឃាត់ការរើសអើងក៏ដោយ ក៏មិនមានច្បាប់ប្រឆាំងនឹងការរើសអើងគ្រប់ជ្រុងជ្រោយនៅក្នុងប្រទេសកម្ពុជាដែរ។

*ហាន ហាវ៉ា អាយុ៥០ឆ្នាំ ភេទស្រី ត្រូវបានចោទពីការប្រព្រឹត្តអំពើអាបធ្មប់ អស់រយៈពេលជាច្រើនឆ្នាំ នៅខេត្តពោធិ៍សាត់។ ស្ថានភាពកាន់តែអាក្រក់ នៅឆ្នាំ២០១៥ នៅពេលដែលមនុស្ស៥នាក់មកពីភូមិសៀនជ័យបានស្លាប់ ដោយសារអ្វីដែលគេហៅថា ជម្ងឺទាចទឹក។ គ្រូម្នាក់បាននិយាយថា ហាន បានដាក់បណ្តាសារពួកគេ។ នារាត្រីមួយ នៅម៉ោង១១.៣០យប់ មានបុរស២ទៅ៣នាក់បានព្យាយាមទំលាយទ្វារផ្ទះរបស់ហានដើម្បីសម្លាប់គាត់។ ក្រោយពីការប៉ុនប៉ងនេះ កូនស្រីរបស់ហាន បានដាក់ពាក្យបណ្តឹងទៅមេប៉ុស្តិ៍នគរបាល មេភូមិ និងអធិការដ្ឋាននគរបាលស្រុក។ នៅខែវិច្ឆិកា ឆ្នាំ២០១៥ មេភូមិបានរៀបចំពិធីសម្បថ ដោយអញ្ជើញហាន និងអ្នកភូមិចូលរួម។ យោងតាមមេភូមិ ស្ថានភាពបានស្ងប់ស្ងាត់វិញ បន្ទាប់ពីហានបានស្បថថាគាត់មិនមែនជាអាបធ្មប់នោះទេ។ ហាន បានសម្រេចចិត្តចាកចេញពីភូមិស្ងាត់ៗ។ តាមកូនស្រីរបស់គាត់ ឥឡូវនេះ គាត់កំពុងតែធ្វើការនៅក្នុងចំការម្រេចមួយ នៅខេត្តរតនគិរី។ បុរស៣នាក់ ដែលព្យាយាមទំលាយទ្វារផ្ទះរបស់ហានមិនត្រូវបានកោះហៅដោយនគរបាលឡើយ (ប្រភព៖ បទសម្ភាសន៍ដោយការិយាល័យ OHCHR កម្ពុជា)*

[៥២] សេចក្តីពន្យល់ទូទៅលេខ ៣១ (៨០) ស្តីពីប្រភេទនៃកាតព្វកិច្ចផ្លូវច្បាប់ ដែលត្រូវបានដាក់លើរដ្ឋភាគី ចំពោះកតិកាសញ្ញា CCPR/C/21/Rev.1/Add.13 កថាខ័ណ្ឌ ១៦។

[៥៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក III។

គោលបំណងជាយុទ្ធសាស្ត្រមួយនៃគោលបំណងជាយុទ្ធសាស្ត្រ៤ នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤ គឺពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នសាធារណៈ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាការបំរើសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដោយមានគោលបំណងបំរើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង។[៥៤] ចំណុចសំខាន់នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ គឺពន្លឿនកំណែទម្រង់អភិបាលកិច្ច ដែលជារួមមានរាប់បញ្ចូលសមធម៌ និងយុត្តិធម៌។ រាជរដ្ឋាភិបាលក៏ព្យាយាមផងដែរ ដើម្បីពង្រឹងការលើកកម្ពស់ការយល់ដឹងស្តីពីការបង្ការ និងការបង្ក្រាបសកម្មភាពពុករលួយ ការពង្រឹង និងពង្រីកការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ទាក់ទងទៅនឹងសេវាសាធារណៈ និងលិខិតុបករណ៍ច្បាប់ និងការលើកកម្ពស់ការអនុវត្តយន្តការ សម្រាប់ទទួលយកមតិឆ្លើយតប និងចាត់ចែងពាក្យបណ្តឹងពីអ្នកប្រើប្រាស់សេវាសាធារណៈ។[៥៥]លើសពីនេះទៀត រាជរដ្ឋាភិបាល ក៏ព្យាយាមលើកកម្ពស់សេវាយុត្តិធម៌ តាមរយៈការពង្រឹងប្រសិទ្ធភាពការងារ ការពង្រឹងទំនុកចិត្តសាធារណៈក្នុងប្រព័ន្ធយុត្តិធម៌ និងប្រយុទ្ធប្រឆាំងការរំលោភបំពានគ្រប់ប្រភេទទាំងអស់នៅក្នុងសង្គម។[៥៦]

វិធានការផ្សេងៗទៀត រួមមានការពង្រឹងនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ ក៏ដូចជាអនុវត្តវិធានការបង្ការ និងវិធានការផ្សេងៗទៀត ដើម្បីបង្ក្រាបសកម្មភាពឧក្រិដ្ឋគ្រប់ប្រភេទទាំងអស់។[៥៧]

ច្បាប់ជាធរមាននៅកម្ពុជា ចែងពីមូលដ្ឋានរឹងមាំមួយដើម្បីបង្ការនិទណ្ឌភាពពាក់ព័ន្ធនឹងករណីនៃ"ការកាត់ទោសដោយមហាជន"។ ទោះយ៉ាងណាក៏ដោយ នៅក្នុងការតាក់តែងរបាយការណ៍នេះ ការិយាល័យ OHCHR មិនអាចកំណត់បាននូវគោលនយោបាយជាក់លាក់ណាមួយដែលមានស្រាប់ ដើម្បីលើកឡើងជាដំណោះស្រាយទៅនឹងអំពើនៃ"ការកាត់ទោសដោយមហាជន" ឡើយក្រៅតែពីមានបទបញ្ជាដូចបានរៀបរាប់ខាងលើចេញពីក្រសួងមហាផ្ទៃដាក់ឱ្យកម្លាំងនគរបាលទាំងអស់ ធ្វើការរាយការណ៍ ស្រាវជ្រាវ និងចាប់ខ្លួនជនដៃដល់នៃអំពើទាំងនេះយកមកផ្តន្ទាទោសតាមច្បាប់។ ជាក់ស្តែង វាហាក់ដូចជាថា ការងារបង្ការដែលបំពេញដោយមន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានដទៃទៀត នៅមានកម្រិតខ្លាំងណាស់ ដោយហេតុថា ការស៊ើបអង្កេតជាបន្ទាន់ និងមានប្រសិទ្ធភាព ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មជាពិសេសនៅក្នុងករណីហឹង្សាដោយមហាជន នៅមានលក្ខណៈខ្វះចន្លោះក្នុងករណីភាគច្រើន។ កង្វះខាតនៃការបង្ការ និងកំរិតនៃនិទណ្ឌភាព ដែលជនល្មើសបានទទួល ក្លាយជាកត្តាជាច្រើនសម្រាប់ករណីនៃការកាត់ទោសដោយមហាជន ដែលនៅតែបន្តរាយការណ៍។

## ៦.២ ការបង្ការ

របាយការណ៍នេះរកឃើញថា ឧបសគ្គចម្បងៗសម្រាប់អាជ្ញាធរដើម្បីទប់ស្កាត់អំពើនៃ"ការកាត់ទោសដោយមហាជន" ហាក់ដូចជាត្រូវបានជឿជាក់យ៉ាងខ្លាំងពីទស្សនៈរបស់ជនល្មើសថា"ការកាត់ទោសដោយមហាជន" គឺមានលក្ខណៈត្រឹមត្រូវ និងស្របច្បាប់ទាំងស្រុង។ មានតែមន្ត្រីនគរបាលម្នាក់ដែលបានផ្តល់សម្ភាសន៍ប៉ុណ្ណោះ បានរាយការណ៍មកថា ប្រជាពលរដ្ឋមិនពឹងផ្អែកទៅលើសមត្ថភាពរបស់នគរបាលក្នុងការចាត់ការប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងចោរឡើយ ព្រោះពួកគេយល់ថា ច្បាប់ហាមឃាត់មិនឱ្យប្រព្រឹត្តចំពោះចោរតាមអ្វីដែលពួកគេសមនឹង

[៥៤] យុទ្ធសាស្ត្រចតុកោណ–ដំណាក់កាលទី IV ទំព័រ ១៤។
[៥៥] យុទ្ធសាស្ត្រចតុកោណ–ដំណាក់កាលទី IV ទំព័រ ២០។
[៥៦] យុទ្ធសាស្ត្រចតុកោណ–ដំណាក់កាលទី IV ទំព័រ ២១
[៥៧] យុទ្ធសាស្ត្រចតុកោណ–ដំណាក់កាលទី IV ទំព័រ ២៤។

ទទួលបាននោះទេ មានន័យថា ហាមឃាត់នូវប្រព្រឹត្តិកម្មមិនគប្បីចំពោះពួកគេ។ ក្នុងករណីបែបនេះ ជនល្មើសតែងតែគេចវេះពីអាជ្ញាធរជាដរាប។ ការស្រាវជ្រាវបានបង្ហាញថា ក្នុងករណីខ្លះ ជំនឿនេះត្រូវគេជឿជាក់យ៉ាងមុតមាំថា មន្ត្រីនគរបាលមានអារម្មណ៍ថា ត្រូវបានគំរាមកំហែងដោយមហាជន ប្រសិនបើពួកគេធ្វើអន្តរាគមន៍។ ពិតណាស់ មន្ត្រីនគរបាលមួយចំនួនបានបង្ហាញថា ពួកគេមិនបានព្យាយាមបញ្ឈប់ការសម្លាប់ដោយមហាជនឡើយ នៅពេលពួកគេមានវត្តមាននៅកន្លែងកើតហេតុនោះ ព្រោះស្ថានភាពអាចបង្កគ្រោះថ្នាក់ដល់ពួកគេផងដែរ។ ក្នុងករណីខ្លះ មន្ត្រីនគរបាលបានព្យាយាមទប់ស្កាត់អំពើហឹង្សា តែមហាជនបានតបតពួកគេវិញ។[៥៨]

លើសពីនេះទៀត ការស្រាវជ្រាវបានចង្អុលបង្ហាញថា សូម្បីតែតំណាងពីស្ថាប័ននីមួយៗរបស់អាជ្ញាធរក៏មិនបានចាត់ទុក ការកាត់ទោសដោយមហាជន ថាជាការរំលោភបំពានលើសិទ្ធិមនុស្សដែរ។ ក្នុងករណីខ្លះ ការិយាល័យ OHCHR បានពិនិត្យឃើញថា មន្ត្រីនគរបាល បានសម្តែងនូវការគាំទ្រដោយចំហរចំពោះអ្នកទាំងឡាយណា ដែលគ្រប់គ្រងយុត្តិធម៌ក្នុងដៃរបស់ពួកគេផ្ទាល់។ នៅពេលត្រូវបានសួរនាំអំពីចំណាត់ការរបស់មន្ត្រីនគរបាលនៅឆ្នាំ២០១៨ ដែលបានសម្លាប់ចោរលួចម៉ូតូម្នាក់ ប្រព្រឹត្តឡើងដោយក្រុមមហាជន មន្ត្រីនគរបាលម្នាក់បាននិយាយថា "ប្រជាពលរដ្ឋ ចង់ឲ្យគេសម្លាប់ចោរនោះចោល"។ ខ្ញុំក៏ចង់ឱ្យគេសម្លាប់ចោរនោះចោលផងដែរ។ ខ្ញុំសប្បាយចិត្តនឹងរឿងនោះ។ តើអ្នកចង់បានអ្វីថែមទៀត? "

ទស្សនៈ ជឿជាក់យ៉ាងមុតមាំក្នុងចំណោមជនល្មើសដែលថា អំពើរបស់ពួកគេ គឺជាអំពើស្របច្បាប់ ហើយក៏ត្រូវបានអនុវត្តដូចគ្នាផងដែរចំពោះបទល្មើសដែលទាក់ទងនឹងអំពើអាបធ្មប់។ នៅពេល ផ្តល់សម្ភាសន៍ មន្ត្រីនគរបាលជាច្រើនបានរាយការណ៍ថា ស្ថានភាពបែបនេះពិបាកដោះស្រាយ។ បញ្ហាចម្បងមួយដែលពួកគេប្រឈម គឺនៅពេលដែលប្រជាពលរដ្ឋសុំជំនួយពីនគរបាល ហើយបានដាក់ពាក្យបណ្តឹងចោទប្រកាន់ប្រឆាំងនឹងជនម្នាក់អំពីការធ្វើអំពើអាបធ្មប់។ ដោយសារការធ្វើអំពើអាបធ្មប់ មិនត្រូវគេបានចាត់ទុកថាជាបទល្មើសនៅក្រោមច្បាប់កម្ពុជា ដូចជាករណីកើតឡើងនៅមុនឆ្នាំ១៩៩២ នោះទេ មន្ត្រីនគរបាល មិនអាចឆ្លើយតបតាមការទាមទារជាបឋមរបស់ប្រជាពលរដ្ឋបានទេ។ ការខកខានក្នុងការប្រតិកម្មរបស់មន្ត្រីនគរបាលដែលគេបានដឹងជាទូទៅថា នេះបង្កឱ្យមានការមិនសប្បាយចិត្តដែលបញ្ឆេះកំហឹងក្នុងចំណោមប្រជាជន។ ការនេះបញ្ជាក់ឲ្យឃើញពីតម្រូវការក្នុងការលើកកម្ពស់ការយល់ដឹងកាន់តែទូលំទូលាយថែមទៀត អំពីសិទ្ធិមនុស្សក្នុងចំណោមប្រជាជន និងការគោរពកាន់តែទូលំទូលាយចំពោះគោលការណ៍និងស្ថាប័ននានានៃនីតិរដ្ឋ។

ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវក៏បានរកឃើញផងដែរថា ក្នុងករណីខ្លះ អាជ្ញាធរមានលទ្ធភាពធ្វើអន្តរាគមន៍ហើយមានឱកាសជាច្រើនមន្ត្រីនគរបាល និង អាជ្ញាធរមូលដ្ឋាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើហិង្សាបន្ថែមទៀត។ នៅពេលកម្រិតនៃកំហឹងបានឡើង ដល់កំរិតខ្ពស់ ការគំរាមកំហែង ដល់អំពើហិង្សាកាន់តែកើតមានបន្ថែមទៀត មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានបានប្រើប្រាស់ទម្លាប់អនុវត្តន៍ ការសម្រុះសម្រួលតាមបែបប្រពៃណី (Somrohsomruel) ដើម្បីធ្វើឱ្យស្ថានការណ៍ស្ងប់ស្ងាត់។ ពួកគេបានស្តាប់ភាគីទាំងសងខាង ហើយបានស្នើសុំឱ្យពួកគេជួបជុំគ្នា និងផ្តិតមេដៃលើលិខិតកិច្ច

[៥៨] មន្ត្រីនគរបាលនៅស្រុកមួយនៃខេត្តកំពង់ស្ពឺ បានរំលឹកពីករណីមួយកាលពីអតីតកាល នៅពេលដែលពួកគេបានចាប់ចោរបាន២នាក់ ហើយបញ្ជូនពួកគេទៅប៉ុស្តិ៍នគរបាល។ មានមនុស្សរាប់រយនាក់ បានប្រមូលផ្តុំគ្នានៅទីនោះ ដែលបានសុំឱ្យនគរបាលបោះបង់ចោលចោរពីរនាក់នោះ។ មន្ត្រីនគរបាល នៅតែចាក់សោរចោរ២នាក់ទុកនៅក្នុងប៉ុស្តិ៍នគរបាលដោយបដិសេធមិនព្រមបើកទ្វារឡើយ។ ក្រុមមហាជនដែលខឹងសម្បារបានព្យាយាមទំលាយទ្វារ និង ជញ្ជាំងឈើដែលផុយស្រួយ រហូតដល់រថយន្តមួយចេញពីការិយាល័យនគរបាលស្រុក បានដឹកចោរ២នាក់នោះចេញដោយសុវត្ថិភាព។

ព្រមព្រៀងមួយដែលចែងថា ភាគីទាំងពីរនឹងបញ្ឈប់សកម្មភាពរបស់ពួកគេ - អ្នកចោទប្រកាន់ត្រូវស្បថថានឹងបញ្ឈប់ការបន្តចោទប្រកាន់អំពីអាបធ្មប់ រីឯដែលជនដែលរងការចោទប្រកាន់ត្រូវស្បថថា ឈប់ប្រើពាក្យអសុរសប្រឆាំងនឹងប្រជាពលរដ្ឋ។

ប្រសិនបើវិធីនេះមិនបន្ធូរបន្ថយភាពតានតឹងទេ ជំហានគឺរៀបចំនូវពិធីស្បថ។ បុគ្គលដែលត្រូវបានចោទប្រកាន់ ថាជាអាបធ្មប់ ត្រូវបានគេសុំឲ្យស្បថថា ខ្លួនមិនមែនជាអាបធ្មប់ទេ។ ពិធីស្បថនេះ ត្រូវបានចាត់ចែងរៀបចំឡើងនៅឯប៉ុស្តិ៍នគរបាល ឬសាលាឃុំ ឬនៅចំពោះព្រះភក្ត្រពុទ្ធបដិមាករ ឬអារុក្ខអារក្ស ដូចជាអ្នកតា។ តាមប្រពៃណី ជនដែលគេចោទថាជាអាបធ្មប់អាចស្លាប់ភ្លាមៗ ឬរងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរប្រសិនបើពួកគេកុហក។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈដែលពិធីស្បថស្បែ អាចបន្ធូរបន្ថយភាពតានតឹងបានមួយរយៈ ការចោទប្រកាន់អាចនៅតែបន្តកើតមានព្រមទាំងឈានដល់ការរំខានយាយី។ ជួនកាលវិធីដែលល្អតែមួយគឺចាកចេញពីភូមិដែលអាចបណ្ដាលឲ្យមានការប៉ះពាល់នូវសិទ្ធិមួយចំនួន ដោយហេតុថាប្រជាពលរដ្ឋ ត្រូវបានបង្ខំឲ្យចាកចេញពីភូមិ គ្រួសារ និងចាកចោលការងាររបស់គេ។

ក្នុងករណីមួយចំនួន ប្រជាពលរដ្ឋនៅតាមមូលដ្ឋានសុំឲ្យបណ្ដេញចេញពីភូមិ ចំពោះជនដែលគេចោទថាជាអាបធ្មប់។ នៅក្នុងករណីទាំងឡាយដែលត្រូវបានពិនិត្យមើល អាជ្ញាធរមូលដ្ឋានបានឆ្លើយតបចំពោះការទាមទារបែបនោះ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួនផ្សេងទៀត ដែលហានិភ័យនៃអំពើហិង្សានៅតែមានកម្រិតខ្ពស់ ពួកគេបានស្នើសុំឲ្យមានដំណោះស្រាយជាបណ្ដោះអាសន្ន ដូចជាកន្លែងស្នាក់នៅខាងក្រៅ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីមួយនៅខេត្តរតនគិរី អ្វីដែលគេសន្មត់ថាជាកន្លែងស្នាក់នៅបណ្ដោះអាសន្ននោះ បានក្លាយជាកន្លែងអចិន្ត្រៃយ៍។ មន្ត្រីនគរបាលស្រុកបរកែវ បានផ្ដល់កន្លែងស្នាក់នៅដល់បុរសម្នាក់និងគ្រួសាររបស់គាត់ (ចំនួន១០នាក់) ក្នុងអង្គភាពនគរបាលតាំងពីឆ្នាំ២០១៥។ អាជ្ញាធរស្រុកបានព្យាយាមរកកន្លែងផ្សេងជំនួសដែលគ្រួសារនេះអាចទៅស្នាក់នៅបាន តែកិត្តិយសរបស់ជនដែលគេចោទថាជាអាបធ្មប់នោះ ត្រូវបានដឹងឮ ដែលធ្វើឲ្យការផ្លាស់ប្ដូរទីកន្លែងរបស់គាត់មានការពិបាក។

នៅខេត្តរតនគិរី អាជ្ញាធរមូលដ្ឋានបានប្រើល្បិចទុច្ចរិត ដើម្បីធ្វើសមាហរណកម្មបុរសម្នាក់ ដែលត្រូវគេចោទប្រកាន់ថាជាអាបធ្មប់ចូលទៅក្នុងភូមិ។ នៅ

*ស្ត្រីម្នាក់រស់ នៅខេត្តរតនគិរី បានធ្លាក់ខ្លួនឈឺអស់រយៈពេលយ៉ាងយូរ។ នៅឆ្នាំ២០១៥ គ្រូបុរាណម្នាក់ នៅប្រទេស វៀតណាម បានកំណត់នូវជម្ងឺរបស់គាត់ថាជាលទ្ធផលនៃការដាក់ បណ្ដាសារ។ អ្នកភូមិម្នាក់ទៀតបានពិគ្រោះយោបល់ជាមួយគ្រូនោះ អំពីចៅប្រុសរបស់គាត់ដែលធ្លាក់ខ្លួនឈឺ ដែលបានអះអាងថា ផងដែរថា អាបធ្មប់ បានធ្វើឲ្យក្មេងប្រុសនេះឈឺ។ ទោះបីជា ក្មេងប្រុសនេះបានជាសះស្បើយឡើងវិញពីជម្ងឺក៏ដោយ ប្រជាពលរដ្ឋ បានចាប់ផ្ដើមផ្សព្វផ្សាយ ពាក្យចចាមអារ៉ាមថា បុរសក្នុងភូមិនេះ មានឈ្មោះថា ពិទូ គឺជាអាបធ្មប់ ព្រោះគាត់បានសួរថា តើចៅប្រុសរបស់អ្នកបានធូរស្បើយពីជម្ងឺហើយឬនៅ នៅមុនពេលសុខភាពរបស់ក្មេងប្រុសនេះចាប់ផ្ដើមធ្ងន់ធ្ងរ។ អ្នកភូមិ បានបណ្ដេញគាត់ចេញពីភូមិ។ មេភូមិបានព្យាយាមស្វែងរកការផ្សះផ្សារ ដោយសុំឲ្យពិទូចូលរួមក្នុងពិធីស្បថតាមប្រពៃណីចំនួន៣ដងតែគាត់បានច្រានចោលនូវសំណើនោះ។ ពិទូបានដាក់ពាក្យបណ្ដឹងទៅតុលាការ ប្រឆាំងនឹងមនុស្ស ៥ នាក់ចំពោះការបរិហារកេរ្ដិ៍។ តុលាការ បានកោះហៅពួកគេ តែពួកគេមិនបានចូលខ្លួនទេ។ ស្ថានភាព បានស្ងប់ស្ងាត់វិញ ដោយសារតែខ្លាចអារនឹងការនាំខ្លួន ឡើងតុលាការ តែនៅឆ្នាំ២០១៧ ប្រជាពលរដ្ឋនៅតែបង្ហាញពីការស្អប់ខ្ពើម ចំពោះពិទូ (ប្រភព៖ បទសម្ភាសន៍របស់ការិយាល័យ OHCHR កម្ពុជា)*

ឆ្នាំ២០១៥ បុរសម្នាក់ត្រូវបានគេបណ្តេញចេញពីភូមិរបស់គាត់ដោយក្រុមមនុស្សប្រហែល៥០០នាក់ ដែលត្រូវគេចោទប្រកាន់ថាធ្វើអំពើអាបធ្មប់។ មន្ត្រីនគរបាលបានឆ្លៀតឱកាសនៃដំណើរទស្សនៈកិច្ចរបស់មន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់មួយនៅក្នុងតំបន់នេះ ដើម្បីជួយគាត់ក្នុងការធ្វើសមាហរណកម្មចូលទៅក្នុងភូមិរបស់គាត់ឡើងវិញ។ អ្នកភូមិ មិនហ៊ានជំទាស់នឹងឆន្ទៈរបស់អ្នកមានឋានៈខ្ពង់ខ្ពស់ និងទទួលយកការវិលត្រឡប់របស់គាត់មកភូមិវិញ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន ជនដែលត្រូវបាគេចោទថាជាអាបធ្មប់មិនចង់អនុវត្តតាមការណែនាំ របស់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានទេ។

## ៦.៣ ការស៊ើបអង្កេត និងការចោទប្រកាន់

ក្នុងចំណោមករណីនៃការសម្លាប់ដោយមហាជនចំនួន២៧ករណី ដែលបានចងក្រង មានតែ២ករណីប៉ុណ្ណោះ ដែលត្រូវបានតាមដានជាមួយនឹងការស៊ើបអង្កេតដ៏មានប្រសិទ្ធិភាព ចំពោះឧប្បត្តិហេតុនៃអំពើហឹង្សាដោយមហាជន ដែលឈានទៅដល់ការចាប់ខ្លួនជនល្មើស។ ក្នុងចំណោមទាំង១៤ករណីនៃអំពើចោរកម្ម ដែលឈានដល់ការសម្លាប់ជនដែលរងការចោទប្រកាន់ថាជាចោរដោយមហាជន មន្ត្រីនគរបាលបានធ្វើការស៊ើបអង្កេតតែលើករណីចោរកម្ម តែមិនបានអង្កេតលើករណីសម្លាប់នោះទេ។ នៅស្នងការនគរបាលខេត្ត អង្គភាពនគរបាលដែលទទួលបន្ទុកគឺ "អង្គភាពទទួលបន្ទុកបទល្មើសព្រហ្មទណ្ឌកម្រិតស្រាល" ជាអ្នកគ្រប់គ្រងលើករណីទាំងនេះ[៥៩] មានន័យថា មានតែករណីចោរកម្មប៉ុណ្ណោះ ដែលត្រូវបានគិតគូរពិចារណាចាត់ការ ហើយករណីឃាតកម្មមិនត្រូវបានពិចារណានោះទេ។ នៅពេលដែលលើកបញ្ហានេះជាមួយមន្ត្រីនគរបាលមួយចំនួន មានការលេចឡើងថា ការសម្លាប់ដោយមហាជន ទៅលើចោរគឺជាញឹកញាប់មិនត្រូវបានយល់ថាជាករណីឃាតកម្មដែលត្រូវទទួលការផ្តន្ទាទោសនោះទេ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា ជនដៃដល់ចំនួន១៤នាក់ ត្រូវបានចាប់នាំខ្លួនទៅតុលាការពាក់ព័ន្ធនឹងករណីចំនួន ៤ នៃអំពើហិង្សា និងក្រោយមកដោះលែង៦នាក់វិញ បន្ទាប់ពីបានធ្វើការអប់រំ។ ក្នុងករណីឃាតកម្ម ដែលកើតឡើងពីការចោទប្រកាន់ថាចេះអំពើអាបធ្មប់ មានជនដៃដល់ ៦នាក់ត្រូវបានចាប់ខ្លួនក្នុង ៥ករណី។ ទិន្នន័យនេះទទួលបានចន្លោះពីខែមករា ឆ្នាំ២០១៧ ដល់ខែមិថុនា ឆ្នាំ២០១៩។

> *"យើងនឹងមិនចាប់ខ្លួន ឬ សួរចម្លើយអ្នកភូមិណាមួយទេ ពីព្រោះមានអ្នកភូមិប្រហែលជា ៥០០នាក់ហើយដែលចំនួននេះគឺវាច្រើនណាស់។ យើងមិនអាចសួរចម្លើយពួកគាត់ទាំងអស់បានទេ។ យើងខ្លាចអ្នកភូមិទាំងនោះ គាត់ខឹង ប្រសិនបើយើងធ្វើការស៊ើបអង្កេតលើករណីនេះ"[៦០]។*
>
> *"ខ្ញុំគ្រាន់តែបានទាត់គាត់មួយជើង ដើម្បីដាក់ទោសគាត់។ មិនមាននរណាម្នាក់ បានសម្លាប់គាត់ទេ។ វាជារឿងធម្មតា ក្នុងការផ្តល់មេរៀនចំពោះមនុស្សប្រភេទនេះ។ ប្រសិនជាគាត់បានស្លាប់ មានន័យថា វាជាថ្ងៃអន្សារ[៦១] របស់គាត់ហើយ។(ប្រភព៖ កិច្ចសម្ភាសន៍របស់ការិយាល័យ OHCHR)។*

[៥៩] ការងាររបស់នគរបាលព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរផ្នែកនៅថ្នាក់ខេត្ត និងស្រុក៖ "អង្គភាពទទួលបន្ទុកបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់" ត្រូវបានគេហៅថា "បទឧក្រិដ្ឋ" ដែលមានបទល្មើស៤ប្រភេទគឺអំពើចោរកម្ម ឃាតកម្ម អំពើភេរវកម្ម និង ការរំលោភផ្លូវភេទ។ និង "អង្គភាពទទួលបន្ទុកបទល្មើសព្រហ្មទណ្ឌកម្រិតស្រាល" ក៏ត្រូវបានគេសំដៅថាជា "បទមជ្ឈឹម" ដែលមានបទល្មើស៥ប្រភេទគឺចោរកម្ម ការលួចបន្លំ/ការរំលោភបំពានលើសេចក្តីទុកចិត្ត ការបង្ករបួសស្នាម ការប្រើអាវុធខុសច្បាប់ និងផ្សេងៗទៀត។

[៦០] សូមមើល https://www.phnompenhpost.com/national/violence-begets-violence.

[៦១] យោងតាមវប្បធម៌របស់កម្ពុជាដែលទទួលឥទ្ធិពលពីសាសនាព្រះពុទ្ធ ជនដែលបានប្រព្រឹត្តអំពើអាក្រក់ នឹងត្រូវទទួលបាននូវបាបកម្មនៅជីវិតជាតិខាងមុខ ឬ ជាតិនេះ (កម្មា វដ្តសង្សា)។ ការស្លាប់ដោយហិង្សាបែបនេះ មានន័យថា វាជាកម្មរបស់គាត់ដែលបានសាងមក ឬជាភ័ព្វវាសនារបស់គាត់។ ពួកគេបានមកដល់ថ្ងៃស្លាប់របស់ពួកគេ "ដល់ថ្ងៃអន្សា" "វាជាថ្ងៃស្លាប់របស់ពួកគេ". ដូច្នេះ មានការយល់ឃើញថា វាជាវាសនា ហើយមិនមានអ្នកណាម្នាក់អាចទទួលខុសត្រូវនោះទេ។

នៅក្នុង ករណីមួយដែលចងក្រងដោយការិយាល័យឧត្តម ស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR-កម្ពុជា) ការអន្តរាគមន៍របស់មន្ត្រីនគរបាល បានធ្វើឲ្យបុរសម្នាក់រស់រានមានជីវិតក្រោយពីការវាយដំដោយមហាជនបើទោះបីជាបច្ចុប្បន្ននេះ គាត់មានពិការភាពផ្នែកស្មារតី ដែលជាលទ្ធផលនៃការវាយដំនេះក៏ដោយ។ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ សម្រាប់បទល្មើសដែលគាត់បានប្រព្រឹត្ត ប៉ុន្តែមិនមានជនណាម្នាក់ត្រូវបានចាប់ខ្លួនទាក់ទងនឹងការវាយដំនោះទេ។ នៅក្នុងករណីដោយឡែកមួយទៀតដែលចងក្រងដោយការិយាល័យ OHCHR បុរសម្នាក់ដែលបានផ្សព្វផ្សាយព័ត៌មានដែលធ្វើឲ្យមានការវាយដំ ត្រូវបានចាប់ខ្លួន និងត្រូវបានដោះលែងវិញក្រោយពីបានសរសេរលិខិតសុំទោស។ ករណីនេះ បន្ទាប់មកត្រូវបានបិត។ នៅក្នុងករណីទី៣[៦២] ដែលចងក្រងដោយការិយាល័យ OHCHR ហើយគឺជាករណីតែមួយគត់ដែលឈានដល់ការជំនុំជម្រះដែលក្នុងនោះមនុស្សចំនួន ៣រូប ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ រយៈពេល៣ឆ្នាំ ដោយចោទប្រកាន់ពីបទអំពើហឹង្សាដោយចេតនា និងបង្ករការខូចខាតដោយចេតនា ដោយមានស្ថានទម្ងន់ទោស។ ពួកគេទាំង៣ត្រូវបានផ្តន្ទាទោសព្យួរទោសរយៈពេល១៨ ខែ និងបង្គាប់ឲ្យសងជំងឺចិត្ត និងការខូចខាតចំនួនប្រហែល ១២៥.០០០ ដុល្លាអាមេរិក។ នៅក្នុងករណីមួយទៀត មន្ត្រីនគរបាល បានចាប់ខ្លួនជនសង្ស័យចំនួន៣រូប និងពួកគេត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពួកគេត្រូវបានដោះលែងដោយសារតែរឿងក្តីនេះត្រូវបានរាយការថា បានដោះស្រាយដោយថវិកាជាមួយនឹងគ្រួសាររបស់ជនរងគ្រោះ។ មិនមានចំណាត់ការផ្សេងទៀត ត្រូវបានធ្វើឡើងដោយតុលាការទៀតទេ។

នៅក្នុងករណីនៃអំពើហឹង្សាដោយមហាជនប្រឆាំងនឹងជនដែលរងការចោទប្រកាន់ថាជាចោរ មានការរាយការណ៍ថា ជនរងគ្រោះ និង/ឬគ្រួសាររបស់ជនដែលរងការចោទប្រកាន់ថាជាចោរ[៦៣] កម្រដាក់ពាក្យបណ្តឹងទៅមន្ត្រីនគរបាល ឬ តុលាការណាស់។ ទីមួយ ពួកគេមានអារម្មណ៍ខ្មាស់អៀនចំពោះការមានការពាក់ព័ន្ធជាមួយករណីអំពើចោរកម្ម។ ទីពីរ ពួកគេខ្លាចមានការសងសឹកពីជនដែលត្រូវបានឆក់ប្លន់ ពីជនដែលបានចូលរួមនៅក្នុងការសម្លាប់ដោយមហាជន ឬ សូម្បីតែពីអ្នកស្រុកភូមិដទៃទៀត។ ទីបី ពួកគេជឿជាក់ថា មន្ត្រីនគរបាលអាចសុំថវិកាសម្រាប់ការស៊ើបអង្កេត ដែលនៅក្នុងករណីខ្លះទំនងជាមិនឈានដល់ការចាប់ខ្លួននោះទេ ដោយសារមន្ត្រីនគរបាលអាចមានការស្ទាក់ស្ទើរក្នុងការបង្កើតទំនាក់ទំនងមិនល្អជាមួយអ្នកភូមិទាំងមូល។

បញ្ហាមួយនៃបញ្ហាចម្បងដែលអជ្ញាធរបានជួបប្រទះនៅក្នុងការស៊ើបអង្កេតករណីនៃអំពើហឹង្សាដោយមហាជន គឺការលំបាកនៅក្នុងការកំណត់ការទទួលខុសត្រូវរបស់បុគ្គល ដោយសារតែមានចំនួនដ៏ច្រើននៃជនល្មើស ដែលអាចមានរហូតដល់រាប់រយនាក់។ បើទោះបីជា អ្នកចូលរួមនីមួយៗ អាចជាផ្នែកមួយនៃអំពើហឹង្សា វាអាចមានការលំបាកនៅក្នុងការកំណត់ពីកម្រិតនៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ។ បន្ថែមពីនេះ និងជាពិសេស នៅក្នុងករណីដែលចំនួនជនដែលចូលរួម មានចំនួនកាន់តែច្រើន មន្ត្រីនគរបាលមានអារម្មណ៍ថាមានបន្ទុកលើសលុប និងមិនមានលទ្ធភាពនៅក្នុងការសួរចម្លើយជនដែលបានចូលរួមទាំងអស់នោះ។ មន្ត្រីនគរបាលមួយចំនួន បានបញ្ជាក់ថា ពួកគាត់ខ្លាចប្រជាជនទាំងអស់នោះប្រឆាំងនឹងពួកគាត់ ប្រសិនបើពួកគាត់ចាប់ផ្តើមការស៊ើបអង្កេត។

បញ្ហាបន្ថែមមួយទៀតទាក់ទងនឹងការទទួលខុសត្រូវចំពោះករណីនៃ “ការកាត់ទោសដោយមហាជន” ត្រូវបានរាយការណ៍ថា មានការខ្វះការសហប្រតិបត្តិ

[៦២] សូមមើល footnote 8.

[៦៣] នៅក្នុងករណីមួយចំនួន អត្តសញ្ញាណរបស់សាកសពដែលត្រូវបានចោទថាជាចោរ មិនត្រូវបានរកឃើញទេ។

ការរវាងមន្ត្រីនគរបាល និងតុលាការ។ យោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបំពេញមុខងារនៅក្រោមព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។ ទោះជាយ៉ាងនេះក្តី នៅក្នុងការអនុវត្តជាក់ស្តែង មន្ត្រីនគរបាល មិនបានបញ្ជូនសំណុំរឿងទាំងអស់ទៅតុលាការនោះទេ។ នៅក្នុងករណីខ្លះ មន្ត្រីនគរបាលអាចធ្វើការសម្របសម្រួល ឬ ដោះស្រាយទំនាស់/ជម្លោះបាន។ ប៉ុន្តែនៅក្នុងករណីខ្លះផ្សេងទៀត មន្ត្រីនគរកាលយុត្តិធម៌ បានបង្ហាញពីកង្វល់របស់ពួកគេថា ប្រសិនបើជនដែលបានរងការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសមួយចំនួន ( ដូចជា អំពើប្លន់ មនុស្សឃាត រំលោភសេពសន្ថវៈ ការបង្កគ្រោះថ្នាក់ចរាចរ ) ត្រូវបានដោះលែងដោយតុលាការ ហើយមិនត្រូវបានឃុំខ្លួននោះ ប្រជាពលរដ្ឋ នឹងធ្វើការវាយប្រហារជាមួយនឹងមន្ត្រីនគរបាល ដោយចោទប្រកាន់ថាពុករលួយ ឬមិនបានបំពេញការងាររបស់ពួកគេឲ្យបានត្រឹមត្រូវ។ តាមទស្សនៈរបស់ពួកគាត់ មន្ត្រីតុលាការ បានត្អូញត្អែរអំពីកង្វះខាត នៃភស្តុតាងដែលផ្តល់ដោយមន្ត្រីនគរបាល ដើម្បីចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ។ មូលហេតុមួយចំនួននៃបញ្ហានេះ គឺកង្វះថវិកា ជំនាញ និងសមត្ថភាព នៅក្នុងការស៊ើបអង្កេត ប្រាក់បៀវត្សរ៍តិច និងកង្វះវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីតុលាការ។

ភ្ជាប់ជាមួយនឹងករណីនេះ ប្រាក់បៀវត្សរ៍ទាបក្នុងចំណោមមន្ត្រីនគរបាលក៏អាចពន្យល់ផងដែរអំពីភាពស្ទាក់ស្ទើរនៅក្នុងការស៊ើបអង្កេតឲ្យបានហ្មត់ចត់ចំពោះករណីរឿងក្តីនៃ“ការកាត់ទោសដោយមហាជននេះ”។ ជាក់ស្តែង ដោយហេតុថា មន្ត្រីនគរបាល បានទទួលប្រាក់បៀវត្សរ៍ទាប មានការរាយការណ៍ថា ពួកគាត់ពឹងផ្អែកការស៊ើបអង្កេត ដើម្បីអាចរកលុយបន្ថែម។ ការស៊ើបអង្កេតចំពោះករណីប្លន់ម៉ូតូ អាចមានកម្រៃកាក់កបខ្លាំង ដោយសារតែ ម្ចាស់ម៉ូតូ ផ្តល់រង្វាន់ទៅមន្ត្រីនគរបាលនៅពេលដែលពួកគេបានម៉ូតូត្រលប់មកវិញ។ អធិការរងប៉ូលីសស្រុកម្នាក់ បានពន្យល់ថាមន្ត្រីនគរបាលនឹងមិនធ្វើការស៊ើបអង្កេតចំពោះករណីវាយដំដោយកំហឹងមហាជនទេ ពីព្រោះក្រុមគ្រួសារ មិនបានដាក់ពាក្យបណ្តឹងដោយសារតែភាពអាម៉ាស់ និងខ្លាចការសងសឹកវិញ។ លោកបានបន្ថែមថា ប្រសិនបើគាត់ធ្វើការស៊ើបអង្កេតទៅលើការសម្លាប់ដោយមហាជន គាត់“នឹងខាតពេលវេលា និងមិនអាចរកលុយបានទេ”។ បន្ថែមពីនេះ គាត់បានជឿជាក់ថា ប្រជាជននឹងមិនយល់អំពីមូលហេតុដែលជនម្នាក់ដែលបានជួយចាប់ចោរ អាចនឹងត្រូវបានចាប់ខ្លួន ដោយសារតែការដាក់ទោសចោរ គឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ។

ផ្អែកលើព័ត៌មានដែលប្រមូលបាន វាជាភស្តុតាងបង្ហាញថា ជាទូទៅ មន្ត្រីនគរបាលមានការទទួលខុសត្រូវនៅក្នុងការស៊ើបអង្កេត និងចាប់ខ្លួនជនដែលបានចូលរួមនៅក្នុងការបង្កអំពើហឹង្សាលើករណីអាបធ្មប់ ជាជាងករណីរឿងក្តីនៃ ”ការកាត់ទោសដោយមហាជន” ប្រឆាំងនឹងជនដែលចោទថាបានប្រព្រឹត្តអំពើល្មើស ឬបានជឿជាក់ថា បានបណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍។ នៅកន្លែងខ្លះ មន្ត្រីនគរបាល មានភាពសកម្មខ្លាំងនៅក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការព្យាយាមក្នុងកិច្ចការពារជនសង្ស័យជាអាបធ្មប់ ដោយផ្អែកលើការអនុវត្តការផ្សះផ្សារតាមប្រពៃណី។

*នៅឆ្នាំ២០១៥ យុវជនចំនួន៣រូប បានវាយនិងសម្លាប់ពូរបស់ពួកគេឈ្មោះរីទ្ធ ដោយបានចោទប្រកាន់គាត់ថាបានធ្វើអំពើអាបធ្មប់ ឲ្យសាច់ញាតិរបស់គេឈឺ។ រីទ្ធ មានកេរ្តិ៍ឈ្មោះមិនល្អទេនៅក្នុងភូមិ។ គាត់ធ្លាប់ផឹកស្រាស និងវាយដំប្រពន្ធរបស់គាត់ ដោយចោទថាបានគេងជាមួយបុរសផ្សេងទៀត។ នៅពេលដែលមន្ត្រីនគរបាលបានចាប់ខ្លួនជនល្មើសទាំង៣ ប្រជាជនប្រមាណជា២០០នាក់ បានផ្តិតមេដៃលើញត្តិមួយ ដើម្បីស្នើសុំមន្ត្រីនគរបាលឲ្យដោះលែងពួកគេ។ នៅឆ្នាំ២០១៦ ពួកគេទាំង៣ ត្រូវបានជំនុំជម្រះ និងផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ៗរយៈពេល៣០ឆ្នាំ ( ប្រភព៖ កិច្ចសម្ភាសន៍របស់ការិយាល័យ OHCHR-Cambodia ).*

ទោះជាយ៉ាងណាក៏ដោយ បើទោះបីជាមន្ត្រីនគរបាលមានភាពសកម្មខ្លាំងនៅក្នុងការស៊ើបអង្កេតចំពោះករណីដែលពាក់ព័ន្ធនឹងការសម្លាប់អាបធ្មប់ក៏ដោយ ចំនួនករណីដែលបានរាយការណ៍ បានបន្សល់ទុកនូវការមិនបានដាក់ទោសទណ្ឌមានច្រើន បើទោះបីជាចំនួនស្ថិតិផ្លូវការមិនអាចរកបាន។ មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋាន បានរាយការណ៍ថាការស៊ើបអង្កេតលើករណីនៃការសម្លាប់ទាក់ទងនឹងអំពើអាបធ្មប់អាចជាការពិបាក ព្រោះប្រជាពលរដ្ឋនៅមូលដ្ឋានមានឆន្ទៈខ្ពស់ក្នុងការការពារជនល្មើសដែលត្រូវបានចោទប្រកាន់ ជាជាងជួយស៊ើបអង្កេតករណីនេះ និងចាប់ខ្លួនពួកគេ។ ការរកសាក្សីក៏អាចជាបញ្ហាប្រឈមដ៏លំបាកផងដែរ ជាពិសេសនៅពេលគ្មានភស្តុតាងរឹងមាំដែលឈានទៅដល់ការចាប់ខ្លួនជនល្មើសដែលបានចោទប្រកាន់។

ជាទូទៅ ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន មានការស្ទាក់ស្ទើរផ្តល់ព័ត៌មានឱ្យមន្ត្រីនគរបាលដែលឈានទៅដល់ការចាប់ខ្លួនជនទាំងឡាយដែលគេជឿថា បានសម្លាប់ជនដែលសង្ស័យថាចេះអាបធ្មប់។ ក្នុងករណីខ្លះ ពួកគេថែមទាំងអាចចាត់វិធានការរួមគ្នា ដើម្បីគាំទ្រជនសង្ស័យ។ នៅឆ្នាំ២០១៦ សាក សពដែលគេកាត់ក្បាលរបស់លោកវាសនា ត្រូវបានរកឃើញនៅក្នុងចំការមួយក្នុងខេត្តកំពង់ស្ពឺ។ មន្ត្រីនគរបាលបានធ្វើការស៊ើបអង្កេត ហើយបានចាប់ខ្លួនស្ត្រី២នាក់ដែលបានសារភាពថា បានប្រព្រឹត្តបទល្មើសនេះ។ ស្ត្រីយំចំណាស់ម្នាក់បានពន្យល់ថា វាសនាបានធ្វើឲ្យសាច់ញាតិរបស់គាត់ម្នាក់ស្លាប់កាលពីប៉ុន្មានឆ្នាំមុន។ ជំងឺម៉្យាងដែលសាច់ញាតិម្នាក់ផ្សេងទៀតទទួលរងគ្រោះត្រូវបានចាត់ទុកដោយអ្នកភូមិថាបណ្តាលមកពីគាត់ដែរ។ ក្រោយមក ពួកគេបានអះអាងថា មន្ត្រីនគរបាលបាន ធ្វើការគំរាមកំហែងឲ្យឆ្លើយសារភាពក្រោមការដាក់សម្ពាធ និងប្រជាពលរដ្ឋចំនួន១៨៨នាក់ដែលរស់នៅក្នុងភូមិ ជាទីដែលឃាតកម្មនេះបានប្រព្រឹត្តឡើង បានដាក់ពាក្យបណ្តឹងទៅមន្ត្រីនគរបាលខេត្ត ដើម្បីសុំឱ្យដោះលែងស្ត្រីទាំង២នាក់។ តុលាការ បានដោះលែងស្ត្រីទាំង២នាក់ ដោយលើកឡើងថាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីរក្សាទុកការចោទប្រកាន់។ នៅក្នុងបរិបទនេះផងដែរ អ្នកភូមិបានបណ្តេញចេញ និងគំរាមកំហែងភរិយារបស់បុរសម្នាក់ដែលត្រូវបានគេសម្លាប់ដោយចោទប្រកាន់គាត់ពីការដាក់ពាក្យ បណ្តឹងដែលឈានដល់ការចាប់ខ្លួនស្ត្រីទាំង ២នាក់។ គាត់បានដកពាក្យបណ្តឹងរបស់គាត់ ហើយមន្ត្រីនគរបាលមិនបានធ្វើការស៊ើបអង្កេតអ្វីបន្ថែមទេ។

ការពិតទៅ ការសម្លាប់ដោយមហាជន កម្រត្រូវបានគេស៊ើបអង្កេតណាស់ហើយ ជនល្មើសរួចផុតពីការផ្តន្ទាទោស ដែលមានន័យស្មើនឹងការទទួលយកដោយស្ងាត់ស្ងៀមចំពោះទម្លាប់អនុវត្តនេះដោយអាជ្ញាធររដ្ឋ។ ជាលទ្ធផល ប្រជាពលរដ្ឋ អាចទទួលបានការលើកទឹកចិត្តឱ្យបន្តទម្លាប់អនុវត្តនេះទៀត។រដ្ឋមានកាតព្វកិច្ចមួយ នៅក្រោមច្បាប់អន្តរជាតិ ដើម្បីផ្តល់សន្តិសុខដល់ប្រជាពលរដ្ឋរបស់ខ្លួនទាំងអស់ រួមទាំងអ្នកដែលសង្ស័យថាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

## ៦.៤ ដំណោះស្រាយ និងការជួសជុលសំណង

ផ្អែកលើករណីដែលបានស៊ើបអង្កេតវាបានបង្ហាញថាសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះ កម្រនឹងបានបំពេញណាស់ ដែលក្នុងនោះមួយផ្នែកដោយសារតែមានចំនួនករណីតិចតួចណាស់ដែលបានទៅដល់តុលាការ ដូចដែលបានពន្យល់ខាងលើ និងដោយសារតែជនរងគ្រោះភាគច្រើនមិនហ៊ានទាមទារសំណង ពីព្រោះភាពអាម៉ាស់និងស្លាកស្នាមទុរយស។

ក្នុងចំណោមករណីនៃការសម្លាប់ដោយមហាជនចំនួន ២២ករណីដែលចងក្រងដោយការិយាល័យ OHCHR តាំងពីឆ្នាំ២០១០ មានតែ៥ករណីប៉ុណ្ណោះដែលឈានដល់ការចាប់ខ្លួនជនសង្ស័យ ហើយសំណងត្រូវបានផ្តល់ឲ្យក្រុមគ្រួសារជនរងគ្រោះ មានតែមួយករណីប៉ុណ្ណោះ។ ករណីចំនួន២ ក្នុងចំណោម

៥ គឺជាករណីថ្មីៗ (ឆ្នាំ២០១៨ - ២០១៩)។ ការវិវឌ្ឍដ៏តិចតួចនៅក្នុងការស៊ើបអង្កេត និងនាំជនល្មើសទៅកាន់ប្រព័ន្ធយុត្តិធម៌អាចជាការកំណត់លើការអំពាវនាវពីសំណាក់នាយករដ្ឋមន្ត្រី ដើម្បីបញ្ឈប់អំពើហឹង្សាដោយមហាជននៅឆ្នាំ២០១៨។[៦៤] ចំណាត់ការបែបនេះ និងការងារបង្ការបន្ថែមទៀត គួរតែត្រូវបានលើកទឹកចិត្ត និងបន្ទរដោយសេចក្តីថ្លែងការណ៍ជាសាធារណៈបន្ថែមទៀតដោយអាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់។

ក្នុងចំណោមករណីដែលពាក់ព័ន្ធនឹងអំពើហឹង្សាលើអាបធ្មប់ចំនួន៣៥ករណី ដែលបានចងក្រងដោយការិយាល័យ OHCHR មាន១០ករណីបានឈានដល់ការចាប់ខ្លួនជនសង្ស័យ។ ក្នុងចំណោមករណីទាំង៥នេះ ជនល្មើស១រូប ឬមួយចំនួនត្រូវបានបញ្ជូនទៅពន្ធនាគារ។ ជនសង្ស័យចំនួន ២រូប ត្រូវបានដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីមានការផ្សះផ្សារផ្នែកហិរញ្ញវត្ថុរវាងក្រុមគ្រួសាររបស់ជនរងគ្រោះ និងជនល្មើស។ នៅក្នុងករណីចំនួន៣ទៀត ជនសង្ស័យ១រូប ឬមួយចំនួនត្រូវបានទទួលការចោទប្រកាន់ ប៉ុន្តែមិនត្រូវបានចាប់ខ្លួនទេ ដែលធ្វើឲ្យក្រុមគ្រួសារជនរងគ្រោះមិនទទួលបានសំណងផ្លូវចិត្ត និងឃើញឃាតករដែលសម្លាប់សាច់ញាតិគាត់មិនទទួលបានការផ្តន្ទាទោសតាមច្បាប់។ ជាមួយនឹងសិទ្ធិទទួលបានយុត្តិធម៌មិនមានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះ និងសំណងតិចតួច ឬមិនគ្រប់គ្រាន់ មិនមានប្រសិទ្ធភាព មិនសមស្រប ចំពោះភាពរងគ្រោះនោះ ជនរងគ្រោះភាគច្រើន មិនទទួលបានការអនុវត្តសិទ្ធិទទួលបានដំណោះស្រាយរបស់ពួកគេទេ។

---

៦៤ សូមមើល footnote 8.

# ៧. សេចក្តីសន្និដ្ឋាន

"ការកាត់ទោសដោយមហាជន" នៅកម្ពុជា ក៏ដូចជានៅក្នុងប្រទេសដទៃជុំវិញពិភពលោក រីកធំធាត់ដោយសារតែការខូចខាតដែលមានជាយូរមកហើយ ភាពតានតឹង និងការខកចិត្តកាន់តែកើនឡើង ដោយសារកង្វះជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋ តំរិយាបទរើសអើងនៅក្នុងសង្គម ភាពក្រីក្រ និងកង្វះការអប់រំ ជាពិសេស ការអប់រំសិទ្ធិមនុស្ស។ ឧប្បដិហេតុ ឬពាក្យចចាមអារាមជាយូរមកហើយ ឬស្ថានភាពស្វាស៊ីបាយរួចលាបមាត់ពពែអាចមានលក្ខណៈគ្រប់គ្រាន់បញ្ឆេះភាពតានតឹងទាំងនេះ។ អសមត្ថភាព និងជួនកាល ភាពគ្មានឆន្ទៈរបស់អាជ្ញាធរដើម្បីឆ្លើយតបនឹងអំពើ "ការកាត់ទោសដោយមហាជន" អាចបដិសេធសិទ្ធិមនុស្សទាំងអស់រួមទាំងសិទ្ធិទទួលដំណោះស្រាយត្រឹមត្រូវដល់ជនរងគ្រោះពីអំពើបែបនេះ។ វាក៏អាចនាំទៅរកនិទណ្ឌភាព ប្រហែលជាអាចកើនឡើងនៃការប្រព្រឹត្តអំពើ "ការកាត់ទោសដោយមហាជន" នៅថ្ងៃអនាគត។

អតីតតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ ភីតធី ឡឺព្រេច បានគូសបញ្ជាក់ពីកង្វល់នៃ"ការកាត់ទោសដោយមហាជន"ជិត២០ឆ្នាំកន្លងមកនេះ។ ថ្វីបើករណីនៃ "ការកាត់ទោសដោយមហាជន" មានការថយចុះ បើប្រៀបធៀបទៅដើមឆ្នាំ២០០០ វានៅតែជាបញ្ហាសង្គម និងច្បាប់ដែលនៅតែបន្តជាបញ្ហាកង្វល់នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃកាលពីឆ្នាំ២០១៨ គឺជាសញ្ញាមួយដ៏សំខាន់ដែល "ការកាត់ទោសដោយមហាជន" មិនត្រូវបានទទួលយកបាននៅក្នុងសង្គមដោយផ្អែកលើនីតិរដ្ឋ និងសិទ្ធិមនុស្ស។ ការកសាងចំណាត់ការរួមគ្នា គឺមានភាពចាំបាច់ណាស់ ដើម្បីឆ្លើយតបនឹងសេចក្តីថ្លែងការណ៍ទាំងនេះ។ ចំណាត់ការនេះ រួមបញ្ចូលទាំងការលើកកម្ពស់ការយល់ដឹងនៃគោលការណ៍សិទ្ធិមនុស្ស និងនីតិរដ្ឋ ដែលវាសំខាន់ណាស់ក្នុងការប្រឆាំងនឹងជំនឿថា សមាជិកសហគមន៍អាចស្វែងរកយុត្តិធម៌នៅក្នុងដៃរបស់ពួកគេ រួមបញ្ចូលទាំងការសម្លាប់ជនណាម្នាក់ ដោយបដិសេធនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងការសន្មតជាមុនថាគ្មានទោស។

របាយការណ៍នេះ ក៏បានបញ្ជាក់ផងដែរថា កត្តាជាមូលដ្ឋានមួយចំនួនដែលឈានទៅ ដល់ការចោទប្រកាន់ និងធ្វើទុក្ខបុកម្នេញអំពើអាបធ្មប់ មានការពាក់ព័ន្ធនឹងប្បញ្ញត្តិ និងផ្នត់គំនិតអវិជ្ជមានរបស់មនុស្សជាមួយនឹងពិការភាពរូបរាងកាយ និងស្មារតីដែលអាចក្លាយជារបាំងមួយដ៏សំខាន់ចំពោះការចូលរួមពេញលេញនៅក្នុងសង្គមរបស់មនុស្សទាំងនេះ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នាជាមួយមនុស្សដទៃទៀត។ ការអប់រំសិទ្ធិមនុស្ស ក៏គួរតែលើកកម្ពស់ការយល់ដឹងផងដែរអំពីសេរីភាពពីការរើសអើង ជាពិសេសនៅលើមូលដ្ឋាននៃពិការភាព សិទ្ធិវប្បធម៌ និងគោលការណ៍បរិយាប័ន្នសម្រាប់មនុស្សទាំងអស់នៅក្នុងសង្គម បើទោះបីជាមនុស្សភាគច្រើនបានដឹងថាពួកគេមានភាពខុសគ្នា ឬ មិនប្រតិបត្តិតាមវប្បធម៌ និងប្បញ្ញត្តិសង្គម ព្រមទាំងប្រពៃណីមួយចំនួនក៏ដោយ។

ការបង្កើតទំនុកចិត្តនៅក្នុងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា និងក្នុងស្ថាប័ននានា គឺមានសារៈសំខាន់ដូចគ្នា។ ម៉្យាងវិញទៀត ករណីនេះរួមទាំងការបង្កើនសមត្ថភាពបច្ចេកទេស និងថវិការបស់ប្រព័ន្ធតុលាការ

និងនគរបាល ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើ “ការកាត់ទោសដោយមហាជន”។ ជាពិសេស តម្រូវការធនធានបន្ថែម គឺមានភាពចាំបាច់ ដើម្បីធានាការស៊ើបអង្កេតត្រឹមត្រូវ ការចោទប្រកាន់ និងការផ្តន្ទាទោសនៅគ្រប់ករណីទាំងអស់។ ម្យ៉ាងវិញទៀត ការខិតខំប្រឹងប្រែងដើម្បីបំបាត់អំពើពុករលួយ គួរតែត្រូវបានកសាងឡើងឲ្យរឹងមាំ និងមានទំនុកចិត្តបន្ថែមទៀតលើប្រព័ន្ធតុលាការ។

មានភស្តុតាងបង្ហាញថា ការបង្ការទប់ស្កាត់ និងបំបាត់“ការកាត់ទោសដោយមហាជន គឺជាដំណើរការមួយដ៏ស្មុគ្រស្មាញ និងចំណាយពេលវេលាយូរ ដែលតម្រូវឲ្យមានការចូលរួម យ៉ាងពេញលេញពីសំណាក់ដៃគូរខុសៗគ្នា ដូចជា រាជរដ្ឋាភិបាល តុលាការ នគរបាល អង្គការសង្គមស៊ីវិល ព្រមទាំងសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋខ្លួនឯងផងដែរ។ សហគមន៍អន្តរជាតិ ក៏អាចផ្តល់ការគាំទ្រផងដែរនីក្នុងករណីនេះ។

# ៨. អនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា

**ច្បាប់ និងគោលនយោបាយ**

- បង្កើតគោលនយោបាយ ដើម្បីដោះស្រាយអំពើ "ការកាត់ទោសដោយមហាជន" និងកែសម្រួលគោលការណ៍ ឬសារាចរដែលមានស្រាប់ សម្រាប់ការអន្តរាគមរបស់មន្ត្រីនគរបាល ក្នុងករណីមានអំពើហឹង្សាដោយមហាជន។

**ការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះគ្រប់បទល្មើសព្រហ្មទណ្ឌទាំងអស់**

- អាជ្ញាធរនានាដែលស្ថិតនៅលំដាប់ខ្ពស់បំផុត គួរតែថ្កោលទោសជាសាធារណៈរាល់អំពើ "ការកាត់ទោសដោយមហាជន" នៅពេលវាកើតឡើង

- ធានាថា រាល់ "ការកាត់ទោសដោយមហាជន" ដោយការសម្លាប់ និងប្រើហឹង្សា ត្រូវតែបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ ចោទប្រកាន់ និងទទួលបានការផ្តន្ទាទោសដោយច្បាប់។

- ធានាថា កងកម្លាំងនគរបាល មានធនធានមនុស្ស និងថវិកាគ្រប់គ្រាន់ ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពនៅក្នុងករណីនៃ "ការកាត់ទោសដោយមហាជន"។

- បង្កើតទិន្នន័យផ្លូវការគ្រប់ជ្រុងជ្រោយអំពីការកើតឡើងនៃ "ការកាត់ទោសដោយមហាជន" ក៏ដូចជាស្ថានភាពនៃការស៊ើបអង្កេត និង/ឬការផ្តន្ទាទោស។

- លើកកម្ពស់ការយល់ដឹងក្នុងចំណោមមន្ត្រីនគរបាលនៅមូលដ្ឋានគ្រប់លំដាប់ថ្នាក់អំពីភាពខុសច្បាប់នៃអំពើ "ការកាត់ទោសដោយមហាជន"។ ការលើកកម្ពស់នេះ គួរតែត្រូវបានធ្វើឡើងក្នុងអំឡុងពេលធ្វើបទបង្ហាញខ្លីៗ/វេទិការសាធារណៈសម្រាប់មន្ត្រីនគរបាល ដែលត្រូវបានរៀបចំឡើងជាប្រចាំនៅថ្នាក់ឃុំ-សង្កាត់ ដោយមន្ត្រីនគរបាល។

- ធានាថា វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីតុលាការ និងនគរបាលមានរាប់បញ្ចូលនូវធាតុផ្សំដើម្បីដោះស្រាយ និងឆ្លើយតបចំពោះកាតព្វកិច្ចនៃការស៊ើបអង្កេតរាល់បទឧក្រិដ្ឋធ្ងន់ធ្ងរទាំងអស់ បើទោះបីជាមានបណ្តឹង ឬអត់ និងធានាថា រាល់ជនសង្ស័យទាំងអស់ដែលជាជនរងគ្រោះនៃបទល្មើសនៃអំពើហឹង្សា មានសិទ្ធិទទួលបានដំណើរក្តីត្រឹមត្រូវតាមនីតិវិធី នៅក្នុងប្រព័ន្ធយុត្តិធម៌។

- ធានាថា មន្ត្រីអនុវត្តច្បាប់ ទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ ស្តីពីសកម្មភាពស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ។

- ពិចារណាក្នុងការបង្កើតក្រុមការងារពិសេសនៅតាមបណ្តាខេត្តពាក់ព័ន្ធ ដែលទទួលខុសត្រូវសម្រាប់ការស៊ើបអង្កេតករណីនៃ "ការកាត់ទោសដោយមហាជន"។

**ពង្រឹងស្ថាប័នយុត្តិធម៌**

- ធ្វើការស្ទង់មតិអំពីបច្ចុប្បន្នភាពនៃការបង់ប្រាក់ក្រៅផ្លូវការនៅក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីជាមធ្យោបាយមួយនៃការស្វែងយល់អំពីបញ្ហានៃអំពើពុករលួយ និងកសាងទំនុកចិត្តនៅក្នុងសហគមន៍។
- ធ្វើការសិក្សាអំពីសុចរិតភាពតុលាការ ដូចដែលបានព្រមព្រៀងនៅក្នុងសូចនាករតាមដានរួមរបស់ក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌។

**ចំណេះដឹងរបស់សាធារណៈជន និងដៃគូរថ្នាក់ជាតិ**

- ផលិតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈនៅក្នុងទម្រង់ខុសៗគ្នា នៅថ្នាក់ជាតិ (ប្រព័ន្ធផ្សព្វផ្សាយសង្គម វីដេអូ ផ្ទាំងបដា ចម្រៀងខ្លីៗតាមវិទ្យុ និងសារPSA ស្ប៉តទូរទស្សន៍ ការប្រើប្រាស់អ្នកដែលមានឥទ្ធិពល។ល។) ដោយធ្វើការគូសបញ្ជាក់ថា សកម្មភាពនៃ “ការកាត់ទោសដោយមហាជន” ជាអំពើខុសច្បាប់ និងថាជនគ្រប់រូបត្រូវទទួលបានផលប្រយោជន៍ពីការសន្មតទុកជាមុនថាគ្មានទោស និងការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយជនល្មើសនៃ “ការកាត់ទោសដោយមហាជន” នឹងត្រូវបានស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសដោយច្បាប់។
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋជាសាធារណៈ នៅថ្នាក់មូលដ្ឋាន អំពីប្បញ្ញត្តិនៃការរើសអើងក្នុងសង្គមគោលការណ៍សិទ្ធិមនុស្ស និងនីតិរដ្ឋជាពិសេសអំពីអំពើខុសច្បាប់នៃ “ការកាត់ទោសដោយមហាជន” ក៏ដូចជាសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងការសន្មតទុកជាមុនថាគ្មានទោស។
- លើកកម្ពស់ការយល់ដឹងនៅថ្នាក់មូលដ្ឋាន អំពីសិទ្ធិរបស់ជនមានពិការភាពរូបកាយ និងស្មារតី និងសិទ្ធិរបស់ពួកគេដែលត្រូវបានដាក់បញ្ចូល និងចូលរួមពេញលេញក្នុងសង្គមដោយគ្មានការរើសអើង។
- រៀបចំសន្និសីទ ឬកិច្ចពិភាក្សាថ្នាក់ជាតិ ដោយរួមបញ្ចូលអាជ្ញាធររាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន អ្នកដឹកនាំសាសនា និងតួអង្គប្រពៃណីបុរាណ ដូចជាគ្រូថ្នាំខ្មែរ ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីអំពើហឹង្សាលើអាបធ្មប់ និងជាមធ្យោបាយដើម្បីដោះស្រាយបញ្ហាអំពើហឹង្សារ ក៏ដូចជាបញ្ហាឫសគល់របស់វា។